
ប្រមូលភាសិតខ្មែរ
ប្រមូលភាសិតខ្មែរ
ផ្សាយចេញពីសមាគមសម្ដេច ជួន ណាត

# បុព្វកថា

ដោយការស្រាវជ្រាវរបស់យើងខ្ញុំ បានជួបប្រទះសុភាសិតសំខាន់ៗហើយមាននាមអ្នកនិពន្ធភាសិតច្បាស់លាស់ ក្នុងពេលដែលបោះពុម្ពជិតចប់ហើយនោះ ទើបបង្កើតឱ្យមានភាគពិសេសនេះឡើង ។ ក្នុងការបោះពុម្ពលើកទី១ នេះ ពុំបានសព្វគ្រប់ល្អតាមបំណងយើងខ្ញុំទេគឺ ៖

១-មាននៅខ្វះភាសិតច្រើនទៀត។

២- ភាសិតដែលមានហើយ រាវរកឈ្មោះអ្នកនិពន្ធ ពុំបានឃើញសព្វគ្រប់ពុំដឹងជាភាសិតរបស់លោកអ្នកណាខ្លះ ព្រោះបានជួបប្រទះ ច្រើនតែភាសិតអនាមិក។

ហេតុនេះហើយបើអស់លោក អ្នក នាង បានអាន ហើយបានស្គាល់ច្បាស់ជាភាសិត របស់លោក ឬស្គាល់ជារបស់អ្នកនិពន្ធណា សូមឱ្យដំណឹងមកយើងខ្ញុំផង ដើម្បីបាត់ការបោះពុម្ពលើកទី២ ឱ្យបានជាក់ស្តែងល្អទុកជាសម្បត្តិប្រទេសជាតិទៅអនាគត។

យើងខ្ញុំរង់ចាំទទួលភាសិតប្លែកៗ ដែលមានអត្ថន័យយ៉ាងសំខាន់ៗទៀត ដោយសង្ឃឹមថា អស់លោកអ្នកនាង នឹងផ្ញើមកឱ្យយើងខ្ញុំចារិកទុកក្នុងសៀវភៅ (ប្រមូលភាសិត) ដែលទុកដូចជាឃ្លាំងនេះជាពុំខាន ។

សូមផ្ញើមកបណ្ណាគារ **ម៉ិត-នាង**

សូមអរគុណទុកជាមុន

**នួន-ម៉ិត, ជុំ-មួន**

# ក

៚ កម្មករមែនពិត តែគំនិតឥតចង់ធ្វើខ្ញុំកំដរអ្នកណាទេ សាច់ឈាមថ្លាឆ្ងង់ស្មោះត្រង់នឹងជាតិ ។

៚ ករណីយកិច្ចជាគំរោងការ ដែលមនុស្សគ្រប់គ្នាត្រូវបំពេញតាមឋានៈខ្លួន ។ (ព្រះធម្មវរោត្តម តុង-ឈូន)

៚ ការកើតជាមនុស្សទោះប្រុសស្រី ចាស់ក្តីក្មេងក្តី តែងឃ្លាឃ្លាតចាកទីស្រឡាញ់ចេញចាកញាតិ មានជាតិមានទុក្ខ ទុក្ខខ្លាំងក្លា ។ (លោកគ្រូ ម៉ុក-សំឱក)

៚ ការកើតបានមកជារូបអង្គ ត្រូវផ្ចង់គំនិតនឹងប្រាជ្ញា ព្រមទាំងសេចក្តីខ្មីឧស្សាហ៍រៀនវិជ្ជាការឱ្យចេះស្ទាប់ ។ (តែ-ជុន)

៚ ការចេះចប់សព្វមន្តសិល្បវិជ្ជា មិនប្រើជាប្រយោជន៍ធ្ងន់តែខួរ ដូចពាក់មាសពេជ្របំប៉នព្យួរ ស្រីមិនគួរខាតធនធ្ងន់តែខ្លួន ។ (ញូង-សឿង)

៚ ការចេះសន្ទនាជាមួយភ្ញៀវ ទុកជាវិជ្ជាដ៏កម្រមួយ ត្រូវប្រើរបៀបមួយរយជំពូក ដើម្បីឱ្យភ្ញៀវរីករាយជានិច្ច ។ (ឈូក-ម៉ឹង-ម៉ៅ)

៚ ការដែលយើងធ្វើ នាំឱ្យយើងដុះដាលចិត្តគំនិតកាន់តែធំ កាន់តែខ្ពស់ កាន់តែរីកធំឡើង យើងធ្វើការជួយបង្កើតលោកទាំងមូល ។ (មាស-រឿង)

៚ ការបរិភោគ អាហារក្នុងលោក មិនដឹងប្រមាណ ស៊ីច្រើនចាក់ប្រាសវិបល្លាសសន្តាន ភ្លើងធាតុមិនបាន ដុតដូចប្រក្រតី ។ ចាត់ជាពិសពុល ព្រោះតែស៊ីជ្រុលនាំកាឡកណ្ណី ឱ្យមកគ្រប់ប្រាណ សន្តានប្រុសស្រី ព្រោះតែចំណី គប្បីរិះគិត។ (ព្រះគ្រូ

បញ្ញាលិខិត កៅ ស៊ីម)

៙ ការធ្វើឱ្យប្រាសចាករោគផ្សេងៗ ជាមូលដ្ឋានធំបំផុត នៃវឌ្ឍនភាពកម្ពុជា ការពារសុខភាព នៃបណ្ដាជន តុបតែង ព្រះរាជធានីយើងឱ្យបានជារាជធានី ល្អជាងគេនៅខាងបូព៌ាប្រទេស ផ្ដល់នូវសុខុមាភាពដល់បណ្ដាជនទាំងអស់គ្នា នេះហើយគោលបំណងជាអចិន្ត្រៃយ៍នៃរាជការក្រុមមឿង ។

៙ ការមិនបៀតបៀនគ្នា ជាប្រភពនៃសន្តិសុខក្នុងផ្ទៃលោក ។ (ព្រះធម្មវរោត្តម តុង-ឈួន)

៙ ការរចនាឯករាជ្យរបស់យើង ជាការពិបាកមែន ប៉ុន្តែនឹងបានផលប្រយោជន៍ច្រើន។

៙ ការអប់រំ គឺជាការហ្វឹកហ្វឺននូវសក្ដានុភាព ដែលជាគ្រឿងពង្រីកបណ្ដុះ ឬបង្កើតចំណេះវិជ្ជា ។

៙ កាលបើឃើញថា ការថ្មីធ្លាក់មកនៅក្នុងកណ្ដាប់ដៃហើយនោះ សឹមលះបង់ការចាស់ជាក្រោយ ។

៙ កាលបើមានភ្ញៀវចូលមករកអាត្មា ចូរចរចាតែពាក្យផ្អែមយ៉ាងស្រស់ស្រាយ ការរាប់អានបានយ៉ាងនេះឆ្ងាញ់ មាល្បាយលើសលុបអស់រសទាំងឡាយក្នុងផែនភព។

៙ កិច្ចការឯណា យើងបានគិតពិនិត្យសំឡឹង ទៅក្នុងអនាគតក្ដី បច្ចុប្បន្នក្ដីអតីតក្ដី ហើយមានប្រយោជន៍ នោះគួរយើងខំព្យាយាមធ្វើកិច្ចនោះឱ្យបានសម្រេចប្រយោជន៍ឡើង។ (ព្រះសាសនមុនី មាស-កង)

៙ កិត្តិយសនៃប្រទេសនីមួយៗ មិនមែនស្ថិតនៅលើមូលដ្ឋាន នៃឃាតកម្មមនុស្សម្នាក់

ឬពីរនាក់នោះទេ។ កុំគិតយល់អំពល់នឹងរូបំ អនិច្ចំមិនទៀងល្មៀងគ្រប់ប្រាណ កើតហើយស្លាប់ក្រឡាប់ព្រាត់ប្រាសឋាន ទុក្ខគ្មានស្រាន្តស្រាក ស្រុតផុតមួយថ្ងៃ ។ (អ្នកឧកញ៉ាមហាវិនិច្ឆ័យ នៅ)

៚ កុំគិតរៀនចង់ធ្វើមន្ត្រី ស្អប់ខ្ពើមដឹកនាំឱ្យក្រ ត្រូវរៀនធ្វើជាកសិករទើបមានទ្រព្យតទៅខាងក្រោយ ។

៚ កុំជិះចង្កេរលើកខ្លួនឯង ក្បាលទូលកញ្ច្រែងកុំក្អេងក្អាង កុំដេកទទូរចាំសំណាង កុំអាងព្រះប្រោសត្រូវតែប្រឹង ។

៚ កុំដេកចាំស្លាប់ អង្គុយចាំមាន ខ្ទាសល្ងង់ទើបចេះ ខ្ទាស់ក្រទើបមាន ដឹងខ្លួនថាល្ងង់គង់បានជាប្រាជ្ញ កុំស្លាប់មុនរស់ រស់ហើយសឹមស្លាប់ ចូរសេពអ្នកប្រាជ្ញ កុំត្រាប់មនុស្សពាល ។ (ព្រះគ្រូធម្មបណ្ឌិត គង់ ស៊ឹម)

៚ កុំរៀននៅទំនេរខាតការកម្ម កុំរៀនបណ្ដាក់ចាំជាពេលក្រោយ កុំរៀនប្រហែលមើលងាយនាំឆ្ងាយ កុំរៀនមិនឱ្យទានស្មូមយាចក ។

៚ កំហុសរមែងមានដល់អ្នកធ្វើ អ្នកនៅឥតអំពើបានអ្វីនឹងខុស ។

៚ កុំអាងថា បើមានមិនបាច់ខំ បើរលំមិនបាច់ច្រាន ។

៚ កុំឱ្យប្រព្រឹត្តទុច្ចរិត ដោយការគប់មិត្រលបចងពន្ធ លួចលាក់មានស្រី សហាយស្មន់ក្បត់ចិត្តប្រពន្ធឱ្យមួរហ្មង ។

៚ កុំឱ្យយកបញ្ហាសាសនាមកបន្លំ នឹងសេចក្តីរៀបរយខាងរដ្ឋបាល ។

៚ ក្រពះបង្កើតឱ្យមានបញ្ហាសេដ្ឋកិច្ចស្មុកស្មាញក្នុងលោក ។

៙ ព្រះរាជាហេតុដើម នៃការចលាចលក្នុងរដ្ឋនីមួយៗ នៃសង្គ្រាមក្នុងលោក។

**ជនត្រេកអរក្នុងធម៌ អាចនាំមកនូវសេចក្តីសុខ។**

ស្រង់ចាកសុភាសិតសម្តេចព្រះសុធម្មាធិបតី

សង្ឃនាយក **គណៈធម្មយុត្តិកនិកាយ ឥន្ទញ្ញាណោ** (ឥ,ន)

★ ★ ★

## ២

៙ ខន្ធទាំងឡាយប្រាំជាភារៈធ្ងន់ កូនប្រពន្ធក៏មានខន្ធប្រាំ បុគ្គលអ្នកនាំភារៈរងកម្ម ដោយសារខន្ធប្រាំត្រូតហើយត្រូតទៀត ។

៙ ខឹងខុសខូតខាត ប្រមាថលិចលង់ ។

៙ ខឹងឥតពិចារណា នាំខូចការខូចប្រយោជន៍ ធម៌ខឹងនាំអាសោចិ ខុសខាតខូចដោយមិនគិត ។

៙ ខ្មែរយើងភាគច្រើនបំផុត បានកាន់ព្រះពុទ្ធសាសនា ដែលជាសាសនានាំទៅកាន់សន្តិភាព ។

៙ ខំរកស៊ីធ្វើការ មិនអសារឥតប្រយោជន៍ ចង្រៃណាស់យ៉ាងហោចគង់គ្រប់ស៊ីមិនសុំគេ។ ប្រសិនមានសំណាង បានកសាងពីបុព្វេ ផ្សំផងមិនលេងទេ ឡើងជាកុដុម្ពិក៏សេដ្ឋី។

៙ ខ្យល់មិនបោកបក់រំលើងស្មៅ ដែលឱនទន់ទោរទៅគ្រប់ទិសតំបន់ទេនេះជាភាពនៃបុគ្គលធំតូចក្នុងលោកនេះ អ្នកផងធ្វើសង្គ្រាមចំពោះអ្នកធំដូចខ្យល់បក់រំលំឈើណាដែលធំៗ ។ (បញ្ញតន្ត្រៈមហាវិរិយបណ្ឌិតោ ប៉ាង ខាត់) ។

**ចៀសចាកអកុសល ក្តីអំពល់ពីទុក្ខសោក រូបរាងតែងស្មោកគ្រោក**

**គួរឱ្យរកព្រះអរហំ**។ ស្រង់ចាកសុភាសិត សម្តេចព្រះមហាសុមេធាធិបតី

សង្ឃនាយក **គណៈមហានិកាយ ចន្ទត្ថេរោ (ប្រាក់ ហ៊ិន)**

# គ

៙ គុកនិងសោរគឺចោរបង្កើត ឱសថល្អឆើតកើតពីរោគ ដំណោកកើតពីការងុយងោក មនុស្សក្នុងលោកកើតពីកម្ម ។

៙ គួរគិតជីវិតពុំទៀងទាត់ តែងតែបែរបត់កាន់ក្តីស្លាប់ ពុំដែលបានស្រួលប្រែប្រួលឆាប់ ក្រឡាប់ស្ងាត់សូន្យចាកកូនចៅ ។

៙ គួរនិយាយទូន្មានគ្នា និងគួរហាមឃាត់គ្នា ឱ្យបានមុនធ្វើអំពើខុសឬការអាក្រក់។

៙ គេទុកវិធីពេទ្យវិទ្យាសាស្ត្រជាអាវុធមានមុខពីរ អាចធ្វើឱ្យមនុស្សជារោគក៏បាន ស្លាប់ក៏បាន បើអ្នកកាន់អាវុធនោះគ្មានសមត្ថភាព ។

៙ គ្មានកម្លាំង គ្មានបញ្ញា គ្មានអាហារ គ្មានជីវិត ។

៙ គ្រប់កាលទាំងពួង ព្រះរាជាដែលមានសេចក្តីទុក្ខព្រួយធ្លាក់មកដល់រមែងទៅជាគ្រឿងលេងនៃមន្ត្រីទាំងឡាយ ព្រោះហេតុនេះឯងបានជាមន្ត្រីតែងត្រូវការព្រះបតីដែលមានទុក្ខ ។ (បញ្ចតន្ត្រ: មហាវិរិយបណ្ឌិតោ ប៉ាង ខាត់)

៙ គ្រួសារដែលរីករាយ គឺដោយសារភរិយា ព្រោះភរិយានេះហើយដែលចេះប្រចុកប្រចែងស្វាមី មានការតាក់តែងគេហដ្ឋានឱ្យជាទីគាប់ចិត្តនៃប្តី និងប្រើវាចាផ្អែមពីរោះ។

**ចេះនិយាយស្ដីដូចព្រះ តែចិត្តមានះដូចទេវទត្ត**

ស្រង់ចាកសុភាសិត សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា

**ទជីទច្បព្ញោ (លី្វ ឯម)**

# ឃ

៙ ឃាត់កំហឹងដោយប្រឹងអត់ឱ្យបាន ឃាត់ពាលសាមាន្យដោយអាជ្ញា បុគ្គលឃាត់ចិត្តចាកទោសា ប្រសើរថ្លៃថ្លាក្នុងលោកិយ ។

៙ ឃាត់ចិត្តចាកក្តីស្នេហា ក្នុងកាមតណ្ហានាលោកិយ ដូចយកអំបោះចងដំរី ពិបាកពេកក្រៃគួររៀរមុន ។

៙ ឃុបឃិតជនពាលរាលទុក្ខដល់ខ្លួន ។

៙ ឃុបឃិតបណ្ឌិត សុខមួយជីវិតឥតទុក្ខា ឃើញខ្លាដេកថាខ្លាស្លាប់ ឃើញខ្លាក្រាបថាខ្លាសំពះ ឃើញគេទៅកុំឱ្យខាន ឃើញគេបានកុំឱ្យទៅ ។

៙ ឃើញឈើពុកកុំអាលដាក់គូថអង្គុយ ឬ(កុំអាលដាក់គូថលើ) ។

៙ ឃើញដំរីជុះកុំជុះតាមដំរី ឬ(ដំរីជុះ កុំជុះតាមដំរី) ។

៙ ឃើញថ្លុកថាជាថ្នល់ ក្រែងកំហល់កំហុសមាន។

៙ ឃើញពីនាយកុំអាលទាយអាក្រក់ល្អ លុះឃើញជាក់ជាខ្មៅសទើបថាបាន បើបណ្តោយតាមគំនិតដែលគិតស្មាន នឹងរំខានព្រោះការខុសកំហុសខ្លួន ។

៙ ឃើញសម្បកថាខ្លឹមរុក្ខា យល់ពួកបច្ចាថាជាមិត្រ ពាលច្រឡំថាបណ្ឌិត ច្រឡំលាមកពិតថាបុប្ផា ។

៙ ឃ្មុំកន្លង់រៀរបងឈើគ្មានផ្កា សត្វម្រឹគារៀរបងព្រៃភ្លើងឆេះ សត្វបក្សីរៀរឈើគ្មានផ្លែបេះ ចោរតែងវេះរៀរចាកចោរ៍បុព្វេ ។

៙ ឃ្លានកុំអាលស៊ី ងងុយកុំអាលដេក ។

៙ ឃ្លានក្រៃណាឆ្ងាញ់ ស្រឡាញ់ក្រៃណាល្អ ឬ(ពិសាក្រៃណានឹងឃ្លានអាក្រក់ប៉ុន្មានក្រៃណានឹងចិត្ត) ។

៙ ឃ្លេមិនខ្លាច ទៅខ្លាចខ្លា (រឿងអាខ្វាក់អាខ្វិន) ។

៙ ឃ្លោកលិច អម្បែងអណ្តែត ។

៙ ឃ្វាលក្របីជិះក្របី ឃ្វាលគោជិះគោ ។

៙ ឃ្វាលចិត្តលំបាកពេកពិត ដូចឃ្វាលពពក ។

៙ ឃ្វាលគោក្របីដោយអាជ្ញា ឃ្វាលចិត្តល្អជាដោយអំណត់ ។

៙ ឃ្វាលចិត្តឥតកំណាញ់ ដោយលះបង់កុំប្រណី ។

៙ ឃ្វាលនគរដោយពលរដ្ឋប្រុសស្រី រួមសាមគ្គីតាមរដ្ឋបុរសជាតិ ។

**កើតមកជាកូនប្រុស ត្រូវតែខំប្រឹងបំពេញករណីកិច្ច**

**លុះត្រាតែបានសម្រេចៗ ការអ្វីមិនទាន់ស្រេច**

**កុំឱ្យប្រញាប់ពោលអួត ៗ**

ស្រង់ចាក់សុភាតសិត សម្រេចព្រះមហាសុមេធាធិបតី

សង្ឃនាយក **គណៈមហានិកាយ (ជោតញ្ញាណោ ជ ណ)**

# ង

- ងប់នឹងកូនប្រពន្ធទ្រព្យ ព្រះថាអភ័ព្វព្រោះជាប់ចំណង ។
- ងប់នឹងញាតិឃ្លាតច្បាប់ ។
- ងប់នឹងមាសប្រាក់ខូចយសសក្តា ។
- ងប់នឹងប្រុសខូចព្រហ្មចារី ។
- ងប់នឹងស្រីចំណីទុក្ខ ។
- ងប់នឹងល្បែងតែងហិនហោច ។
- ងប់នឹងស្រាខូចស្មារតី ។
- ងប់នឹងពាក្យសរសើរគេថាភ្លើ ។
- ងប់នឹងពាក្យបង្គាប់ស្លាប់គំនិត ។
- ងប់នឹងស័ក្តិយសស្អុយទាំងអស់ក្នុងលោកិយ ។
- ងប់នឹងជំនឿរឿគំនិត ។
- ងាប់ដើម្បីជាតិមាតុភូមិ ទេវតាឥន្ទ្រព្រហ្មចោមឱ្យពរ ។
- ងាប់ខ្លួន សមសួនជាងងាប់កេរ្តិ៍ឈ្មោះ ។
- ងាប់គំនិត ងងឹតដល់ស្លាប់ ។

៚ ងាប់ទាំងរស់ ស្អុយទាំងស្រស់ ។

៚ ងាប់ដៃជើង ច្រើងជាងងាប់ពាក្យសម្ដី ។

៚ ងាប់នឹងស្រី ចង្រៃមួយជាតិ ។

៚ ងាប់នឹងប្រុស ខូចឈ្មោះមួយជាតិ ។

៚ ងាប់នឹងសម្ដី ដូចត្រីកំភ្លាញ ។

៚ ងាប់នឹងអាចម៍ឯង ជាក់ស្តែងដូចខ្វែក ។

៚ ងាប់ព្រោះគំនិត ដូចកាំបិតចិតដងឯង ។

៚ ងាប់ជាតិ ព្រោះឃ្លាតសាមគ្គី ។

៚ ងាប់នយោបាយ ព្រោះស្ដាយលាភ ។ ៚ ងាប់ស្លូក ដូចឃ្លោកទុំ ។

៚ ងាយមិនក្រៃណានឹងបាន មានមិនក្រៃណានឹងអ្នកបានសុខ ចេះក្ដីមិនក្រៃណានឹងម្ចាស់ស្រុក ។

៚ ងើបស្កក ឱនដាក់ក្រាប់ ឬ(ងើយ...) ។

**អ្នកណាបានធម៌ព្រះ ជឿជាក់ច្បាស់កាន់រក្សា**

**ស្មើបានយានត្រេត្រា នាំមាតាបិតាបានខ្ព**

ស្រង់ចាកសុភាសិត សម្ដេចព្រះមហាសុមេធាធិបតី

សង្ឃនាយក **គណៈមហានិកាយ ចន្ទត្ថេរោ (ប្រាក់ ហ៊ិន)**

## ច

៚ ចងអ្វីមិនជាប់ស្មើសង្សារ ការអ្វីមិនស្មើការប្រតិបត្តិ ស្វាត់អ្វីមិនស្មើចិត្តអរហត្ត កាចអ្វីមិនស្មើចិត្តពាលា ។

៚ ចងទូកបោះបង្គោល រិះរកថ្នោលពួរយុថ្កា (ការខ្យល់ព្យុះកាចជាក្រែងពានពាបោកបែកបាក់) ។

៚ ចងជនលោភដោយឱ្យធនធាន ចងប្រាជ្ញកល្យាណដោយពាក្យសត្យ ចងអ្នកឆ្មើងឆ្មៃដោយប្រណិប័តន៍ ចងអ្នកល្ងង់ក្អត់ដោយបណ្តោយតាម ។

៚ ចចើងចង់លាភវែងបាត់ធន់ទៅ ។

៚ ចចេសមិនចង់ត្រង់ឈើចាប់ មិនចង់ចាស់ស្លាប់ចាកធម្មតា តែចិត្តខ្មើមស្អប់សីលចរិយា នេះជាអាការៈពាលជន ។

៚ ចង់ដឹងភាពមនុស្សដោយសេពគប់ ចង់ដឹងភូមិភពដោយទស្សនា ដឹងពាលបណ្ឌិតដោយវាចា ចង់ដឹងអាត្មាត្រូវអប់រំ ។

៚ ចង់គាប់ប្រើស្វះស្វែង រករៀនរិះសារពើក្តី ។

៚ ចង់គុណឱ្យទុក្ខ ចង់បានក្តីសុខឱ្យស្វែងដើររក ឬ (ចង់គង់ឱ្យទុក) ។

៚ ចង់ចេះឱ្យសំលាប់អាចារ្យ ចង់បានផ្លែផ្កាឱ្យយកភ្លើងដុតគល់ ។

៚ ចង់ចេះឱ្យធ្វើល្ងង់ ។

៚ ចង់បានប្រាណជាប្រុសឱ្យទាត់ទៀង រៀងៗរាល់ជាតិអសង្ខេយ្យ គួររៀរប្រពន្ធអ្នក

ដទៃ និស្ស័យកាមេនឹងប្រែភេទ ។

๛ ចង់បានសុខតត្រុកចូលក្រុមភាគច្រើន មិនក្រវើនមើលមុខក្រោយឱ្យច្បាស់ការ ឰតែផ្គរចាក់ទឹកចោលបង់អាសារ ដល់គញមានភ្លៀងរត់ឆ្លេឆ្លាររកទឹកគ្មាន ។

๛ ចង់ដឹងសេះលឿនដោយជវ័ន ចង់ដឹងគោគ្រាន់ដោយរទេះ ចង់ដឹងទឹកដោះដោយរួតកែះ ចង់ដឹងប្រាជ្ញចេះដោយចរចា ។

๛ ចង់ឆ្ងាញ់ឱ្យរកអន្លក់ ចង់ស្រណុកឱ្យនឿយពីក្មេង ឬ (ចង់ពិសាឱ្យរកអន្លក់) ។

๛ ចង់បុណ្យបានបាប ចចើងចង់លាភ វែងបាត់ធនទៅ ។

๛ ចង់ធំឱ្យតូច ចង់ខ្ពស់ឱ្យទាប ចង់បានឱ្យបង់ ចង់ចេះឱ្យរៀន ចង់ទៀងឱ្យត្រង់ ចង់ស្រួលឱ្យស្រង់ ខ្លួនពិបាក ។

๛ ចង់ធំខំពីតូច បើខ្លាចខូចកុំឆាប់ខឹង ការអ្វីឱ្យចេះថ្លឹង កុំប្រឹងជុះតាមដំរី ។

๛ ចង់ល្អហួសមាឌ ចង់បានហួសខ្នាត កម្រិតមាត្រា មិនបានដូចប៉ង បំណងប្រាថ្នា ខូចទាំងទ្រព្យា គួរបានក៏បង់ ។

๛ ចង់បានវាបង់ ចង់មានទ្រទ្រង់ ចង់ត្រូវបានខុស ចង់ខ្ពស់បានទាប ដោយហេតុកំហុស ដែលខ្លួនបណ្ដុះ បណ្ដោយឱ្យផល ។

๛ ចង់បានហួសខ្នាត ច្រើនតែបង់ខាត ខកខូចលាភា ខាតបង់ចំណេញ ច្រើនហួសមាត្រា ដូចពាក្យចាស់ថា លាភវែងបាត់ធន ។

๛ ចង់ច្រើនបានតិច ក្រោកដើររឹលរេច បានខាតទទេ ខំចេញជួញឆ្ងាយ ពុំបានទំនេរ ប្រែខាតបង់កេរ្តិ៍ ដើមទុនចេញទៅ ។

៚ ចង់ស្តាប់សំឡេងដែលពីរោះ ចំពោះជាចង់គ្មានស្រាកស្រន់ ចង់ស្រូបរសក្លិនមិនឆ្អែតឆ្អន់ ព័ន្ធជោដ្ឋញ្ញធម្មារម្មណ៍ ។

៚ ចង់ប្រាជ្ញឱ្យខំប្រឹង ចងក្បិនតឹងរកស៊ីធូរ គំនិតមុនគំនូរ រៀនធ្វើគ្រូ មានគេរាប់ ។

៚ ចង់ដឹងខ្ញុំឱ្យមើលពេលធ្វើការ ចង់ដឹងវង្សាក្នុងពេលដែលកើតទុក្ខ ចង់ដឹងមិត្រក្នុងកាលភ័យមកផ្ទុក ចង់ដឹងប្រពន្ធកាលទុក្ខអស់សម្បត្តិ ឬ (កាលទុក្ខអស់សម្បត្តិ) ។

៚ ចង្អៀតផ្ទះនៅបាន ចង្អៀតចិត្តនៅពុំបាន ។

៚ ចង់ស្រួលដូចបន្លា ត្រូវឧស្សាហ៍ដុសដែកដុល ។

៚ ចង់ឱ្យគេកោតស្ញប់ស្ញែងក្រែងអំណាច ឱ្យគេខ្លាចគេសរសើរថាក្លាហាន តែតម្លៃខ្លួនមិនដល់ដូចស្មាន នោះនឹងបានតែវិនាសខ្លួនទេតើ ។

៚ ចាក់អង្ករយកអង្កាម ឬ(កុំចាក់អង្ករយកអង្កាម) ។

៚ ចាញ់ចត្រង្គអស់ប្រាជ្ញា ចាញ់តណ្ហាអស់កុសល ។

៚ ចាញ់បានជាព្រះ ឈ្នះបានជាមារ ។

៚ ចាញ់ល្បែងអស់ទ្រព្យធន ចាញ់ប្រពន្ធអស់សិរី ចាញ់ក្ដីអស់គំនិត ។

៚ ចានមួយរាវ លែងអីរណ្តំគ្នា ឬ (ចានក្នុងរាវ...) ។

៚ ចាបមួយនៅនៃប្រសើរក្រៃ ជាងចាបដប់នៅលើឈើ ។

៚ ចាប់នេះចាប់នោះ មិនឆ្ពោះត្រង់ណា ។

៚ ចាប់ការឱ្យជាប់បាន ខំប្តូរប្រាណសម្រេចផល សាងជាតិចេះកិច្ចកល ស៊ូឱ្យដល់

ទើបដាំដុះ ។

៚ ចាប់ច្រវាក្រាក សំឡឹងជ្រោយ ។

៚ ចាប់ត្រីបានកុំឱ្យល្អក់ទឹក ។

៚ ចាប់ត្រីដៃពីរតម្រាបហាម ចាក់អង្គុរយកអង្កាមហាមមិនឈ្នះ អុំទូកឡើងភ្នំខំមានះ បង់ព្រះទៅសំពះឯបាយាប ខ្លះថា (បន់ព្រះ) ។

៚ ចាប់ចោរ ចោរចាប់វិញ ។

៚ ចាប់វល្លិមួយ រញ្ជួយរាល់ដើម ។

៚ ចាយវាយក្រៅមត្រា នៅវិនាសធនធានផង ឬ(នូវវិនាស...) ។

៚ ចាស់ដូងចាស់ត្នោត ។

៚ ចាស់អាងស្លាប់ ពាលអាងកាប់ ក្មេងអាងយំ ។

៚ ចាស់កោងកាន់ច្រត់ អួតអាងប្រគំ ក្លួរអួតផ្លុំ ប៉ិពកយកខ្យល់ ។

៚ ចាស់ធ្វើគួរយើងកោត ថាចាស់ឆោតមិនបាន អ្នកឆោតខុសលំអាន សាច់សន្តានសត្វក្រៀល ។

៚ ចាស់ថានៅស្រុកស្រាស់បន្លា អារសាច់ជូនខ្លាកុំខ្លាចស្តាយ វិជ្ជានឹងកើតមកបីកាយ កុំណាយខ្លាចនឿយគិតឱ្យយូរ ។

៚ ចាស់ចើកបានចួននួនក្រមុំ ដោះក្បំពកប៉ុនផ្លែទន្លាប់ សែនស្រឡាញ់ពេញចិត្តប្រព្រឹត្តជាប់ របស់អ្វីក៏ផ្កាប់វាទាំងអស់ ។

៙ វាអើយឡើងកាលណាក៏ឱ្យភ្លាម ស៊ូព្យាយាមអង្អែលទន្លាប់ស្រស់ ស៊ីពុំបានក៏ស៊ូហិតតែរស ការទាំងអស់ជាហេតុបរាមុខ (បរាភវសូត្រ) ។

៙ ចិញ្ចឹមបំពង់បាយ ។

៙ ចិញ្ចឹមមនុស្សខូច ដូចចិញ្ចឹមកូនខ្លា ។

៙ ចិញ្ចឹមមនុស្សឱ្យមើលចិត្ត ចិញ្ចឹមសត្វឱ្យមើលចង្កូម ។

៙ ចិញ្ចឹមគោក្របី រកខ្សែវល្លិបោះក្រោយឃ្នង ។

៙ ចិញ្ចឹមកូនខ្លា វាសងគុណ ។

៙ ចិត្តជនអ្នកលោភដូចសាគរធំ ទន្លេប្រជុំពុំមានស្កប់ស្កល់ ទោះបីមានទ្រព្យនៅសេសសល់ គង់តែកិច្ចកលនៅពោលថាក្រ ។

៙ ចិត្តចង់កុំអាលស៊ី យល់តែស្រីកុំអាលចង់ ។

៙ ចិត្តជាទេវត្ត មាត់ជាទេវតា ។

៙ ចិត្តដាច់នៅស្រី ។

៙ ចិត្តល្អ ក្រខ្លួន ។

៙ ចិត្តល្អក្រមិនយូរ ឬ (មិនក្រយូរ) ។

៙ ចិត្តជាមេទ័ព ត្រូវច្បាំងប្រារព្ធ ទប់ទល់អន្តការ បើចិត្តក្លាហាន មិនបានរួញរាដល់ពេលទុក្ខា ភក្ត្រាញញឹម ។

៙ ចិត្តរេបែរទៅខាងផ្លូវលោក តែងតែសោយសោកគួរអាណិត បើអែបនែបខាងផ្លូវធម៌

ស្និទ្ធ ចេញពីងងឹតភ្លឺស្វាងទែង ។

៙ ចិត្តល្អតាមកាល ភារៈធ្ងន់ស្រាលត្រូវបើកកិរិយា ធ្វើភាពប្រើសព្រៃនៅជិតមាត់ខ្លា ធ្វើឫកហានក្លា អង់អាចតាមកាល។

៙ ចិត្តឧបាទានគ្មានស្គាល់ទុក្ខ ភ្លេចមុខភ្លេចក្រោយឱ្យតែជួន ខំឱបបាច់ឆ្អឹងមិនដឹងខ្លួន ចំនួនបីរយកំណាត់ប្លាយ ។

៙ ចិត្តនៃបុគ្គលកាលលោកធម៌ ប៉ះមិនញាប់ញ័រមិនសោកា ប្រាសចាកតម្រេកក្សេម ក្សាន្តចិន្តា ទាំងបួននេះជាសួស្តីប្រសើរ ឬ(ជាមង្គលប្រសើរ) ។ (មង្គលសូត្រ)

៙ ចិត្តចង់ធ្វើមាត់ថាធ្វើដៃមិនធ្វើ តើអំពើនោះកើតការយ៉ាងណា បានតែខំអាង សំណាងព្រេងជាប្រមាណ មុនជាខានបានឃើញផលដល់តិចឡើយ ។

៙ ចិត្តក្នុងពាល់លោក ផ្អែមតែពាក្យនិងសម្ដី កូនចៅទាំងប្រុសស្រី កុំបីត្រាប់មនុស្ស យ៉ាងហ្នឹង ។

៙ ចុះទឹកក្រពើ ឡើងលើខ្លា ។

៙ ចុះទូកកុំឱ្យចុះកន្សៃ្យ ទៅព្រៃកុំឱ្យបាំងជម្រុំ ។

៙ ចូរសេពអ្នកប្រាជ្ញ កុំត្រាប់មនុស្សពាល ។

៙ ចូរមើលកាលវែង កុំមើលកាលខ្លី ។

៙ ចូររកពូជល្អសាបព្រោះទុក តទៅអនាគតបើដីមានជី ឱ្យផលចំហុត ច្រូតកាត់ឆាប់ ផុត ផុតភ័យអន្តរាយ ។

៚ ចូលស្ទឹងតាមបត់ ចូលទូកតាមកំពង់ ចូលស្រុកតាមប្រទេស ។

៚ ចូលជិតព្រះអាទិត្យដោយខ្នង ចូលជិតកងអគ្គីដោយខាងពោះ ចូលជិតម្ចាស់ដោយភោគភាគចន្លោះ ចូលជិតឆ្ពោះបរលោកដោយឥតមោហ៍ ។

៚ ចូរព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ បានស្គរនិងទឹកឃ្មុំ ពួនក្នុងផ្ទះឆីម្នាក់ឯង ។ ចៀសសត្វមានស្នែង ៥០ហត្ថ ចៀសសត្វសេះហត្ថមួយរយ៉ា ចៀសដំរីមានភ្លុកពាន់ហត្ថា ចៀសជនពាលាចេញចាកស្រុក ។

៚ ចេកស្លាប់ព្រោះផ្លែ ។

៚ ចេញពីខ្លួនមិនទាន់ចួននៅឡើយទេ ត្រូវគ្នាន់គ្នេរយកពីគេមកផ្សំផង ទើបការនោះបានបែបបទល្អហ្មត់ហ្មង តាមបំណងប៉ងប្រាថ្នាក្នុងការល្អ ។

៚ នេះគេថាកាច ប្រាជ្ញាគេថាព្រើល ឬ(គេចេះថាគេកាច គេប្រាជ្ញថាគេព្រើស) ។

៚ ចេះច្បាប់មិនខ្លាចក្ដី ចេះវិន័យមិនខ្លាចអាបត្តិ ឬ(មិនខ្លាចសង្ឃ) ។

៚ ចេះរបេះក្បាច់ ឬ(ច្រើនចេះរបេះក្បាច់) ។

៚ ចេះពីរៀន មានពីរក ក្រពិខ្ជិល។

៚ ចេះមួយចេះពីរឱ្យតែស្ទាត់ ប្រកបប្រាកដអ្នកចំណាន ជាហេតុចិញ្ចឹមជីវិតបានសន្តានជួយពឹងពំនឹងអីយ ឬ(សន្តានចូលពឹង...) ។

៚ ចេះដប់មិនស្មើប្រសប់មួយ ឬ(អ្នកចេះដប់...) ។

៚ ចេះឯងមិនក្រែងចេះគេ ពូកែឯងមិនក្រែងពូកែគេ ។

- ចេះមិនឈ្នះចង់ ។

- ចេះមែនហើយតែនៅឡើយមិនទាន់ចេះ ព្រោះចំពោះច្រើនលើសលុបគ្រប់បែបយ៉ាង និងគុណនារាប់មិនបានមានជាតាង កុំអាលអាងថាចេះចប់សព្វអស់ហើយ ។

- ចេះឯងឱ្យក្រែងចេះគេ ។

- ដៃតូច[1] ខ្លួនទាប ចង់ឈោងចាប់ផ្កាយ ។

- ចោរព្រៃហ៊ានដោយសារស្រុក ខ្មោចក្រៅលុបខ្មោចក្នុងញ៉ាំង ប្រទេសក្រៅមិនហ៊ានចូលមកច្បាំង បើមិនមានខ្មាំងក្នុងស្រុកក្បត់ ។

- ចោលសាច់ស្រវាឆ្អឹង ទំពាររទៅរឹងបែររកសាច់វិញ ។

- ចៅហ្វាយមានបុណ្យខុនមានស័ក្តិ ចៅហ្វាយអប្បលក្ខណ៍ ខុនធ្លាក់អណ្តូង ឬ(ខុនធ្លាក់តត្លូង) ។

- ចំបាប់នឹងលោកសង្ឃ ខ្លាចអ្វីនឹងកាន់ព្រះកេស[2] ឬ(កុំខ្លាចកាន់ព្រះកេស) ។

- ចំណីច្រើនមុខច្រើនពិសា កូនច្រើនបានច្រើនល្អ ឬ(សម្លច្រើនមុខច្រើនពិសា) ។

- ចំណីឆ្ងាញ់កុំទុកស្អែក ប្រពន្ធគាប់ភ្នែកកុំឱ្យដើរក្រោយ ។

- ចំណែកជនមានចំណេះចេះវិជ្ជា គួរនាំគ្នាស្ញើចសរសើរគេទៅចុះ ចំណែកជនគ្មានវិជ្ជាគ្នាធ្វើខុស កុំបន្ទុះគួរមេត្តាករុណាផង ។

- ចំណេះវិជ្ជាលោកចែងចាត់ ទុកជាសម្បត្តិសម្បូរបាន ទោះបីក្រខ្សត់អត់ប៉ុន្មាន គង់

---
[1] មនុស្សថៃ គឺមនុស្សតូចទាបពេកខុសខ្នាត ។

[2] កេស (ក្បាល) ។

តែបានគ្រាន់អាស្រ័យ ។

៙ ចំណោះជិះកឯង ។

៙ ចាំក្បួនចាំឱ្យស្ទាត់ កុំអៀនប្រៀនផ្សំពាក្យពោល (សមពាក្យពោល) ។

៙ ច្បាប់ក្បួនតម្រា មែនមានខ្លឹមសារ គួរខំរៀនសូត្រ ឱ្យបានចេះដឹង គ្រាន់ជាចង្កូត នៃប្រាណរបូត ដល់ត្រើយជោគជ័យ ។

៙ ច្បាប់ពុំឈ្នះ (មានះ) មនុស្សពាលនឹងកាំភ្លើង គួរតែយើងពុំទទឹងរឹង ខ្វាយខ្វល់គួរបណ្ដោយឱ្យខ្លែងហើរទៅតាមកល តែអស់ខ្យល់មុខជាធ្លាក់ជាក់ប្រាកដ ។

៙ ច្របាច់កចិន លៀនអណ្ដាតខ្មែរ ។

៙ ច្រើនមកពីតិច ដោយចម្រើនកិច្ច ខាងការសន្សំ ដូចប្រទ្បាយតូច ក្លាយជាស្ទឹងធំហូរប្រាសព្រោះចំ យូររឹតធំសាយ ។

៙ ច្រែះកើតពីដែក តែងតែទំពាស៊ីដែកវិញ (ពុទ្ធភាសិត) ។

★ ★ ★

## ឆ

៚ ឆ័ត្រថ្មថ្មដាជាជាតិធ្ងន់ ចិត្តទេពអត់ធន់មហិមា អ្នកតាមឱវាទចាស់ព្រឹទ្ធា ហៅធ្ងន់មួយសាលើសលែងក្រៃ ។

៚ ព្រះបន្ទូលព្រះពុទ្ធវិសេសលន់ ធ្ងន់ក្រៃលែងធ្ងន់ផុតនិស្ស័យ ព្រោះជាកំពូលលើភពត្រៃ រកអ្វីមកថ្លៃថ្លឹងពុំបាន ។

៚ ឆ្លួតស្រី ឆ្លួតស្រា ឆ្លួតល្បែងពាលា អំពើឆ្គាំឆ្គង ។

៚ ឆ្កែខាំឱ្យរកម្ចាស់ គោឆ្កឹះឱ្យរកនាយ ។

៚ ឆ្កែព្រុសមិនដឹងខាំ ផ្គរលាន់រអាំមិនដែលភ្លៀង ។

៚ ឆ្កែចចកកុំត្រាប់រាជសីហ៍ សត្វបក្សីកុំត្រាប់រាជហង្សា អ្នកល្ងង់ខ្លៅកុំត្រាប់អ្នកប្រាជ្ញា បាគូភ្លៀវក្លាកុំត្រាប់សត្វសសេះ ។

៚ ឆ្កែទាល់ច្រក រលកទាល់ច្រាំង ។

៚ ឆ្កែជាឱ្យបាយឆី ដេកនៅដីចាំធនធាន គ្រឿងសឹកទុកទាហ៊ាន គេរ៉ែគម្ពីរទុកប្រាជ្ញប្រាយ ។ (កិរកាល)

៚ ឆ្ងាញ់កាមញ៉ាមស្អិត ឆ្ងាញ់សុភាសិតស្អិតលើសកាម ។

៚ ឆ្ងាញ់មាត់មិនស្អិត ដូចចិត្តឆ្ងាញ់ ។

៚ ឆ្ងាយកាយ ណាយចិត្ត ។

- ឆ្មាកន្ទុយខ្មៀន ឬមនុស្សឆ្មាកន្ទុយខ្មៀន ឬ(ធ្លាក់ខូច ឬធ្លាប់មានពុតដូចឆ្មាកន្ទុយខ្មៀន) ។

- ឆ្មាមិននៅកណ្ដុរឡើងរាជ្យ ។

- ឆ្លុះកញ្ចក់ឆ្មេចនេត្រា ។

- ឆ្លៀតកេងកិបចំពោះអ្នកឱ្យផល ដោយប្រើកលគិតគំនិតថោកថាគេ មិនដឹងប្រឹងឆបោក នេះហៅចាប់បោកឆ្នាំងបាយឯង ។

- ឆ្លៀតពងដូចត្រីងៀត ។

- ឆ្អឹងស្រែក ស្បែកហៅ ឬ(ឈាមស្រែកស្បែកហៅ) ។

- ឆ្អិនសឹមស៊ី ។

- ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ ។

- ឆ្អិនគំនិតពិតជាឆ្អិនគ្រប់យ៉ាង ឆ្អិនព្រេងសំណាងផុតទុក្ខា ។

- ឆ្អិនឆ្ងាញ់យ៉ាងណាកុំសារ៉ាភ្លេចកាលឆៅ ធម្មតាឆ្អិនទើបកើតក្រោយដោយសារក្ដៅ បើគ្មានឆៅតើបានឆ្អិនមកពីណា ។

**កុំយកវិជ្ជា ទៅប្រឡង ឬប្រកួតនឹងវាសនា ៕**

ស្រង់ចាកសុភាសិត (ព្រះឧត្ដមមុនី អ៊ុំ ស៊ូ)

# ៥

៚ ជក់នឹងល្បែងតែងវិនាស ឬ(តែងហិនហោច) ។

៚ ជនណាអេះដែលចេះគិតប្រព្រឹត្តត្រូវ ទៀងតាមផ្លូវសុភាសិតពិតប្រាកដមិនលំអៀង ឃ្លៀងឃ្លាតទីពីអត្ថបទ យើងសន្មត់ថារកបានដោយកម្រ ។

៚ ជនណាស្តាប់ត្រាប់ត្រងតាមសុភាសិត ជននោះស្ថិតក្នុងចំណោមអ្នកប្រាជ្ញប្រាយ តែងលេចឈ្មោះបោះសំឡេងឮវែងឆ្ងាយ ល្បីសុសសាយជាអ្នកប្រាជ្ញអាចចេះដឹង ។

៚ ជនណាល្ងើលមើលឃើញតែទ្រព្យលោកិយ ជននោះមើលឃើញផ្លូវខ្លីពន់ពេកណាស់ ទ្រព្យនេះឯងតែងមិនទៀងជាងជាក់ច្បាស់ នឹងក្រឡាស់ផ្លាស់ជាទោសក៏សឹងមាន ។

៚ ជនឯណាវេចរុំនូវក្រឹស្នា ដោយស្លឹកឈើធម្មតាឬក្រដាស ក្លិនក្រឹស្នាក៏ផ្សព្វផ្សាយពេញពាស ក្រអូបដាស់ដល់ជនអ្នកវេចនោះ ។

៚ មិនប៉ុន្តែប៉ុណ្ណោះទោះស្លឹកវេច ក៏ជាប់ក្លិនដាសលេចឡើងចំពោះ ដូចបុគ្គលគប់ប្រាជ្ញអាចភ្លឺផ្លុះ មានឧបមេយ្យដូច្នោះប្រាជ្ញគួរដឹង ។

៚ ជនជួកាន់យកទោសទុក្ខ ដូចកល់ជ្រូកស្រុកប៉ងអាចមន ជនល្អកាន់យកគុណឧត្តមដូចហង្សប៉ងចំចឹកទឹកដោះ ។

៚ ជនឯណាកំចាត់ក្តៅក្រោធបាន ជននោះគ្មានសោកសាន្តក្នុងលោកិយ ព្រះឥសីសរសើរអ្នកគប្បី លះបង់ក្តីលុបគុណគាប់សត្យា ។

៙ អ្នកឯណាអាចអត់ផរុសវាទ មិនលោភដោយពាក្យបេសុញ្ញា សប្បុរសសរសើរអ្នកនោះណា កបខន្តីគឺតិក្ខាដ៏ឧត្តម ។

៙ ជនឯណាដឹងពាក្យពោលគួរសម និងពាក្យប្រិយភិរម្យពីរោះពិត ដឹងក្តីក្រោធសភាពប្រាណប្រព្រឹត្ត ជននោះហៅបណ្ឌិតពិតក្នុងលោក ។

៙ ជនខ្សត់ចង់ស៊ីរស់ខ្ពស់ខ្ពង់ ជនអ្នកឥតកម្លាំងអង្គចង់ចំណាប់ ជនអ្នកឥតបញ្ញាចង់ថ្លែងស័ព្ទ ជនបីនេះរាប់ទុកស្មើឆ្កួត ។

៙ ជនអ្នកដេកចង់ក្រោកថាយប់យូរ អ្នកដើរគិតគូរថាយោជន៍ឆ្ងាយ ពាលាពុំចេះធម៌ទាំងឡាយ សង្សារវែងឆ្ងាយពីនិព្វាន ។

៙ ជនឯណាតបគុណប្រយោជន៍បាន ជននោះហៅសន្តានញាតិវង្សផៅ ជនឯណាចិញ្ចឹមបាយទឹកនៅ ជននោះលោកហៅថាជាបិតា ។

៙ ក្តីស្និទ្ធស្នាលក្នុងឯជនណាពិត ជននោះហៅថាមិត្រស្និទ្ធស្នេហា ក្តីស្ងប់ទុក្ខមាននៅស្រីឯណា ស្រីនោះហៅថាប្រពន្ធពិត ។

៙ ជនឯណានៅរួមប្រពន្ធកាច ឬទាសាកំណាចចិត្តឫស្យា ឬនៅផ្ទះមានពស់ពិសហានក្លា ជននោះថាជិតស្លាប់កុំសង្ស័យ ។

៙ ជនប្រាសចាកគុណកបគ្នាច្រើន តែចម្រើនដោយក្តីសាមគ្គីអាចផ្ចាញ់បាន នៅពួកពៃរីដោយឫទ្ធីសាមគ្គីដ៏ហៅហាន ។

៙ ខ្សែពួរដែលបុគ្គលវេញដោយស្មៅ នាំយកទៅព័ទ្ធចងដំរីបាន រូបតូចពិតតែចិត្តស្ម័ត្រស្មើប្រាណ គង់ផ្ចាញ់បានរូបធំរលំអីយ ។

៙ ជនធ្វើការប្រញាប់ដោយខ្លួនឯង ឬចាត់ចែងប្រើគេឱ្យធ្វើផងញ៉ាំង ខ្លៅឱ្យក្តៅចិត្តម្ហូរហ្មង ដោយគន្លងការរហ័សក្នុងកាលក្រោយ ។

៙ ជនណាទ្រុស្តមិត្រអស់កាលម្តង ហើយគិតប៉ងសេពគថ្មីទៀតវ៉ា ជននោះជិតមច្ចុរាជគឺមរណា ដូចមេលាកើតគ៌តកូនអស្សតរ ។

៙ ជនឯណាមាត់ក្រអូបដូចបទុម ពាក្យភិរម្យដូចជាតិចន្ទន៍ត្រជាក់ តែក្នុងពោះដូចពិសមុតដូចចក្រជននោះ គួរកុំស្ម័គ្រស្មាគមឡើយ ។

៙ ជនចាញ់ប្រហារ មិត្រសាមាថី[3] ចាញ់កុំប្រាជ្ញ ស្រីកំណាចចាញ់កំណាញ់ រោគាកាញ់ចាញ់បាយតិច ។

៙ ជនពាលដល់ពេលកើតកលិយុគ ទេវតាឱ្យទុក្ខចាំផ្តន្ទា ពួកប្រាជ្ញសប្បុរសកាន់ធម្មាដល់ពេលទុក្ខាទេវតាជួយ ។

៙ ជនពាលសាមាន្យ ឃោរឃៅឃ្លានពានមិនមានមេត្តា ជននោះតែជួបនឹងទុក្ខទោសា ឈឺចាប់ខ្លោចផ្សាមិនដែលចៀសបាន ។

៙ ជនណាពោលភាសាដទៃស្ទិទ្ធ យូរទៅជាប់ចិត្តភ្លេចពាក្យខ្លួន ភ្លេចជាតិសាសនានិងច្បាស់ក្បួន ដូចក្រពើចូនវង្វេងបឹង ។

៙ ជនណាដឹងគួរសម ដឹងអភិរម្យពាក្យពោលពិត មិនខឹងក្រោធក្រៅក្រឹត្យជននោះពិតជាអ្នកប្រាជ្ញ ។

៙ ជនណាខំព្យាយាមរៀនមុន បន្ទាន់វ័យខ្លួនតែសព្វថ្ងៃ ជននោះលោកចាត់ជាប្រុស

[3] សមាថី អ,ថ សាម៉ា (មកពីសំ សមថី សមមត្ត) អត់អាច បានការ ស្ទាត់ ។

ថ្ងៃ វិសេសប្រពៃគួរគ្រាប់តាម ។

៙ ជនណាទ្រាំអត់ ខន្តីសង្កត់ រក្សាមារយាទ មិនខឹងផ្តេសផ្តាស ពួកបណ្ឌិតជាតិ សរសើរជាអាទ៍ ថាអ្នកធូន់ធួរ ។

៙ ជនណាកើតក្នុងត្រកូលខ្សត់ អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ ចង់បានជាស្តេច សោយរាជ្យស្តុកស្តម្ភ ហេតុនេះនឹងនាំឱ្យអន្តរាយ ។

៙ ជនដែលប្រាសចាកគុណ ចាត់ថាស៊ុនអាប់យស ទោះមានត្រកូលខ្ពស់ នឹងមានយសក៏មិនសម ។

៙ ជនដែលធ្វើអំពើល្អបរិសុទ្ធស្អាត មិនប្រមាទធ្វេសប្រហែសការគ្រប់យ៉ាង ជននោះឯងតែងសត្រូវនឹងពួកម្ខាង ដែលកសាងតែកម្មពៀរជាអកុសល ។

៙ ជនដែលចេះសាស្ត្រា ទោះត្រកូលក្រ ទាបក៏ចាត់ទុកថាល្អ ទេវតាក៏បូជាផង ។

៙ ជនខ្លៅទៅជាប្រាជ្ញ ដោយត្រឹមអាចមានប្រាជ្ញា ចេះមូលសូត្រឯណា ក៏ចាត់ថាជាបណ្ឌិត ។

៙ ជនណាមានជាតិព្រមភាសា ភ្លេចជាតិអាត្មាភាសាខ្លួន ដូចមេអំបៅភ្លេចដង្កូវក្បួន គាប់ចួនចូលវង្សតិរច្ឆានសត្វ ។

៙ ជនណាបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ ពួកស្មូមឬអ្នកដទៃៗ ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្តីវិនាស ។ (បរាភវសូត្រ)

៙ ជន្មជីវិតមិតដើរលឿន គ្រឿនទៅមុខមិនថយក្រោយ បណ្តោយទុកចាំយើងទេ ម្តេចក៏យើងនៅតែស្ពឹកមិននឹកគ្នេរ ត្រិះរិះរេបំពេញកិច្ចល្អអ្វីសោះ។

៙ ជនអ្នកប្រព្រឹត្តល្បែងបីប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ ធ្វើទ្រព្យខ្លួនមានឱ្យអន្តរាយ ការល្បែងទាំងឡាយនេះនាំវិនាស ។ (បរាភវសូត្រ)

៙ ជន្លេនសត្វពូជប្រេត ស៊ីមិនឆ្អែតតាមសំណាង ផែនដីធំអស់យ៉ាងស៊ី ខាងៗខ្លាចអស់ដី ។

៙ ជាងទងស៊ីវងកំបែក ជាងដែកស៊ីហែកនឹងដៃ ឬ(នឹងមាត់) ជាងមិនកើតទៅបន្ទោសឯដែក ។

៙ ជាតិក្អែកគោកកុំត្រាប់ក្អែកទឹក រុក្ខាព្រៃព្រឹក្សកុំត្រាប់សត្វ ពួករាស្ត្រកុំត្រាប់ត្រកូលខ័ត្តិយ៍ មហាក្សត្រកុំត្រាប់ប្រជារាស្ត្រ ។

៙ ជាតិកែវមណីល្អឆើត មិនដែលកើតសត្វថ្មភ្នំ គុជមានថ្លៃឧត្តម មិនមានសព្វគជេន្ទ-ជ័យ ។

៙ ជាតិមនុស្សពាលពោលពាក្យមិនពិត កុំយកធ្វើមិត្តខាតរបស់ មនុស្សសុចរិតចិត្តសម្បុរស ស្រឡាញ់ឱ្យស្មោះចិត្តឱ្យស្មើ ។

៙ ជាតិជាកូនប្រុស ធ្វើទាហានស្មោះ និទ្រាលើពូក ឆីបាយក្រហម ជួយជាតិគោកធ្លកលីបាវសាងលោក ស្លាប់ក្រោមទង់ជ័យ ។

៙ ជាតិពាលមិនដឹងគួរ គ្មានគេសួរសាកចង់ជាក់ ឆ្លើយឆ្លងផងរាក់ទាក់ ក្បួនហីនលក្ខណ៍ធ្លាក់លើខ្លួន ។ (លោកនិត)

៙ ជាតិទាពូជទាប ចង់នៅទីរាប មិនចង់ឡើងធ្មើរ ។

៙ ជាតិពាលឃើញពាលចូលគ្នាបាន ពូជសិង្គាលប្រាណមិនឆីគ្នា ពូជចោរយកចោរជា

មិត្រភ្ងា បណ្ឌិតសោភាគប់សប្បុរស ។

៙ ជាតិជាអ្នកជា ស្វាត់ស្មៀមកិរិយា មិនចេញក្អេងក្អាង ឯសន្តានពាល ចេញឫកអាង យ៉ាង[4] ភ្លាត់ស្មៀតស្រទាង ព្រោះព្រុសមិនឈប់ ។

៙ ជាតិមនុស្សទោះថោកទាប មិនចោលភាពពីម៉ែឪ ពាក្យមនុស្សវែងជាងផ្លូវ ស្រូវច្រើនខ្ទបខូចអង្ករ ។

៙ ជាតិខ្លឹមចន្ទន៍ត្រជាក់ក្នុងលោកា ដូចចន្ទ្រាត្រជាក់លើសខ្លឹមចន្ទន៍ សុភាសិតសប្បុរសពោលធម្មក្ខន្ធ ត្រជាក់លើសខ្លឹមចន្ទន៍និងចន្ទ្រា ។

៙ ជាតិអំពៅទោះនៅក្នុងយន្តគាប មិនលះបង់សភាពរសផ្អែមសាយ ជាតិបណ្ឌិតទោះមានទុក្ខក្នុងកាយ មិនជិនណាយលះបង់ព្រះធម៌ថ្លៃ ។

៙ ជាតិអំពៅរសផ្អែមវិសេសខ្លាំង ក្នុងមួយថ្នាំងកង់ៗដោយលំដាប់ តាំងពីចុងដល់គល់រសផ្អែមជាប់ លោកិយជាប់ចាប់ចិត្តចង់ភោក្តា ។

៙ សប្បុរសជាតិជាមិត្រប្រពៃ មានឧបមេយ្យដូចអំពៅផ្អែមពិសារ ជាតិជនទ្រុស្តមិត្រមានឧបមា ដូចអំពៅត្រូវផ្កាវិបរិតរស ។

៙ ជាតិកំជិលសិល្បសាស្រ្តឯណាមាន សិល្បសាស្រ្តខាងទ្រព្យសម្បត្តិអន្តរធាន សម្បត្តិគ្មានញាតិមិត្រឥតមានរវល់ ឥតមិត្រត្រេកមេត្រីក្តីសុខគ្មាន ឥតសុខសាន្តគ្មានបុណ្យគ្មានកុសល ឥតបុណ្យយោគសិវមោក្ខទៅមិនដល់ ចុះក្នុងកលកាមភពជប់ជាប់ហោង ។ (លោកនីតិ)

---

[4] អាងយ៉ាង ពាក្យយួន (ក្អេងក្អាង) ។

ជាតិបណ្ឌិតពិតពេញប្រាជ្ញត្បក្ស គ្មានគេស្ម័គ្រសាកសួរការនានា ដូចស្គរធំឥតគេដំគោះវាយវា បើគេសួរកាលណាដូចភ្លៀងធ្លាក់ ។

ជាតិពាលពិតឥតគេសួរឬសាសង ក៏លាន់កងរំពងពោលឥតអាក់ និយាយច្រើនកើនហួសជ្រួសដំណាក់ ចុះក្នុងក្បួនហិនលក្ខណ៍ធ្លាក់សព្វកាល ។

ជាតិប្រាជ្ញនៅជិតបណ្ឌិតប្រាជ្ញ មួយរំពេចក៏អាចចេះធម៌អាថ៌ ដូចអណ្ដាតដឹងរសនៃអាហារ ជូរចត់ខារហីរប្រៃអាចដឹងបាន ។

ជាន់ជើងចោរ ឬ(ដូចជាន់ជើងចោរ) ។

ជាប់ជ្រួលច្រវាក់ក្រែស្រស់ស្រាយ គួរខ្លាចខ្លួនក្លាយជាក្លៀវក្លា វង្វេងផ្លូវមិនសួរនរណា តនឹងបច្ចាឥតអាវុធ ។

ជិះក្របីចម្លងភក់ ស្រណុកជាជាងហែល ។

ជីងចក់ផ្លាស់ពណ៌តាមកន្លែង ពួកជនពាលតែងផ្លាស់មារយាទ ដោយការចូលជិតបណ្ឌិតជាតិ គង់ប្រែបទបានយល់ខុសត្រូវ ។

ជុះអាចម៍ក្ដាប់ ឬ(កំណាញ់ជុះអាចម៍ក្ដាប់) ។

ជុះអាចម៍កប់ដូចខ្លា ឬឆ្មា (មនុស្សលាក់គំនួច ឬលាក់ពុត) ។

ជួញជិតជាជាងជួញឆ្ងាយ ជួញក្បែររៀងអាចរក្សាប្អូនស្រី ឬ(ចិញ្ចឹមកូនស្រី) ។

ជួញខាតកុំឈប់ខាន បើចង់បានកុំខ្លាចបង់ ខ្លាចបាត់ឱ្យផ្ចិតផ្ចង់ ប្រុងថៃទាំឱ្យមាំមួន។

៚ ដើក្រោយដោយជើងមុខ ។

៚ ជើងបួនគង់មានជ្រុល អ្នកចេះពេញផ្ទុល[5] គង់មានជ្រួស ។

៚ ជើងជា ស្មារឹង ។

៚ ជឿជនសុភាព ឬករាបទាបពាក្យពីរោះ តែងមានសោមគ្រោះ មានកេរ្តិ៍ឈ្មោះក្រអូបសាយ ។

៚ ជោគបោកអ្នកផង ឱ្យនឹកប៉ុនប៉ង ចង់ពឹងតែជោគ មិនខំរកស៊ី ឱ្យកើតមានភោគទាល់ក្រករជោគ ជោគផាយចោលបាត់ ។

៚ ជំពប់ជើងគង់បាក់ ជំពប់មាត់បង់ប្រាក់ ។

៚ ជ្រងោប៉ុនក្បាលអារក្ស ឬ(ធំប៉ុនក្បាលអារក្ស) ។

៚ ជ្រង៉ោប៉ុនគល់ មិនយល់ប៉ុនសក់ ។

៚ ជ្រាយរអៀចដូចបបរឈ្មោល។

៚ ជ្រូកស្លាប់ព្រោះសាច់ ។

៚ ជ្រើមដូចមហាត ។

៚ ជ្រៃលោមស្រទ្បៅ ត្រាវលោមបឹង ។

៚ ជ្រៃមិនលាការរួមរឹត បណ្ឌិតមិនដែលរាចាកធម្មា ខ្លាមិនដែលរាខ្លាចម្រឹគា ជនពាលាមិនដែលរាខ្លាចអាក្រក់ ។

---

[5] ផ្ទុល ឬផ្ទូរ (ដំបូលរទេះ) ក្នុងទីនេះសំដៅ ច្រើនជ្រៅជ្រះពេញបន្ទុក ។

- ជ្រៃស្នាយកន្ទ្រាញ និងកុកស កុំត្រេកអរ ធ្វើត្រាប់តាម ។

- ជ្រៅទឹកជ្រៅដីមិនជាជ្រៅអ្វីគង់មានទោដល់ ឯគំនិតជ្រៅ ជ្រៅឆ្ងាយសែនសល់ ជ្រៅទៅមិនដល់គ្មានទីបំផុត ។

- ជ្រៅតែមាត់ គំនិតរាក់កំភែល ។

- ជ្រៅដូចក្ដិតចាន ។

- ជ្រះថ្លាក្នុងការល្អ គួរត្រេកអរជ្រះថ្លាចុះ ជ្រះថ្លាក្នុងការខុស កុំបណ្ដោះជ្រះថ្លាឡើយ។

- ជ្រះថ្លាតែមាត់ ចិត្តស្នូរជន ។

- ជ្រះថ្លាដូចទឹកភក់ ។

**អ្នកដែលមិនធ្វេសស្មារតីមិនស្លាប់គំនិត**

**នោះបីស្លាប់បាត់ទៅហើយ ក៏ទុកដូចជានៅរស់ៗ**

ស្រង់ចាកសុភាសិតសម្តេចព្រះមហាសុមេធាធិបតី

សង្ឃនាយកគណមហានិកាយ

**(ជោតញ្ញាណោ ជ,ណា)**

# ឈ

៙ ឈាមស្រែកស្បែកហៅ ។

៙ ឈើជើងធាត់ ឈើមាត់ស្គម ។

៙ ឈើធ្ងន់យកដំរីទៅបន់ ដល់ជម្ងឺស្រន់យកពងមាន់ទៅថ្វាយ ។

៙ ឈើកោងវល្លិព័ទ្ធ មនុស្សខ្វាត់ភ្លាត់កុំឱ្យយកខ្លួនបៀត ឬថា(មនុស្សសាត់ព្រាត់ កុំឱ្យជាគ្នា ។

៙ ឈើធំរលំព្យុខ្លាំង ។

៙ ឈើល្អផ្កាក្រអូបសូម្បីមួយដើម អាចស្រង់ក្លិនផ្សើមឈ្ងុយសព្វព្រៃដូចត្រកូលដែលកូនល្អប្រពៃ បានជាសិរីនៃវង្សញាតិផៅ។

៙ ឈើផ្លែចាញ់សន្លឹក ត្រីច្រើនទឹកល្អក់ពុំជា ឬ(ឈើផ្លែច្រើនចាញ់សន្លឹក) ។

៙ ឈើងាប់ពីចុង ដំរីស្លាប់ពីពុង មនុស្សស្លាប់ពីជើង ។

៙ ឈើពុកកុំដាក់គូថលើ ឬ(កុំអង្គុយលើ) ។

៙ ឈ្មួញទឹកពិតពឹងទូក រឺឈ្មួញគោកពឹងរទេះ សំណាងពឹងចំណេះ ប្រាជ្ញប្រាយចេះពឹងគម្ពីរ ។

៙ ឈ្នះក៏ដោយចាញ់ក៏ដោយឱ្យតែត្រូវ ទៅតាមផ្លូវដែលសុចរិតឥតចៀសវាង តាមគន្លងយុត្តិធម៌ល្អឥតល្បៀង កុំបញ្ជៀងកុំបញ្ឆិតគិតលោភយស ។

៙ ឈ្លោះនឹងពាលឃើញពិបាកបន្តិចហើយ កុំស្មានឡើយថាពាលស្តាប់សព្វវាចា ទុកថាវែកញែកខុសត្រូវទៅផ្លូវណា ក៏ពាលថាគេមិនស្តាប់ច្បាប់អ្វីទេ ។

៙ ឈ្នះអ្នកស័ក្តិខ្ពស់ដោយលុតក្រាប ឈ្នះអ្នកទន់ទាបដោយឱ្យទាន បំបែកសាមគ្គី ឈ្នះអ្នកក្លាហាន ឈ្នះអ្នកស្មើប្រាណដោយតស៊ូ ។

៙ ឈ្នះអ្នកខ្ពស់ដោយបន្ទន់ប្រាណ ឈ្នះអ្នកក្លាហានដោយទំលាយ ឈ្នះអ្នកខ្សោយ ដោយឱ្យសម្លបាយ ឈ្នះអ្នកស្មើកាយដោយព្យាយាម ។

៙ ឈ្នះប្រទេសដទៃតែងល្បី ឈ្នះល្បែងអប្រិយវិសេសឯក ឈ្នះខ្លួនៗឯងឧត្តមប្លែក ហៅឈ្នះចម្លែកលែងចាញ់វិញ ។

៙ ឈ្នះអ្នកក្រោធដោយក្រឹត្យមិនក្រោធតប ឈ្នះអសប្បុរសប្រកបដោយសប្បុរស ឈ្នះកំណាញ់ដោយឱ្យទ្រព្យរបស់ ឈ្នះបុរសឡេះឡោះដោយពាក្យសត្យ ។

៙ ឈ្មោះខ្លួនបែបណា ខំធ្វើការឱ្យដូចឈ្មោះ ។

៙ ឈ្មោះល្អក្រក្នុងលោក សិរីរត់រកអ្នកមានកេរ្តិ៍ឈ្មោះ ។

៙ ឈ្លោះនឹងស្រីនាំឱ្យហិន ក្តីនិងចិននាំឱ្យថោក ។

៙ ឈ្លោះគ្នាក្នុងគ្រួសារ ដូចស្រាតកាយាបង្ហាញញាតិ ឈ្លោះគ្នាក្នុងសង្គមជាតិ ដូចលាតកំណាប់បង្ហាញចោរ ។

៙ ឈ្លោះនឹងបរទេស កុំធ្វេសគំនិត ។

**អ្នកបួសធូន់ក្នុងលោកតយសមិនបទរ**

**គ្រហស្ថគ្មានរបរ មិនថ្លៃថ្នូរ ២**

ស្រង់ចាកសុភាសិត សម្តេចព្រះធម្មលិខិត

**ឧត្តមប្រឹក្សា ទជិប្បញ្ញោ (ល្វី ឯម)**

# ញ

៙ ញញឹមស្មើ សើចស្មើរ សម្តីពីរោះ ការណ៍ទាំងនេះចូរប្រយ័ត្ន ។

៙ ញញួរប្រើកើតព្រោះមានដង អ្នកផងបានខ្ពស់ព្រោះអ្នកធំ ដូចពេជ្រមានមាសប្រាក់ស្រោបរុំ ទើបបានឧត្តមស្គាល់ថាពេជ្រ ។

៙ ញាក់ដូចគោក្របី នាំឱ្យខូចក្តីរាប់អាន ។

៙ ញាតិផ្ទាល់ បើមិនស្គាល់គឺអ្នកដទៃ ។

៙ ញាតិនិងមិត្រ បើញាតិមិនគិត មិត្រប្រសើរជាង ។

៙ ញាប់តែពាក្យ ទ្រគាកស្លាប់ឈឹង ឬ(ទ្រគាកងាប់ស្លូក) ។

៙ ញាប់ដូចក្តាមស៊ីអាចម៍។

៙ ញឹកណាស់ដំរីចេញរួច ជាលភ្អែកក្រួចដាក់ទឹកមិនលេច ។

៙ ញៀននឹងល្បែងតែងហិនហោច ។

៙ ញៀននឹងល្បែងតែងបង់យស ។

៙ ញៀននឹងស្រីចំណីទុក្ខ ។

៙ ញៀននឹងបៀ គឃៀរស្លៀកពាង ។

៙ ញៀននឹងបៀប៉ោ អស់ខោអស់អាវ ។ ៙ ញៀននឹងស្រា ដេកផ្ងារក្នុងផ្លូវ ។

៙ ញៀននឹងលោភ ថោទាបដូចសត្វ ។

# ដ

៙ ដង្កូវចេញពីសាច់ ច្រែះចេញពីដែក ។

៙ ដប់នាក់អន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ ឬ(គ្នាច្រើនអន្សមខ្លោច) ។

៙ ដល់កំពង់លង់ទឹក ។

៙ ដល់ក្របីបាត់ទើបធ្វើរបង ដល់ពេលប្រឡងទើបស្វាធ្យាយ ដល់ពេលចេញដើរវេចសំពាយ បីនេះអន្តរាយវិនាសបង់ ។

៙ ដល់ត្រើយ សើយគូថ ។

៙ ដាក់ទុកកូនចៅ ឱ្យមើលផៅសន្តាន ឬ(ទុកដាក់កូនចៅ) ។

៙ ដាក់ទ្រូឱ្យស្រាស់បន្លា អារសាច់ជូនខ្លា ទើបនៅស្រុកបាន (ន័យមួយ) ទៀតថា៖ នៅស្រុកឱ្យស្រាស់បន្លា អារសាច់ជូនខ្លាទើបនៅស្រុកបាន (វចនានុក្រម) ឬថា (នៅផ្ទះឱ្យស្រាស់បន្លាអារសាច់ជូនខ្លាទើបនៅស្រុកបាន) ។

៙ ដាវមុតៗមែននៅក្នុងស្រោម វិជ្ជាចេះព្រមមិនត្រូវការ ជាតិស្រីឥតប្តីនឹងព្យាបាល គជសារឥតហ្មនឹងប្រដៅ ។

៙ ដាវមុតៗមែនក្នុងស្រោម វិជ្ជាចេះព្រមនៅក្នុងក្បួន ប្រពន្ធគាប់ចិត្តនៅឆ្ងាយខ្លួន ដល់ចួនត្រូវការរអារចិត្ត ។

៙ ដឹកគោញី បន្សីគោឈ្មោល ។

៙ ដឹងបានដឹងបង់ ដឹងបាត់ដឹងគង់ ដឹងគួរដឹងគាប់ ដឹងខ្ពស់ដឹងទាប ដឹងដប់ផ្ទប់ឈើ

មួយ ។

៙ ដឹងដៃកកាំបិតព្រា ទុកឱ្យជាកុំឱ្យបាត់ ។

៙ ដឹងបាំងតាមសាប់ ច្បាប់កាត់តាមពាក្យ ។

៙ ដឹងហាបឱ្យដឹងដុល ភ្នែកឱ្យយល់ទៀងត្រាជូ ។

៙ ដឹងគ្នានៅគ្រាក្រ សម្បុរល្អនៅខែកត្តិក ឬ(ដឹងគ្នាទាន់គ្រាក្រ សម្បុរល្អទាន់ខែកត្តិក)។

៙ ដឹងឆ្លើយព្រោះដង កូនឆ្គងព្រោះមេបា ឬ(កូនឆ្គងត្បិតឪម៉ែ) ។

៙ ដឹងឆ្លើយត្បិតដង កូនសោតរែងឆ្គង ដ្បិតតែឪពុក ទ្រព្យគង់ដ្បិតតែស្រី ចេះរៀបដាក់ទុក ប្រះដេកឆាប់លក់ដ្បិតឥតបើគិត ។

៙ ដឹងរង្គោះ បោះបណ្ដោយ ។

៙ ដឹងថាខ្លួនល្ងង់ គង់បានជាប្រាជ្ញ ។

៙ ដុតឱ្យខ្លោច រោចឱ្យឆៅ ។

៙ ដួងមួយធ្លាយ គង់មានតក់មាននាឡិ ដូចកន្លង់នឹងផ្កា ។

៙ ដូចក្រពើវង្វេងបឹង ។

៙ ដូចបាចអង្កាមប្រាសខ្យល់ ឬ(ដូចបាចខ្សាច់ប្រាសខ្យល់) ។

៙ ដូចខ្លាបានទួល ។ ៙ ដូចខ្វាក់បានដៃ ។

៚ ដូចខ្មៀនកន្ទុយឆ្កែ ទោះនៅប្រែពត់ពុំត្រង់ ។

៚ ដូចចិញ្ចឹមកូនខ្លា ។ ៚ ដូចចាប់ក្ដាមដាក់ចង្អេរ ។

៚ ដូចចាប់ស្វាមកបំបួស ។ ៚ ដូចយកអន្ទង់ ទៅចំហុយភក់ ។

៚ ដូច (ជាគេ) អូសឫស្សីច្រាសចុង ។

៚ ដូច (ជាគេ) អូសឆ្កែឱ្យចុះទឹក ។

៚ ដូច (ជាគេ) ប្រដៅក្រពើឱ្យចុះទឹក ។

៚ ដូច (ជា) ទឹកកន្លះក្អម ។ ៚ ដូចញញួរនិងទ្រនាប់ ។

៚ ដូចកាំបិតនិងជ្រុញ ឬ(ដូចជ្រុញនិងកាំបិត) ។

៚ ដូចសង្សឹមផ្កាយលើមេឃ ។ ៚ ដូចអាចម៍ចូលឈ្នាង ។

៚ ដូចអាចម៍ត្រូវថ្ងៃ ឬ(ក្រអឺតដូចអាចម៍ត្រូវថ្ងៃ) ។

៚ ដូចទន្សាយបានទួល ។ ៚ ដូចឆ្មាចូលត្រឡោក ។

៚ ដូចត្រឡាចនៅក្នុងបន្លា ។ ៚ ដូចប្រដៅសេកចាស់ ។

៚ ដូចក្របីនឹងចេក ។ ៚ ដូចខ្លាចឃ្មុំនិងដើមពង្រ ។

៚ ដូចសំពៅនូវសំប៉ាន ឬ (ដូចសំពៅពឹងសំប៉ាន) ។

៚ ដូចសត្វប្រលាំងកាស ឬ (ជាប់គ្នាដូចសត្វប្រណាំងកាស) ។

៚ ដូចស្រមោលនិងស្គរ ។ ៚ ដូចដេកផ្ងារស្តោះដាក់ទ្រូងឯង ។

៙ ដួលមិនបាច់ច្រាន បានមិនបាច់ខំ ។ ៙ ដួលត្នោលដូចគ្មានអីទប់ ។

៙ ដួលដូចគោចាស់ ។ ៙ ដួលតិតដួលតូង ។

៙ ដួលសង់ជ្រោង ។ ៙ ដើរឱ្យមានបី ស្រដីឱ្យមានបួន ។

៙ ដើរជិតផ្ទះគេពេលគេដេក កុំក្អេងក្អាងពេលគេផ្អើលភ្ញាក់ និយាយឱ្យល្មមគេស្តាប់ជាក់ កុំខ្សឹមលបលាក់គេសង្ស័យ ។

៙ ដើរលេងផ្ទះគេទោះជិតឆ្ងាយ គេហៅស៊ីបាយឱ្យខំអត់ អង្ករគេច្រកដឹងកំណត់ ឱ្យល្មមតែមាត់កូនចៅគេ ។

៙ ដើរឱ្យរំពៃ អង្គុយឱ្យរំពឹង ។

៙ ដើរដោយផ្លូវគន្លង តម្រាយអ្នកចាស់បុរាណ ។

៙ ដើមឈើអាស្រ័យដីជីល្អជា តែងនឹងផ្កាផ្លែចម្រើនឡើង អ្នកដែលអាស្រ័យសប្បុរសថ្កុំថ្កើង ចម្រើនបុណ្យឡើងទៅធំបាន ។

៙ ដើមនៅឯស្រែ ផ្លែនៅឯផ្សារ ។ ៙ ដេកមិនលក់ បក់មិនល្ហើយ ។

៙ ដេកមិនលក់កុំខំដេក ឬ (ត្រូវខំដេក) ។

៙ ដេកលក់បាត់ខ្លាច ។ ៙ ដេកយប់កុំនិយាយនឹងស្រី ។

៙ ដេកយប់កុំដំអក់ ឱ្យលង់លក់ក្រៅសុចរិត ខ្ញុំណាមានគំនិត គួរឱ្យគិតប្រណីវា ។

៙ ដេកយប់កុំដេកយូរ ហើយទទូរដូចគេងាប់ សំពត់ស្លៀកឱ្យជាប់ កុំឱ្យអាក្រាតក្រៅខ្លួន ។

៙ ដេកយប់កុំដេកយូរ ខ្លាចក្ដីទុជ៌ន[6] ដល់ប្រាណ ។

៙ ដេកដល់ថ្ងៃរះហៅឥតគំនាប់ ចង្រៃអភ័ព្វជិតដល់អាត្មា ។

៙ ដេកដល់ថ្ងៃនាំចង្រៃខ្លួន ។ ៙ ដេកទាល់ថ្ងៃយកកំជិលដៃលគេ ។

៙ ដេកកុំដំងើច គេក្រកុំសើច គេភ័យកុំព្យូរហ៍ ទោះខឹងប៉ុន្មាន ធ្វើជាឱ្យគួរ តឹងគិតឱ្យធូរ យូរគិតឱ្យឆាប់ ។

៙ ដេកលើភ្លៅ ទៅបៅដោះអ្នកដទៃ ។

៙ ដេកយប់ឱ្យរាំងទ្វារ ទ្រព្យសម្រាលរៀបប្រយ័ត្ន ចងទូកកុំឱ្យរសាត់ ផ្ទះបាក់បែកឆាប់ទ្រល់ទ្រ ។

៙ ដេកផ្ងារស្ដោះដាក់លើទ្រូងឯង ។

៙ ដេកផ្សំដួល រមួលផ្សំគ្រេច ។ ៙ ដេញទាន់កុំជាន់កែង ។

៙ ដៃភ្លើងជើងមាន់ ។

៙ ដៃស្ដាំជាខ្ញុំកាយ ព្រោះខ្វល់ខ្វាយអេះខ្វារខ្វាំ កូនដៃនៃដៃស្ដាំ ខ្ញុំត្រចៀក ច្រមុះភ្នែក ។ ដៃឆ្វេងជាខ្ញុំជើង តាមទំនើងជើងរហែក ប្រើលាងសព្វចង្អែក វេណីចែកចាំទុកហោង។

៙ ក្រោកឡើងពីព្រឹកប្រកបការងារ ។ ៙ ដោះកន្ទេក អារីសកូន ។

៙ ដោះស្រាយប្រស្នា ថ្កើងឯអ្នកប្រាជ្ញ ។

៙ ដំណេកដេកជាខ្នាត ឱ្យសំអាតសំអាងជា ទើបទេព្ដាររក្សាចម្រើនសុខសិរីសួស្ដី។

---

[6] អានថា ទូរជន់ ។

៚ ដំណាំអ្វីៗ សាបព្រោះលើដី គេតែងបានផល ដំណាំដែលគេដាំបុណ្យ បាបសល់រ៉ល់ ធ្ងន់ស្រាលដូចកល ដំណាំនោះដែរ ។

៚ ដំរីសារស្លាប់ ទៅយកឯចង្អេរបាំង ។

៚ ដំរីស្លាប់យកឯគ្រប់បាយ គ្រប់ដំរីម្ដេចជិតបាន ។

៚ ដំរីផុង ព្រយុងដើមលើ ។

៚ ដំរីជល់គ្នាខ្ទេចស្មៅ ឬ(ខ្ទេចដើមឈើ) ។

៚ ដំរីខ្វាក់ ទ្រមាក់ឆ្កួត ។

៚ ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច ឬ(ខុស) ។

៚ ដំរីជុះកុំជុះតាមដំរី ។

៚ ដំបៅមិនឈឺយកឈើទៅចាក់ ឬ (យកបន្លាចាក់) ។

៚ ដាំចង្ក្រានមិនប្រមាណឆ្នាំង ។

៚ ដាំដូងឱ្យខំថៃ ចងស៊ីផ្លែឱ្យដុតគល់ បើជូនសំណាងដល់ រវល់តែឆ្ងាញ់ពិសា។

## ឋ

៙ ឋានសួគ៌មាននៅក្នុងលោកិយ គឺជនប្រុសស្រីក្នុងគ្រួសារ
ដែលស្រុះស្រួលគ្នារាល់វេលា ទោះខ្ទមជរាពិតជាប្រាសាទ ។
បរិភោគតែអំបិលនិងបាយ ក៏មានរូបកាយមុខស្រស់ស្អាត
ប្រៀបដូចទេវតាពណ៌សុទ្ធសាត នៅក្នុងប្រាសាទត្រៃត្រឹង្សា ។
៙ ឋានសួគ៌ប្រកបដោយសុខា គួរយើងប្រាថ្នាទៅគ្រប់គ្នា
ឋាននិព្វានសុខលើសសួគ៌នានា ហៅមហាសុខាប្រសើរក្រៃ ។
៙ ឋានបុគ្គលមានទ្រព្យ លោកិយគេរាប់មុខមិនខ្វះ
សិរីប្រសិទ្ធឥតកន្លះ ពាក្យត្អិះតិះដៀលមិនដែលដល់ ។

៙ ឋិតថេរឥតអំពើ បើមិនធ្វើអំពើល្អ ។

៙ ឋិតថេរតែខ្លួន ចិត្តផ្នួនតែទុក្ខ ។

៙ ឋិតនៅក្នុងសេចក្តីប្រមាទ ឈ្មោះថាស្លាប់ ។

៙ ឋិតនៅឯកឯង ប្រសើរជាងនៅរួមដោយជនពាល ។

៙ ឋិតក្នុងរដ្ឋគ្មានយុត្តិធម៌ គួរខ្លាចជាងនៅក្នុងព្រៃខ្លា ។

៙ ឋិតនៅក្នុងរដ្ឋ ដែលមានប្រមុខរដ្ឋល្អ ដូចនៅក្នុងឋានសួគ៌ ។

៚ ឋិតនៅក្នុងប្រទេសអព្យាក្រិត្យ ដូចជាស្ថិតនៅគ្រប់ប្រទេសទាំងអស់ ។

៚ ឋិតនៅក្នុងប្រទេសរណបគេពិបាកចិត្ត ដូចជានៅក្នុងដប ។

៚ ឋិតនៅក្នុងគុក ស្រណុកជាងនៅក្នុងអំណាចស្រីប្រច័ណ្ឌ ។

★ ★ ★

# ឱ

| | |
|---|---|
| ៙ ឱមជនគឺអ្នកថោក | អាចប្រែក្លាយភាពជាខ្ពង់ខ្ពស់ |
| ដោយការសេពគប់នឹងសប្បុរស | ដង្កូវបានខ្ពស់ព្រោះបុប្ផា។ |
| ឱមជនដូចជាសត្វដង្កូវ | ទៅឋិតនៅលើព្រះកេសា |
| នៃព្រះរាជាដ៏ថ្លៃថ្លា | ដោយបុប្ផាផ្គងគន្ធា ។ |
| ៙ ឱមជនបាសេពគប់បណ្ឌិត | ដង្កូវគប់មិត្រនឹងបុប្ផា |
| អាចឃិតឃោងគ្នាបានថ្លៃថ្លា | ថ្កើងក្នុងលោកាទាំងពីរពិត។ |
| ៙ ឱកិនីគឺបីសាចញី | ព្រះមុនីប្រដូចនឹងមនុស្សស្រី |
| ដែលមិនគោរពដល់ស្វាមី | ប្រច័ណ្ឌតែប្តីជានិច្ចពិត។ |
| ៙ ស្រីពួកនេះគួរឱ្យខ្លាចក្រៃ | ម៉្ងៃៗរិះគន់ប្រច័ណ្ឌស្អិត |
| ព្រោះនាំចង្រៃមួយជីវិត | នាំឱ្យវិបរិតចិត្តមួរហ្មង ។ |
| ៙ ឱំសៈគឺសព្វល្បោម | រោមចោមចោះសត្វនានា |
| ដូចពួកជនពាលា | ដែលកម្មពៀរចោមឱ្យផល។ |
| ៙ ឱំសៈគឺសព្វល្បោម | នាំគ្នាចោមសត្វនានា |
| ដូចកូនល្ងង់លីលា | នាំគ្នាចាយទ្រព្យម៉ែឪ ។ |

៤៥- ខ្ញុំសៈគឺសព្វល្បោម ខំចោមបោះសត្វនានា
ដូចបុគ្គលលិកពាលា នាំគ្នាលួចប្រាក់ជាតិចាយ ។

★ ★ ★

# ៣៩

៙ ណាមរាប្រែជាសត្វហង្ស មានរូបរាងខ្ពង់ប្រសើរឯក
ដូចបណ្ឌិតដែលចេះដឹងអនេក ឯពួកសត្វក្អែកដូចមនុស្សល្ងង់។
ធម្មតាក្អែកចូលក្នុងហ្វូងហង្ស ធ្វើម្ដេចបានខ្ពង់ស័ក្ដិសមទ្រង់
ពួកជនប្រុសស្រីដែលខ្លៅល្ងង់ ទោះមានរូបខ្ពង់ក៏ទាបថោក ។
អ្នកមានរូបល្អដូចទេវតា តែខ្វះបញ្ញាការប្រាជ្ញព្រោក
ល្អដូចផ្កាចារគ្មានគេរក ល្អដែរតែថោកគ្មានតម្លៃ ។
ទោះបីបានធ្វើតំណាងរាស្ត្រ គ្មានការវៃឈ្លាសទាន់សម័យ
គ្មានពាក្យនិយាយប៉ុនពងចៃ ចាំតែលើកដៃបាទតាមគេ ។
៙ ណាលិនប្រែថាអ្នកកាន់ខែល ចេះកាប់ប្រហែលចេះការពារ
ដូចអ្នកចេះដឹងមិនខ្លាចរា ឧបស័គ្គនានាការពារបាន ។
ខែលនិងអាវុធគឺវិជ្ជា នៃប្រុសនិងនារីគ្រប់ប្រាណ
ដែលបានរៀនសូត្រយ៉ាងចំណាន ក្នុងភូមិភពឋាននាលោកិយ ។
៙ ណាលិនប្រែថាអ្នកកាន់ខែល គឺពលរដ្ឋដែលជាទាហាន
ត្រូវតែកាប់ចាក់ពួកឈ្លានពាន កុំឱ្យកើតមានក្នុងផែនដី ។

ទោះពួកបរទេសយកលាភទាក់ កុំឱ្យភាន់ភ្ញាក់ស្មារតី

តស៊ូទាល់ស្លាប់ក្រោមទង់ជ័យ ជាតិខ្លួនប្រពៃថ្កើងរុងរឿង ។

★ ★ ★

# ណ

៙ ណាត់ពេលប្រជុំគ្រប់កិច្ចការ ត្រូវតែឧស្សាហ៍ទៅឱ្យទាន់
កុំធ្វេសប្រហែសមិនរួសរាន់ កុំអន់ជាងមាន់ជាតិតិរិច្ឆាន ។

៙ ណាត់ជួបជុំគ្នាពេលម៉ោងណា ត្រូវប្រុងកាយាកុំខកខាន
ត្រូវគិតអៀនខ្មាសមាន់តិរិច្ឆាន រងាវបានទៀងគ្រប់ពេល ។

៙ ណាយកាយ ឆ្ងាយចិត្ត ។

៙ ណាស់ខាងណា ចិត្តប៉ះទៅខាងណោះ ។

៙ ណាស់ខាងទុក្ខសុខឃ្លាតឆ្ងាយ ណាស់ខាងអបាយឆ្ងាយសួគ៌
ណាស់ខាងខ្ជិលរៀនគ្មានវិជ្ជា ណាស់ខាងឈ្លោះគ្នាបានហិនហោច ។

៙ ណាស់ខាងស្រឡាញ់ជាតិ មានយាទខ្ពស់ ។

៙ ណែនាំខុសផ្លូវតែងទៅអបាយ ឬ (នាំទៅអបាយ) ។

៙ ណែនាំក្រពើឱ្យហែលទឹក ណែនាំពាលថ្មឹកឱ្យលួចឆក់
ណែនាំសត្វខ្លាឱ្យលោតហក់ នេះក្បួនអាក្រក់គេថាឆោត។

៙ ណែនាំជនពាលឱ្យធ្វើល្អ ពាលមិនត្រេកអរប៉ុនចុងសក់
ពាលរិតបានចិត្តធ្វើអាក្រក់ ភូតភរកុហកថែមខ្លាំងក្លា។

នរប្រុសស្រីចូរចងចាំ បុរាណបានផ្តាំផ្តាច់ទុកថា

ប្រដៅជនពាលដោយអាជ្ញា ឃុំឃាំងប្រហារទើបវាខ្លាច ។

៚ ណែនាំកូន[7] ត្រូវប្រដៅខ្លួនទុកជាគំរូ។

★ ★ ★

[7] កូនបង្កើត កូនសិស្ស ប្រជាពលរដ្ឋ បុគ្គលិក និងកម្មករ ។

# ត

- តកម្លាំងឱ្យសេពអាហារ ។
- តដងវែកឱ្យល្មមនឹងស្មា ។
- តវាសនាឱ្យខំសន្សំបុណ្យ ។
- តសំពៅមិនត្រូវស្តាយដែក ឬ(តសំពៅទៅស្តាយអីដែក) ។
- តក់ៗដូចទឹកត្នោត ព្រឹកឡើងសោតពេញបំពង់ ឬ(ដល់ព្រឹកឡើងសោតពេញបំពង់) បានមកទុកឱ្យគង់ កុំឱ្យបង់បាត់ឡើយណា។
- តណ្ហាទាសោពុទ្ធោថា សត្វជាទានសាចង់នេះជាប់ ។
- ចង់ខ្លាំងតែងផុងខ្លួនផ្ទួនផ្ទាប់ តែឆ្លោយឱ្យធ្លាប់ទុក្ខជាប់ង៉ក់ ។
- តណ្ហាជាមេខ្វះ ចេះតែកន្លះ មិនដែលគ្រប់គ្រាន់ អ្នកមានសន្តោស ចិត្តលុះជាក់ស្បាន់ ក្រដេញមិនទាន់ ជាន់កែងមិនបាន ។
- តមមេស៊ីពង ស៊ីរងសម្បុក ។
- តមមាន់ញីស៊ីមាន់ឈ្មោល តមកំបោរស៊ីអាចម៍ក្រពើ ។
- តម្លក់វាទៅ ទើបញ្ចៅវាមក ឬ(ទើបញ្ចៅវាជ្រុះ) ។
- តរុណានៅជិតតរុណី ក្របីនៅជិតរុក្ខាចេក ហត្ថីអំពៅចូលបោចសែក ស្ករប្លែក ស្រមោចតែងរត់រក ។ ខ្លះថា (អំពៅហត្ថី...) ។

៙ តរុណីស្អាតរូបសប្បាយភ្នែក កុមារីប្លែកចិត្តសល្អ សប្បាយចិត្តភ្លឺបវរក្នុងលោកកម្រ បានជួប ។

៙ តាបសរូបស្គមនោះឧត្តម ចតុប្បាទធាត់ធំនោះសោភណា
ប្រុសមានវិជ្ជានោះសោភា ស្រីមានភស្តានោះសោភី ។

៙តាមប្រាជ្ញអាចឃ្លាតជាតិទុក្ខ ឯសុខអាមិសកុំផ្តេកផ្តិត
ផ្លូវព្រះនិព្វានគ្មានវិបរិត តែស្និទ្ធអាមិសអាមះភ័យ ។

៙ តឹងព្តឹះដូចអូសឫស្សីច្រាសចុង ។

៙ តឹងគិតឱ្យធូរ យូរគិតឱ្យឆាប់ ។

៙ តឹងង៉ាង ធូរស្ប៉ត ។

៙ តូចមានពិសពិត ធំឥតគំនិត ទាំងឥតខ្លឹមសារ ដូចថ្នាំវិសេស ពូកែបានការ ទោះតិចយ៉ាងណា សះជាជម្ងឺ ។

៙ តូចពិតដូចពេជ្រពណ្ណរាយ ។

៙ តែខំប្រមាថវាបាត់បុណ្យ ចិត្តជូស្នូរជនចាត់សទ្ធា
មានះបាត់មិត្រឥតគ្នីគ្នា វិជ្ជានឹងចេះមកពីចិត្ត។

៙ តែខំច្រើនកើនចំណេះ តែចេះការច្រើនជាបច្ច័យ
តែខំរៀនសូត្ររាល់ខែថ្ងៃ ដូចថ្មែត្បូងពេជ្រលេចពន្លឺ ។

៙ តែថាឯស្រានិងការល្បែង    គួរលះគួរលែងបានមិនអ្វី
ឯត្រង់ចំណង់ចង់នឹងស្រី    លោកិយយើងក្រលះបានណាស់។

៙ តែឃ្លាវាឆ្ងាញ់ តែស្រឡាញ់វាល្អ ឬ(ឃ្លានវាឆ្ងាញ់ ស្រឡាញ់វាល្អ) ។

៙ តែចេះពេកតែឆ្លាតពេកគេស្អប់    គេត្រឡប់ជាថាឯងសម្ដែងឫទ្ធិ
គេមិនតាំងចិត្តបំណងចងជាមិត្ត    គេមិនគិតថាឯងល្អបរិសុទ្ធទេ ។

៙ តែនិយាយឆ្ងាយពីមាត់ទៅហើយ    កុំស្មានឡើយថាមិនចូលត្រចៀកគេ
តែមានរូបកុំគិតពួនមិនបាច់ទេ    មុខតែគេមើលឃើញស្ដែងពុំលែងឡើយ។

៙ តែខ្សោយវិជ្ជាវាខ្សត់ធន    តែបុណ្យស័ក្តិគ្មានខ្មាសអៀនជាប់
អាស្រ័យក្នុងលោកក៏មិនគាប់    ព្រោះមិនប្រសប់ផ្លូវសេពគប់ ។

៙ តែងគោលដូចទូកឥតបង្គោល ឬ(ដូចទូកកណ្ដាលទន្លេ) ។

៙ តាំងខ្លួនឱ្យឃ្លាតពីខ្លៅចេញ    វែងណាស់លលេញហួសប្រមាណ
លក់ដូរមើលដើមឱ្យដឹងដាន    គិតអានសឹមធ្វើតាមប្រាថ្នា ។

៙ តាំងឱ្យមើលៗឱ្យសព្វ    បើនឹងស្អប់កុំអាលបាញ់
ក្ដីឈ្នះគេចុះចាញ់    កុំខ្ទាញ់កុំតាមផ្ដន្ទាទៀត ។

៙ ត្នោតបាទប្រមាថត្នោតលៃ ប្រមាត់ដីចង់ឡើងទ្រើង ។

៙ ត្នាតផ្តុំក្តុយ ។

៙ ត្រកូលសជាតិ មាយាទសពូជ ឬ (សខ្លួន) ។

៙ ត្រកូលខ្ពង់ខ្ពស់ យសហេតុផលស្មោះ ហិរិឱតប្បា ប្រព្រឹត្តសោភ័ណ ទើបបានថ្លៃថ្លា គេលើកទុកជា អភិជនពិត ។

៙ ត្រង់មិនឈ្នះទាល់ ។

៙ ត្រង់ពុតមនុស្សពាលពេទ្យនឹងពត់ ដោយមន្តឱសថពុំបានឡើយ ។

៙ ត្រឡប់ត្រឡិន បាយបិណ្ឌជាបាយបាត្រ ។

៙ ត្រឡាចវារទៅ ល្ពៅវារមក ។

៙ ត្រីមួយត្រកតែស្អុយមួយ ស្អុយទាំងអស់ ។

៙ ត្រីរស់ក៏រួច ទន្សាយក៏រួច ។

៙ ត្រីបានត្រីតូច ត្រីរួចត្រីធំ ។

៙ ត្រីព្រួលកុំចោលស្រកា ត្រីប្រាកុំចោលស្រកី ត្រីក្អីកុំចោលជើង ។

៙ ត្រីងៀតឆ្លៀតពង ។

៙ ត្រីកប់ត្រឡប់ជាត្រីអាំង សំឡក្នុងឆ្នាំងរកវែកដួសគ្មាន ។

៙ ត្រីឆ្ដោរស៊ីកូនឯង ។

៙ ត្រឹកៗដល់ផ្ទះ តូងតាងដេកផ្លូវ ។

៙ ត្រុកៗអ្នកស្រុលមើលងាយ រលាស់គូថខ្វាយមានឱតមានភាន់ ។

៙ ត្រូវសន្សំទ្រព្យ តិចៗត្រឡប់ ចម្រើនធាត់ធំ ។

៙ តក់ៗគង់ពេញ បំពង់រងផ្សំ សម្បត្តិស្តុកស្តម្ភ ធ្វើសេដ្ឋីបាន ។

៙ ត្រូវកំចាត់សត្រូវដោយសត្រូវ ដោយឱ្យទ្រព្យត្រូវដល់ចិត្តវាដូច បន្លាដែលមុតក្នុងបាទា យកបន្លាដូចគ្នាជួសទើបបាន ។

៙ ត្រូវយកដើមត្រែងជាច្បាប់ប្រាណ វាយោរបកច្រានមិនរលំ រុក្ខជាតិដូចយ៉ាងធ្នឹមសុក្រំ ខ្យល់ធំបក់ចំគង់រលើង ។

៙ ត្រូវដឹងប្រមាណ អាហារដែលបាន បរិភោគរាល់ថ្ងៃ ទោះមានតិចច្រើនចេះគិតសំចៃ គ្រប់គ្រាន់សព្វថ្ងៃ ទើបបានសុខសាន្ត ។

៙ ត្រូវតាំងចិត្តខ្ជាប់នៅជានិច្ច ម្តងៗបន្តិចដោយខ្មីឃ្មាត

កុំដាច់ស្រយាលរយាលឃ្លាត រវាតចោលកិច្ចការសិក្សា ។

៙ ត្រូវកោតក្តីបី កោតមួយពាក្យស្រី ស្រដីមារយា កោតមួយពាក្យពិស អសុរោះវាចា កោតមួយពាក្យពាល ពាលោទុជន ។

៙ ត្រូវនឹកប្របូលការគ្រប់មុខ មកពិនិត្យទុកមុននឹងធ្វើ

ការណាយល់ជាគាប់ប្រសើរ ត្រូវប្រើព្យាយាមនិងមានះ ។

៙ ត្រូវថ្នមកូនអាយុប្រាំវស្សា ត្រូវាយជេរថាទៅត្រឹមដប់ឆ្នាំ

ដល់អាយុដប់ប្រាំមួយចូរចាំ ពាក្យអ្នកប្រាជ្ញផ្តាំថាកូនជាមិត្រ ។

៙ ត្រូវត្រាប់កុកសាប់ កុំត្រាប់កុកស ។

៙ ត្រូវទ្រាំអត់ខ្យត់តោកយ៉ាកពិបាកប្រាណ ពីដើមដានទើបក្សេមក្សាន្តទៅគ្រាក្រោយ
កុំចង់បានក្នុងគ្រាអំណាត់ដែលខ្យត់ខ្សោយ តែបណ្តោយតាមចំណង់នឹងបង់លាភ ។

៙ ត្រួសត្រាយទុក ស្រណុកជាងកែកុន ។

៙ ត្រួសៗគ្រប់មុខគ្មានបានការ ដល់ពេលចរចារដូចឆ្មាចូលត្រឡោក ។

៙ ត្រើយនាយនិងត្រើយអាយ    ពិតជាឆ្ងាយដាច់អាល័យ
ឯមេឃហើយនិងដី    ក៏ឆ្ងាយក្រៃតតជួបគ្នា ។
ពួកជនជាបណ្ឌិត    សែនឆ្ងាយពិតពីពាលា
មិនដែលបានជិតគ្នា    ក្នុងគ្រាណាបានម្តងសោះ ។
ឯទិសទាំងប្រាំបី    ក៏ឆ្ងាយក្រៃឆ្ងាយទាំងអស់
មិនដែលឮម្តងណាសោះ    ថាខាងកើតជួបខាងលិច។

៙ ត្រើយស្ទឹងតើយសមុទ្រ    ថាឆ្ងាយផុតតែទៅដល់
ត្រើយញាណព្រះទសពល    ទៅមិនដល់យល់មិនផុត ។

៙ ត្រៀបត្រាដូចឃ្លោតត្រឡាច គ្មានអង់អាចស្គាល់ខុសត្រូវ ។

៙ ត្រៀមទុកមុន មិនស្តុនការ ។

៙ ត្រៃចីវរល្អលើសអស់គ្រឿងស្លៀកពាក់    គ្មានពួកអ្នកប្រាជ្ញកែប្រែបំបែរបាន
ជាម៉ូដចាស់រាប់កោដិកប្បពីបុរាណ    ជាសញ្ញាណភាពទង់ជ័យនៃអរហន្ត ។

൙ ត្រៃរតនៈជាវត្ថុសក្តិសិទ្ធិផុតក្នុងលោក ។

൙ ត្រាំពិសដូចពស់វែក ។

★ ★ ★

# ថ

៙ ថយយសព្រោះព្រហើន ។

៙ ថាបើមានកើតគង់មានស្លាប់ ជរាឈឺចាប់ចុកស៊កសៀត
ចៀសទុក្ខជួបទុក្ខៗដល់ទៀត ចង្អៀតចង្អល់ទាល់តែក្ស័យ ។

៙ ថៃទាំទើបគង់ទ្រព្យ (រៀបរណ្ដាប់ទុកទើបជា
ចាយវាយក្រៅតម្រា នៅវិនាសធនធានផង) ។

៙ ថោកអីនៅដៃ ថ្លៃអីនៅមាត់ ។

៙ ថ្ងៃនេះឯងចួនថ្ងៃស្អែកគេ ចួនថ្ងៃនេះដេរថ្ងៃស្អែកជា
ថ្ងៃនេះបណ្ឌិតថ្ងៃស្អែកពាលា ថ្ងៃនេះវឌ្ឍនាស្អែកវិនាស ។

៙ ថ្ងៃជាគ្រូថ្ងៃ ពាក្យនេះជាន័យ បំភ្លឺឱ្យយល់ អ្វីមានខាងក្នុង ជាគ្រូសាកល កុំគិតខ្វាយខ្វល់ រកគ្រូផ្សេងជាតិ ។

៙ ថ្នមឱ្យឡើងចាងទោសច្រើនប្រការ វាយល្មមរាងចាលមានគុណអនេក
ដូច្នោះកុំថ្នមកូននិងសិស្សពេក ត្រូវវាយដំផ្ដេកផ្ដួលពត់ឱ្យហើយ ។

៙ ថ្លង់ចង់ស្ដាប់ច្រៀង ផ្អៀងផ្អងផ្ទៀងផ្ទាប់ ដៃតូចខ្លួនទាបចង់ឈោងចាប់ផ្កាយ ។

៙ ផ្លស់យសព្រោះប្រមាទ ។

៙ ថ្លៃមាសថ្លៃពេជ្រ មិនមែនថ្លៃផ្ដាច់ នៅក្នុងលោកិយ ថ្លៃឫក្សមារយាទ ទើបថ្លៃពិសី

ថ្លៃឥតមានអ្វី ប្រៀបផ្ទឹមស្មើបាន ។

★ ★ ★

# ទ

៙ ទងកុមុទប្រមាណទីផលស្ថាន វិស័យប្រមាណត្រកូលវង្ស
វាចាប្រមាណប្រាជ្ញខ្លៅល្ងង់ ស្មៅល្ហុងប្រមាណនៃពសុធា ។

៙ ទំពបាក់កុំសង្គ្រុញ។ ៙ ទន្លេដប់ មិនស្កប់សមុទ្រមួយ ។

៙ ទន្សាយបានទួល ឬ (ដូចទន្សាយបានទួល) ។

៙ ទន្លេស្ទឹងសុទ្ធសឹងមិនផឹកទឹក ដើមព្រៃព្រឹក្សមិនស៊ីផល
មហាមេឃមិនធ្លាក់នូវភ្លៀងខ្យល់ ក្នុងមណ្ឌលឯណាមួយតំបន់ ។

៙ ក៏ឯទ្រព្យសប្បុរសផងទាំងឡាយ សឹងចម្រើនផ្សព្វផ្សាយដល់មហាជន
ប្រយោជន៍សប្បុរសប្រកបជណ បំពេញបុណ្យផ្លូវកុសលដល់និព្វាន ។

៙ ទម្លាប់ធំជាច្បាប់ បើរៀនច្បាប់កុំត្រាប់ខ្លៅ ប្រាជ្ញាអាចប្រដៅ ស្ដីកូនចៅ ស្ដីឱ្យសោះ

៙ ទានជាទីញ៉ាំងជនដំរឹងអង្គ ឱ្យលះបង់ពុតព្យសន៍កំណាចប្រាណ ទានអាចនាំប្រយោជន៍ទាំងពួងបាន បង្អោនប្រាណពាក្យពីរោះព្រោះទាននាំ ។

៙ ទានជាថ្នាំនាំកើតក្ដីស្នេហា កំណាញ់ជាឱសថានៃទោសទុក្ខ ទានជាថ្នាំយសស័ក្ត

ចម្រើនសុខ កំណាញ់ទុកជាថ្នាំនាំកំព្រា ។

៙ ទាហានច្រើងដ្បិតសឹក ធ្វើស្រែកដ្បិតទឹក ត្រេកពលដ្បិតបាយ សិស្សប្រាជ្ញាដ្បិតគ្រូ ជេរពោលដំវាយ ពលជាដ្បិតនាយ ព្រិលប្រើខះខំ ។

៙ ទិវារាត្រី យប់ថ្ងៃប្រក្រតី តែងរត់ទៅមក កាត់អាយុសត្វ ជនបន្សល់ទុក ផ្តាច់ក្តីសាន្តសុខ ទុកតែងរាងឆ្អឹង ។

៙ ទីប្រជុំកុំកន្ទុះបង្អាប់គ្នា    ឱ្យខ្មាសគេពុំល្អជាពុំគួរគាប់
ទីប្រជុំកុំស្លៀកពាក់អួរអាប់    នេះជាច្បាប់សម្រាប់កាន់អនាម័យ ។

៙ ទីប្រជុំកុំនិយាយឱ្យឮខ្លាំង    គួរឱ្យតាំងនូវស្មារតីនិយាយតិច
ទីប្រជុំត្រូវប្រើឫកស្ងប់ជានិច្ច    នេះជាកិច្ចប្រព្រឹត្តប្រើនៃអ្នកប្រាជ្ញ។

៙ ទីប្រជុំត្រូវប្រើឫកយ៉ាងក្លាហាន    ឱ្យបានឫកពារម្យទមទាំងកុំខ្លាច
ទីប្រជុំកុំប្រើឫកប្រហើនកាច    ព្រោះគេអាចនិន្ទាជាមនុស្សឥតច្បាប់។

៙ ទីប្រជុំកុំនិយាយពាក្យទាស់    ជាទីនាស់របស់ឈ្មោះប្រុសស្រីណា
ទីប្រជុំច្រើនតែមានមនុស្សខុសគ្នា    ក៏ឱ្យកើតទោសវេរាគួរកុំភ្លេច ។

៙ ទីលំនៅចង្អៀតជ្រៀតមិនចុះ    សឹងច្រមុះដោយសារអសោចិគ្រៃ
តែងនាំមកនូវទុក្ខអចិន្ត្រៃយ៍    តែអាស្រ័យទៅបានជាមធ្យម ។

៙ ទីលំនៅៗរួមមនុស្សអារិ    ជាទំនិសត្រូវមិនភិរម្យ

ជាទុក្ខលើសទីពេញអាចម                    នឹងសម្ងំខំនៅសៅនាំរំខាន ។

៚ ទីលំនៅៗរួមអកតញ្ញូ                    ជាទុក្ខរកអ្វីតស៊ូនឹងប្រៀបបាន

លើសលែងទីដែលរួមអារិប្រាណ          ព្រោះសន្តានមក្ខោជាចោរធំ ។

៚ ទឹកថ្លាល្អឹកបើល្អក់ ដ្បិតរលកបោកសោះសា ។

៚ ទឹកទិព្វទោះនៅ ក្នុងថ្នាំពិសក្តៅ គួរយកកុំខាន មានទោះនៅក្នុង ទីស្មោកគ្រោកស្ថាន គួរយកឱ្យបាន កុំខានឡើយណា ។

៚ ទឹកជ្រៅតែងមានជ្រោះ មានសត្វពស់វាពួនខាំ កង្កែបអែបទ្រាសត្រាំ ពស់លបខាំលេបមិនលែង ។

៚ ទឹកបាក់ទៅទាប ដីខ្ពស់កណ្តៀរពូន ។ ៚ ទឹកជន់ បុណ្យស្តេច ។

៚ ទឹកបាក់ទៅទាប បុណ្យបាក់ដ្បិតបាប លាភបាត់ដ្បិតឃោរ ។

៚ ទឹកត្រជាក់ត្រីកុម ទឹកក្តៅត្រីរត់ចេញ ។

៚ ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ។

៚ ទឹកហូរមិនដែលហត់ ព្រះពុទ្ធមិនដែលខឹង។

៚ ទឹកហូរមិនដែលហត់ ប្រុសស្បថកុំឱ្យជឿ ។

៚ ទឹកបាក់ទៅទាប លាភបាក់ទៅសិរី ទួលហៅម្តេចក្តី ទឹកទៅពុំបាន ។

៚ ទឹកខ្លាចគេដងដាក់តម្កល់ ជាតិដែលដុលខ្លាចគេដាំឆៅ ក្រញូងខ្លាចធ្វើខ្នួចក្លួចដូចស្មៅ ទូកខ្លាចគេទៅជាន់គែមផ្អៀង ។

៙ ទឹកហូរតាមប្រឡាយ ទន្សាយបោលតាមប្រឡោះ ។

៙ ទឹកថ្លាលាងសក់ ទឹកល្អក់លាងជើង ។

៙ ទុកចោលវាចាស់ ប្រើណាស់វាថ្មី ។

៙ ទុកចិត្តកុំឱ្យដាក់ ស្មើភ្នែកខ្វាក់ទាំងសងខាង
ឱ្យកូនគន់មើលតាង ស្មើភ្នែកម្ខាងពុំពេញពីរ ។

៙ ទុក្ខខ្សោយជាងចិត្ត សព្វខ្សោយកម្មពិត លោកខ្សោយជាងធម៌ ជាតិខ្សោយសាស-នា លាមកខ្សោយល្អ អាត្មាខ្សោយករ ជនសក្រឃើញ។

៙ ទុច្ចរិតសុចរិត ដែលជនប្រព្រឹត្ត ក្នុងជាតិនេះណា គាប់ជានិស្ស័យ បច្ច័យវាសនា ដិតជាប់អាត្មា ទៅបរលោកនាយ ។

៙ ទូកនៅកំពង់នៅ ។ ៙ ទូកបែកជាទូកគត់ ទូកកំបុតជាទូកកង ។

៙ ទឹកហួសកំពង់ វាចែវចង្អង់ ថយមកចូលចាប់ ពាក្យលឿនហួសខ្នាត ហៅឥតទំនាប់ ថយមករកគាប់ ពុំបានឡើយ ។

៙ ទូកលឿនជិះលុបអុំឱ្យលិច ត្បូងពេជ្ររឹងម្តេចគង់ប្រេះឆា
ទីស្វាត់ប្រយ័ត្នចេងវាចា គិតអាថ៌ឯណាកុំអាងជិត ។

៙ ទូកយើងវែង ទូកគេខ្លីតាមគេម្តេចបាន ឬទាន់ ។

៙ ទូកដាច់យកទូកតាម ។ ៙ ទូកប្រហោងក្នុង ឬ(ទូងៗដូចស្គរ) ។

៙ ទើងធីប្រើរក ទើបស្វែងប្រើទៅ ទើងស្នេហ៍ប្រើហៅ មិត្រមកជាមិត្រ ។

៙ ទេពីមើលព្រឹក្ស ក្សត្រាមើលឫទ្ធិ ពលមើលចេស្ដា ជាងមើលអំពើអំពីហត្ថា ទោះយកភរិយា មើលនាលំនៅ (ខ្លះថាទាហានមើលចេស្ដា) ។

៙ ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោកសល់ រមិលមើលយល់ប៉ុនភ្នំ ។

៙ ទោសតិចកុំទាញផ្សំ ឃើញមិនចំកុំនិយាយ

កុំចាប់ស្ទើររវើរវាយ នាំឱ្យរវល់អំពល់ចិត្ត ។

៙ ទោះពេលយប់ព្រលប់ គន់ឱ្យគ្រប់ទ្រព្យនានា ។

៙ ទោះមុខមន្ត្រី សេនាបតី ពុំដោយគន្លង រលោភោចង់បាន បំពានរាស្ត្រផង រាស្ត្រនឹងក្ដៅក្រហាយ អង្គឥតអាស្រ័យ ។

៙ ទោះគិតកុំរួសរាន់ គិតឱ្យគ្រាន់ទើបដើរទៅ កុំឱ្យអាប់អាសៅ កើតដំនៀលដល់អាត្មា។ ឬ (គិតឱ្យគ្រាន់ទើបដើរទៅ) ។

៙ ទោះបីដំរីបាត់ លោកប្រើស្កាត់វាជាត្រើយ តាមនឹងដំរីហើយ កុំបីដើរនឹងជើងលា។

៙ ទោះទូកដាច់សាត់សោះ យកទូកស្នោះទៅតាមគ្នា ។

៙ ទៅឥតគេរក មកឥតគេហៅ ។

៙ ទៅទាំងប៊ីទាំងស្គរ ។ ៙ ទំពាំងស្នងឫស្សី ។ ៙ ទុំមុនស្រគៀល ។

៙ ទាំងគេឯងតែងតែមានភាន់ច្រឡំ ប្រឹងគិតខំឱ្យទៀងទាត់គង់ភ្លាត់បាន

ទុកជាអង្គបុព្វបុរសពីដើមដាន ក៏គង់បានភាន់ច្រឡំមកខ្លះដែរ ។

៙ ទ្រព្យគង់ដ្បិតស្រីចេះសំចៃទុក ផ្ទះធំស្រណុកដ្បិតភរិយាជា ។

៙ ទ្រព្យធននេះថោកថ្លៃ កុំដាក់ដៃឱ្យតែកូន (នៅអស់ទាំងបងប្អូនអ្នកដទៃរក្សាតាង) ។

៙ ទ្រព្យច្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះរក ។

៙ ទ្រព្យធនទោះថោកថ្លៃ រួមរក្សាកុំបីឆ្លោយ ។

៙ ទ្រព្យស្មើដោយវិជ្ជានោះពុំមាន សត្រូវប្រាណមិនស្មើដោយព្យាធិ
ស្រឡាញ់ក្រៅមិនស្មើកាយិន្ទ្រិយ៍ កម្លាំងអ្វីមិនបានកម្មបុរាណ ។

៙ ទ្រព្យមានលើកឱ្យគេខ្ចីទៅ ចំណេះចេះនៅតែក្នុងក្បួន ប្រពន្ធនៅឆ្ងាយអំពីខ្លួន ដល់ចួនត្រូវការរអាចិត្ត ។

៙ ទ្រព្យរបស់សប្បុរសទោះតិចតួច បានជាប្រយោជន៍ជននានា ដូចទឹកអណ្ដូងរសសាបថ្លា អស់មហាជនផងដងអាស្រ័យ ។

៙ ទ្រព្យសប្បុរសទោះមានច្រើន ពុំបានចម្រើនអ្នកដទៃ ដូចទឹកសមុទ្រ មានរសប្រៃ មនុស្សផងអាស្រ័យផឹកពុំបាន ។

៙ ទ្រព្យសម្បត្តិដែលប្ដីឱ្យកើតមាន ស្ត្រីជាពានទទួលគ្រងរក្សា បុរសជាប្រធាននៃភរិយា ស្ត្រីដូចចេសម្ទុលផុលជាប់នៅ ។

៙ ទ្រព្យលួចប្លន់បាន ធ្វើដើមធនធាន រកស៊ីកែខៃ មិនដែលចម្រើន បាកុំសង្ស័យ មុខជាហិនហៃ វិនាសហិនហោច ។

៙ ទ្រព្យលើកឱ្យគេខ្ចី ចេះដឹងអ្វីឆ្លើយមិនបាន ភរិយានៅឆ្ងាយប្រាណ ឈ្មោះថាគ្មានៗ ដូចគ្នា ។

៙ ទ្រព្យធនមាសងាយរក្សា ជាតិស្ត្រីកញ្ញាលំបាកថែ ចិត្តវាឃ្លោងយប់ថ្ងៃប្រែ គំនិតគេចកែពិបាកស្គាល់ ។

៙ ទ្រព្យធនខ្លួនផងក្តី ឱ្យគេខ្ចីទោះច្រើនតិច ដល់ត្រូវការធ្វើម្តេច និងបានចាយថាគ្មាន។

៙ ទ្រព្យពាលប្រយោជន៍រួមគ្នា ទ្រព្យសប្បុរិសាសាសនាជាតិ ដូចទឹកអណ្តូងភ្លៀងកើតអាទ៌ អ្នកផងសង្វាតដងអាស្រ័យ ។

៙ ទ្រព្យកើតក្រោយកិរិយា បើរកភរិយារើសមារយាទ ក្រទ្រព្យមាសប្រាក់បញ្ញាឆ្លាតហៅមានតាមខ្នាតគង់ពកស្នែង ។

៙ ទ្រព្យដែលគេបាន ដោយនៅលំអាន មិនសូវព្យល្បី ដល់ខ្វាត់បាត់ទៅ បាកលំនៅថ្មីឮសព្ទស្រដី ល្បីពេញទាំងស្រុក ។

៙ ទ្រាំអត់សង្កត់ចិន្តា ប្រសើរថ្លៃថ្លាក្នុងលោកិយ លែងជាតិពីរនេះទៅក្តី សម្តេចជិតស្រីទ្រង់ត្រាស់សរសើរ ។

★ ★ ★

ឆ

៙ ធម្មជាតិជ្រៃបញ្ញើក្អែក ទំនើរលើមែកឈើព្រឹក្សព្រៃ ជញ្ជក់យករសឥតប្រណី ទាល់តែក្សិណក្ស័យវិនាសបង់ ។

៙ ធម្មជាតិជំហានដែលឈានដើរ ដំណើរទៅកាន់គ្រប់ទីស្ថាន តែងយោលទៅមុខតាមលំអាន ទើបជ្រែងជួយច្រានប្រាណជ្រុលទៅ ។

៙ ធម្មជាតិក្នុងលោក មានប្រាជ្ញមានព្រោក មានឆោតល្ងង់ឆ្កួល ជាគូនឹងគ្នាទប់ទល់តាមកល ឱ្យកើតវិលវល់ ក្នុងនាលោកិយ ។

៙ ធម្មតាវែកមិនស្គាល់រសសំឡ មេអំបៅមិនស្គាល់រសបុប្ផា ពួកល្ងង់ខ្លៅមិនស្គាល់រសសេធម្មា បាបពាលាមិនស្គាល់រសបុណ្យ ។

៙ ធម្មតាអ្នកជាជាតិ ការកេរ្តិ៍អាទិគិតគូរ កុំខ្ជិលដេកទទូរ ទាល់ថ្ងៃរះពេញពន្លឺ ។

៙ ធម្មតាមិនមែនជាបងប្អូន ល្អុះល្អូនមិនបាយូរអង្វែង បើកើតអាក់អន់ក៏រមែង លះលែងស្រឡាញ់ឈប់រាប់អាន ។

៙ ធម្មសត្យា មន្ត្រីប្រជា ត្រូវកាន់ហ្មត់ចត់ ទើបប្រទេសជាតិ ចម្រើនប្រាកដ ពាក្យសត្យសន្មត់ ជាមូលយុត្តិធម៌ ។

៙ ធម៌ចង់ជាហេតុឱ្យកើតទុក្ខ ធម៌ចង់ជាគ្មានសុខមួយវេលា តែចង់ទុក្ខជួយឱ្យវេទនា ចង់រាទុក្ខរត់ផុតប្រកាន់ ។

៙ ធុងទទេឮខ្លាំងណាស់ ។ ៙ ធំតែខ្លួនដូចឃ្លោក ។

៙ ធូន់នៅថ្ម ក្រនៅក្តី ។ ៙

៙ ធូន់អម្រែកជួយគ្នាបាន ធូន់ជម្ងឺក្នុងប្រាណជួយមិនបានទេ ឬ(ជួយមិនកើតទេ) ។

៙ ធ្នូស្នាបង់បាញ់ ធម៌បង់ទន្ទេញ ស្រីបង់ភស្តា របាំបង់លេង វង្វេងតម្រា ចុះក្នុងមាលាមន្ទិលសៅហ្មង (លោកនីតិ) ។

៙ ធ្វើការអ្វីគប្បីគិតទៅមុខផង ក្រែងសៅហ្មងប៉ះពាល់ជាតិញាតិសន្តាន មើមុខក្រោយ កុំបណ្តោយឱ្យតែបាន សុខសាន្តត្រាណតែខ្លួនឯងមិនក្រែងគេ ។

៙ ធ្វើការអ្វីតែចម្លែកប្លែកពីគេ បើមិនបានប្រសើរទេមុខជានឹងខុស អាប់យសឈ្មោះ អប្រិយល្បីសាយសុស គេបន្តុះគេបន្ទាបរាបដល់ដី ។

៙ ធ្វើការបានប្រាក់ ធ្វើការបានស័ក្តិ ធ្វើការបានយស ធ្វើការបានទ្រព្យ បានវិជ្ជាស្មោះ ចម្រើនឥតថ្លស់ ដោយសារការងារ ។

៙ ធ្វើការជាមួយប្រុសពាលព្រួយល្មម លំបាកណាស់ព្រមស្រីពាលា ធ្វើការរបៀបរវែង ខ្លោចផ្សា ពួកសប្បុរិសារួមស្រួលងាយ ។

៙ ធ្វើការអ្វីឱ្យប្រាកដ ទើបផុតខ្សត់ទូក្ខវេទនា បើធ្វើតែមាត់ខ្ជិលខ្ជីខ្ជារ គ្មានគិតការងារ ប៉ុនពងចៃ ។ ប្រាប់អ្នកដទៃថាធ្វើការ យកឈ្មោះសង្ហាខំកែខៃ ពេលចូលធ្វើការរាល់ៗថ្ងៃ ចិត្តគិតអាល័យតែម៉ោងចេញ។ នេះហៅធ្វើការធុនខ្ញុំគេ គ្មានគិតគ្នាន់គ្នេរខាតចំណេញ ដល់ផលហុចឱ្យត្រឡប់វិញ ធ្វើមាត់ស្ញេញថ្ងូរថាក្រៗ ។ (សុង ស៊ីវ)

៙ ធ្វើការងារគ្រប់បែបយ៉ាង ជាព្រេងសំណាងរបស់មនុស្ស មិនមែនសំណាងខំទម្លុះ មេឃដីហើយស្ទុះមករកទេ ។ (សុង ស៊ីវ)

៚ ធ្វើការក្រសួងណាកុំយកក្រសួងនោះធ្វើជាយីហោ ហើយក្លែងធ្វើចោរបន្លំខំឆ្លៀតពងទឹកន្លៀត អ្នកធ្វើយ៉ាងនេះសំគិះគេថាមនុស្សចោលម្សៀត នេះឯងហៅជនក្បត់ជាតិយ៉ាងកំសាកកំសុយសោះ ។ (សុង ស៊ីវ)

៚ ធ្វើគុណបានទោស ដូចប្រោះខ្លាស្លាប់ ។

៚ ធ្វើចេះត្រូវគេប្រើ ធ្វើល្ងីល្ងើស្រណុកខ្លួន ។

៚ ធ្វើឆ្កួតដើម្បីស្តាប់កិច្ចការ ធ្វើភមរាដើម្បីក្រេបរសជាតិ ព្យាយាមមុតមាំកុំបីឃ្លាតខ្មីឃ្មាតសង្កេតគង់ឃើញកល ។

៚ ធ្វើជាចៅក្រមមិនលែងនិយាយហួស ធ្វើជាអ្នកបួសមិនលែងត្រូវអាបត្តិ ។

៚ ធ្វើទានធ្វើឱ្យស្មោះ កុំអាឡោះអាល័យស្ងួន ឬ (ឱ្យទានឱ្យស្មោះ) ។

៚ ធ្វើបាបមិនធ្វើបុណ្យ លែងជាតិទៅនៅនរក ។

៚ ធ្វើមេអ្នកបាអ្នក។

៚ ធ្វើស្នូមយាចក ថោកទាបអាក្រក់ ក្នុងនាលោកិយ ក្រទ្រព្យសម្បត្តិ មារយាទសោភីទុកជាប្រុសស្រី រាប់មុខទុកចិត្ត ។

៚ ធ្វើស្រែទាន់ក្តៅដី ចង់ស្រីទាន់ក្តៅចិត្ត ។

៚ ធ្វើស្រែខុសមួយឆ្នាំ ឆ្នាំក្រោយទ្រាំគង់ចំណេញ បើយកប្រពន្ធវិញតែខុស ម្តងខុសរហូត ។

៚ ធ្វើស្រែឱ្យមើលស្មៅ ទុកដាក់កូនចៅឱ្យមើលផៅសន្តាន ។

៙ ធ្វើស្រែលើទួល សាកស្លួរទំនួល មនុស្សល្ងង់ងងឹតយប់ ទីពឹងអសប្បុរស បានទុក្ខទោសសព្វ បណ្ឌិតសេពគប់ បានសុខសួស្តី ។

៙ ធ្វើស្រែទាន់មានភ្លៀង ខំស្រែកច្រៀងទាន់ចិត្តចង់ សាងជាតិដោយស្មោះត្រង់ ខំចង់ស្រីទាន់ក្តៅចិត្ត ។

៙ ធ្វើស្រែយកស្រូវ បើគាបអំពៅ គេយកស្ករជាតិ បុគ្គលជួយយើង ប្រាថ្នាសង្ឃាត កំរៃតាមខ្នាត មិនមែនទទេ ។

៙ ធ្វើអ្វីឱ្យស្បាន់ ធ្វើអ្វីឱ្យបាន ធ្វើអ្វីផ្ទង់ធ្វើឱ្យស្រូវ ធ្វើអ្វីឱ្យត្រង់ ធ្វើអ្វីឱ្យគង់ ធ្វើអ្វីឱ្យគាប់។

៙ ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ ។

៙ ធ្វើមិនបាច់ភ្ជួរ រក្សាតែម្បូរ ស៊ីស្រូវមិនអស់ ។

៙ ធ្វើស្រែចំការឱ្យមើលស្មៅ ទុកដាក់កូនចៅឱ្យមើលផៅសន្តាន ធ្វើទីលំនៅមើលភូមិស្ថាន បរិភោគប្រមាណមើលអាហារ ។

៙ ធ្វើអ្វីធ្វើឱ្យហើយ កុំទុកឡើយបង្កើតកេរ្តិ៍ សម្អាតអស់សរិល កុំឱ្យមានក្តីនិន្ទា ។

**រូបកាយតែងចាស់ជរា ឯកេរ្តិ៍ឈ្មោះល្អ មិនចេះចាស់ជរាឡើយ**

**នាំងធម៌របស់សប្បុរស ក៏មិនចេះចាស់ជរាដែរ៕**

ស្រង់ចាកសុភសិត សម្តេចព្រះមហាសុមេធាធិបតិ សង្ឃនាយក

គណៈមហានិកាយ (ជោតញ្ញាណោ ជ.ណ)

ឆ

៙ នរជនណាមានពាលស្អប់ពាលពាធា ពាលនិន្ទាពាលឈ្នានីសរិះគន់គ្រប់ នរជននោះជាអ្នកប្រាជ្ញគួរសេពគប់ ទុកជាម្លប់ការពារថ្ងៃអាស្រ័យបាន ។

៙ នរជនស្រឡាញ់អសប្បុរស មិនសោមនស្សធ្វើសប្បុរសផង ត្រេកអរធម៌អសប្បុរស សេពសៅហ្មង បទនេះហោងជាហេតុអន្តរធាន (បរាភវសូត្រ) ។

៙ នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនមានចិញ្ចឹមរក្សា មាតាបិតាដែលចាស់ជរា ហេតុនោះទៅជានាំឱ្យវិនាស ។ (បរាភវសូត្រ)

៙ នរណាអេះ ! ចេះផ្គាប់មនុស្សត្រូវគ្រប់គ្នា កុំបីមានគេនិន្ទាឈ្នានីសបាន ឱ្យគាប់ចិត្តស្និទ្ធសេពគប់គ្រប់ៗប្រាណ យើងសន្និដ្ឋានថាគ្មានម្នាក់ជាក់មែនហើយ ។

៙ នរណាឡើយសម្រួចបន្លាភ្នំ សភាពស្រួចៗសមកំណើតវា នរណាឡើយដាក់ថ្នាំភ្នែកម្រឹគា សភាពខ្មៅៗថ្លាធម្មតាតែង ។

៙ នរណាឡើយដាក់ថ្នាំក្នុងបង្កផល សភាពនៃក្លិនឧប្បលក្រអូបឯង កុលបុត្រកបរូបបច្ច័ក្ខចែង សភាពរូបល្អឯងតាមវាសនា ។

៙ នរូអ្នកណា ទោះយកអាត្មា ចូលសាសន៍ពុទ្ធរតន៍ ចូរធ្វើឱ្យត្រង់ ដោយនូវបន្ទាត់ហៅស្វែងសម្បត្តិ យកផ្លូវនិព្វាន ។

៙ នាកាលកើតកលិយុគយុទ្ធនា ព្រះរាជត្រូវការអ្នកក្លាហាន នាកាលព្យាធិយាយីប្រាណ ទ្រង់ចង់បានពេទ្យចេះមន្តសុខា ។ នាកាលពេលបរិភោគអាហារវិញ ចង់បាន

មិត្រសម្លាញ់មកភោក្តា នាកាលកើតកិច្ចអាថ៌ប្រស្នាសឹងប្រាថ្នារកប្រាជ្ញអាចដោះស្រាយ។

៙ នាងគូនឹងអ្នក មេខាតលក្ខណ៍គូនឹងអាកំបាក់ទន្សា ក្សត្រីគូនឹងក្សត្រា ស្រីទេពកញ្ញា គូនឹងមហាក្សត្រ ឬ(នាងរត់រកអ្នក មេកណ្តាច់លក្ខណ៍រត់រកអាកំបាក់ទន្សា ទំទាវរត់រក ឧកញ៉ា នាងទេពកញ្ញារត់រកមហាក្សត្រ) ។

៙ នាកាលកិច្ចការគឺខ្លួនធ្វើហើយ គ្មាននរណាមួយឡើយមើលនរណាហេតុនោះឯង សព្វអំពើកិច្ចការ ទោះជាធ្វើការនោះដោយសល់នៅ ។

៙ នាងតីស្នាគាង ស៊ីរះសងខាង មិនឱ្យអន់ចិត្ត ឬ(មិនឱ្យទាស់ចិត្ត) ។

៙ នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង ទោះនឹងឆ្ពោះទៅ ស្រុកតូចធំផង សឹង ដូចបំណង នៃចិត្តប្រាថ្នា ឬ(នៃចិត្តចិន្តា) ។

៙ នារីណាមានកាយពិការអង្គ តែចេះផ្គង់ធ្វើវត្តប្រតិបត្តិប្តី នារីនោះថារូបពិសី ប្រុស កាលើរូបពិការតែចេះការ ។ វិជ្ជាការចេះនោះនាំយោងប្រាណជួយឱ្យបានឋានន្តរទីអាចារ្យ ឬស័ក្តិយសខ្ពង់ខ្ពស់ក្នុងសង្សារ មិនខាតការលោកិយស្រីគង់ដោយ ។

៙ នារីមានប្តីពីរបីដង ភិក្ខុផងនៅវត្តពីរបីវ៉ា[8] បក្សីជាប់ជង់ពីរបីគ្រាមាយា ពួកនេះធ្វើ ច្រើនក្រៃ ។

៙ នារីជួរជាតិ បង្កវិវាទ បង្ខិនឱ្យខ្លាច ប្រកាន់អំនួត ប្រកួតអំណាច ប្រកឹងពូជកាច ប្រកាន់ពង្សា ។ ដាំស្លខ្ទះខ្វាយ បង់ខាតមិនស្តាយ មិនស្តាប់មេបា ឃើញប្រុសក្រឡេក តម្រេកតណ្ហា សម្តែងមាយា មារយាទកិច្ចកល ។

---

[8] ពីរបីវ៉ា គឺពីរបីវត្ត ។ វត្តវ៉ា ។

៙ បរិភោគចំណី ចំណូលស្វាមី មិនទុកសំណល់ រួចបាយចុះក្រេស សំណេះទៅដល់ផ្ទះគេថ្លែងកល ថ្លែងកិច្ចក្អាកក្អាយ ។

៙ ប្រុសប្រាជ្ញត្រេកត្រ៊ិះ បើបានស្រីនេះ ព្រះស្តែងកុំស្តាយ ក្រហល់ស៊ូនៅ យូរទៅក្រហាយ ទោះកូនរយប្លាយ គួរផ្លាស់ជាថ្មី ។

៙ នារីណាប្រាថ្នាបុរសគាប់ ចង់ឱ្យជាប់រឿយៗសព្វជាតិណា គួរគោរពស្វាមីនៃអាត្មា ដូចអច្ឆរាបម្រើព្រះកោសីយ ។

៙ នារីរូបខ្មៅអាក្រក់ក្រៃ តែមារយាទថ្លៃចិត្តសោភា វិសេសជាងស្រីល្អរូបបាចិត្តលោកា មិនល្មមនឹងកាមរាគ ។

៙ នាយស្នូនផ្ទាំជំផ្ទាំងតាំងឱ្យល្អ គ្រូនឹងតតាំងវាយសិស្សឱ្យសិក្សា នឹងឱ្យធ្លាក់អបាយនោះកាលណា វាយប្រាថ្នាជាហេតុចម្រើនសិស្ស ។

៙ ជេរវាយនោះនឹងឱ្យសិស្សអន្តរាយ ធ្លាក់ទៅក្នុងអបាយក៏ទេណា ជេរវាយនោះជាហេតុឱ្យវឌ្ឍនា មានវិជ្ជាចម្រើនដល់កូនសិស្ស ។

៙ និយាយស៊ីឱ្យមើលតម្រា និយាយការឱ្យមើលទំនង ។

៙ និយាយច្រើនគេមិនស្តាប់ អាប់ប្រាជ្ញា ។

៙ និយាយបែកជាអូរហូរជាស្ទឹង ។

៙ និយាយយប់ផ្ទប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក ។

៙ និរាសកុំម្ទេញ ខឹងកុំទន្ទេញ ស្អប់កុំព្យាបាទ ។

៙ និរាសកុំម្ទេញ ទុក្ខពេញកុំដឹង ខឹងកុំទន្ទេញ មិត្រកុំបណ្ដេញ ស្អប់កុំព្យាបាទ ។

៙ នឹងជួញចេញគិតក្រោយ ទោះនឹងឱ្យៗមើលមុខ ។

៙ នឹងឆីចង់ពិសា ខ្ជិលទំពាឱ្យម៉ដ្ឋហ្មង ។

៙ នឹងលើរង្កើក្រោម ។ ៙ នឹងលេបវាស្លាក់ នឹងខ្ទាក់វាស្លែង ។

៙ នឿយណាស់កុំដេក យកប្រពន្ធឱមើលម្ដាយក្មេក ចូលដំណេក កុំនិយាយនឹងប្រពន្ធ ។

៙ នៅផ្ទះឱ្យស្រាស់បន្លា អារសាច់ជូនខ្លា ទើបនៅស្រុកបាន ខ្លះថា(នៅព្រៃឱ្យស្រាស់បន្លា) ។

៙ នៅផ្ទះម្ដាយជាទីទៃ ទៅព្រៃម្ដាយជាមួយ ។

៙ នៅស្ងៀមព្រងើយ គ្មានអ្នកណាឡើយ ជាមិត្រអ្នកណា អ្នកជាសត្រូវ ក៏គ្មានដូចគ្នា ដឹងមិនបានថា អ្នកណាដូចម្ដេច ។

៙ នៅត្រង់ណា គ្មានចេះអក្ខរា ន មោ ក ខ ទីត្រង់នោះឯង លោកតែងតែសរសើរ ចេះ ក ខ ក៏ធ្វើប្រាជ្ញបាន ។

៙ នៅជិតសប្បុរស សុខស្រួលទាំងអស់ ឥតមានភិតភ័យ នៅជិតជនពាល មានតែចង្រៃ ព្រួយចិត្តរាល់ថ្ងៃ មិនបានក្ដីសុខ ។

៙ នៅជិតមនុស្សពាល ដូចភ្លើងឆេះវាល ឆេះព្រៃព្រឹក្សា ដូចសត្វមានពិស ក្លាខ្លាំងពាលា ដូចយក្សមនុស្សា តែងមានទោសទុក្ខ ។

៙ នៅមូលបងប្អូនប្រពន្ធ ថ្នមចិត្តឱ្យធ្ងន់កុំអាលជេរ បើឃើញខ្លះខ្ជិលនៅទំនេរ កុំស្ងៀមទទេដាស់តឿនទៅ ។

៙ នៅមិនឈ្នះនាង រាងមិនឈ្នះរោគ ជោគមិនឈ្នះចង់ បានមិនឈ្នះបង់ ត្រង់មិនឈ្នះទាល់ ។

៙ នំដែលបង្កប់ថ្នាំពិសពុល ឃើញល្អសោតសល់ដូចនំទិព្វ ដល់ដាក់ក្នុងមាត់បរិភោគ គ្រឹប ប្រកាច់រឹបដួលតូងស្លាប់តែហោង ។

៙ នំពុលទុកដូចជាលាភយស ដែលអសប្បុរសចក្រពត្តិកោង វាថាជួយលើកជួយសណ្ដោង ដល់អ្នកលង់តោងវាជាន់ក ។ (សុង ស៊ីវ)

៙ នំណាមានរសជាតិល្អឆ្ងាញ់ពិសា គេត្រូវការរកនំនោះគ្រប់ៗគ្នា រដ្ឋបុរសស្មោះជួយជាតិឥតរួញរា ជាតិសាមគ្គានាំគ្នាតាមទាំងប្រទេស ។

៙ នំបង្អែមជាសត្រូវអ្នកប្រមឹក ការរវើកជាសត្រូវអ្នកស្ងប់ស្ងាត់ ព្រានប្រមាញ់ជាសត្រូវដល់ពួកសត្វ មិនប្រតិបត្តិជាសត្រូវដល់ក្បួនច្បាប់ ។

៙ នាំមិនដែលធំជាងនាឡិ ។

★ ★ ★

# ប

៙ បក្សាសប្បាយនឹងនភាល័យ    សត្វក្នុងព្រៃសប្បាយនឹងព្រឹក្សា

សេដ្ឋីសប្បាយចិត្តនឹងទ្រព្យា    សប្បុរិសាសប្បាយនឹងព្រះធម៌ ។

៙ បក្សីត្មាតបន្ទោសនិគមស្រុក    អ្នកឈឺរងទុក្ខបន្ទោសអាហារ

អ្នកក្របបន្ទោសព្រេងវេសនា    អ្នកខ្ជិលធ្វើការតែងត្មះពេល ។

៙ បក្សីសឹងអាងអាកាសស្ថាន    ត្រីប៉ុន្មានសឹងអាងព្រះគង្គា

អ្នកទុព្វលសឹងអាងព្រះរាជា    ទារិកាតូចៗសឹងអាងយំ ។

៙ បង់ព្រះទៅសំពះឯបាយាប ។

៙ បង់បោយមិនមើលប្រាណ ដាំជើងក្រានមិនប្រមាណផ្នាំង

ឬ (បង់បោយឱ្យមើលប្រាណ ដាំជើងក្រានឱ្យប្រមាណផ្នាំង) ។

៙ បញ្ញើទុកស្មើបំណុល ។

៙ បណ្តាបុណ្យទ្រព្យ ជាបុណ្យគួរគាប់ មិនមានអន្តរាយ សម្បត្តិទ្រព្យប្រាក់ ចោលខ្ចាត់ខ្ចាយ មិនបានវែងឆ្ងាយ បានតែមួយជាតិ ។

៙ បណ្ឌិតស្ងៀមស្ងាត់ ចាំស្តាប់គ្រប់មាត់ អ្នកពោលប្រាស្រ័យ ប្រើស្មារតីគិត គំនិតខ្ញែ ឱ្យបានជោគជ័យ ជាងពោលប៉ប៉ាច់ ។

៙ បណ្ឌិតចរទៅដោយជើងម្ខាង    សំអាងឈរដោយជើងមួយខ្មី
មិនបានត្រិះរិះនូវទីថ្មី    មិនគប្បីលះចោលលំនៅចាស់ ។

៙ បណ្ឌិតត្រាច់ចរទៅដោយចិត្ត    តាំងពិនិត្យបែរមើលនូវទីថ្មី
ប្រៀបដូចឈានជើងម្ខាងទៅខ្មី    កាលឈរក្តីដោយចិត្តកម្ចាត់បង់ ។

៙ លះចោលទីស្ថានចាស់មិនអាងខ្មាង ប្រៀបដូចឈរជើងម្ខាងរំពឹងអង្គ
មិនពិចារណាទីថ្មីរំពៃត្រង់  មិនលះបង់ទីស្ថានបូរាណចាស់ ។

៙ បន់ព្រះសំពះទេព្តារ ។

៙ បន្លាស្រួចភ្នំស្រួចៗខ្លួនឯង    គ្មានអ្នកណាចាត់ចែងសំរួចវា
ភ្នែកម្រឹកខ្មៅៗឯងជាធម្មតា    គ្មានអ្នកណាចាត់ថ្នាំចាំគោរព ។

៙ ផ្កាឧប្បលមានក្លិនក្រអូបឯង    គ្មានអ្នកណាចាត់ចែងដាក់ទឹកអប់
កុលបុត្រចេះឯងដឹងឯងសព្វ    គ្មានអ្នកណាប្រារព្វចាំដាស់តឿន។

៙ បរិភោគអាហារការសេពកាម ដេកត្រេកញ៉ាបញយៗមិនឈប់នៅ
មានក្នុងគោនិងបុរសអស់ទូទៅប្រុសមានសិល្បសាស្ត្រនៅវិសេសក្រៃ ។

៙ បើប្រាសចាកចេះវិជ្ជាការ    ជាអាសារឥតការឥតកម្រៃ
ទុកស្មើគោគេផ្ទុកប្រើសព្វថ្ងៃ    នឹងអាស្រ័យក្តីទុក្ខរកសុខគ្មាន ។

៙ បរិវិតក្កក្តៅក្តួលអួលអន់អាក់ ចូលចាប់ចាក់ជីវិតមនុស្សផ្លុះដល់ ថ្លើមមុតជាងដាវ

ជាងកាំបិតស្និទ្ធសម្បើម បរិវិតក្កនេះជាឆ្នើមគួរឆ្មើមពេក ។

៙ បាតដៃជាខ្នងដៃ ឬនិយាយបាតដៃជាខ្នងដៃ ។

៙ បានមាត់បានក ។

៙ បានហើយមិនល្មមចង់ល្មោតទៀត មិនឆ្លៀតដោះកាយឆ្ងាយពីជ្រាំចិត្ត ផ្ដេកត្រេក ផ្ដិតផ្ដួលបង្ខំ ទៅចំទូលកាមតាមនិស្ស័យ ។

៙ បានតែបាបមិនឆ្អាបមាត់ ។

៙ បានពីក្អែកចែកទៅតាវ៉ៅ ។

៙ បានមកថាតូច រួចទៅថាធំ ។

៙ បានមកទុកឱ្យគង់ កុំឱ្យបង់បាត់ឡើយហោង ។

៙ បានមាស ក្រអីនឹងក្រដាសខ្ចប់ ។

៙ បានស្វាយណាយក្រូច បានតូចណាយធំ បានក្រមុំណាយចាស់ មិនបានឈ្នះបង់។

៙ បានហើយចង់បានទៀត ឆ្លៀតហើយឆ្លៀតទៀតកុំគិតឈ្វេង មើលយល់តែមុខឯង មិនមើលគេឯទៀតផង ។

៙ បានច្រើនកុំខំពារឱ្យសន្សឹមតិចៗទៅ ឬ(ឱ្យសន្សឹមសៀរតិចទៅ)

៙ បាបពុំទាន់ឱ្យផលដល់កាលណា ពាលគិតថាបាបផ្អែមដរាបនោះ

បាបឱ្យផលកាលណាទើបពាលលុះ ដល់ក្ដីទុក្ខចំពោះកាលនោះឯង

៙ បាបពុំទាន់ឱ្យផលដល់កាលណា   ពាលគិតថាបាបនោះដូចទឹកឃ្មុំ

លុះបាបកម្មឱ្យផលដល់ប្រជុំ   ទើបពាលរងទុក្ខធំក្នុងកាលនោះ ។

៙ បាបមិនឆ្អាបមាត់ ។

៙ បាបកម្មកុំបីមាន សីលនឹងទានឱ្យរិះគិត ។

៙ បាយសង្ឃដ ហ៊ានប្រមាថកន្ទោងធំ ។

៙ បាយកកបាយទា ប្រពន្ធមាជាភ័ព្វក្ដួយ ដំរីស្លាប់ជាភ័ព្វក្ដួយ ប្រពន្ធក្ដួយជាភ័ព្វមា។

៙ បាយកកក៏បាយ មេម៉ាយក៏ស្រី ឬ(កកក៏បាយ...) ។

៙ បាយថ្លាន់ៗដូចបបរឈ្មោល ឬ(បាយជ្រាយដូចបបរឈ្មោល) ។

៙ បុគ្គលណាគប់សេពដោយសប្បុរស សោមនស្សសម្ភពគប់ប្រាជ្ញ ប្រាណអាចដឹងរសធម៌របស់សប្បុរសផងទាំងឡាយ បុគ្គលនោះឆើតឆាយផុតបាបកម្ម ។

៙ បុគ្គលកើតក្នុងត្រកូលកាច អង់អាចយល់ទោសគេប៉ុនល្ង មិនយល់ទោសខ្លួនដែលធ្វើមក គរប៉ុនទាំងដូងឈោងមិនដល់ ។

៙ បុគ្គលយល់ទោសអ្នកដទៃ តូចប៉ុនគ្រាប់ស្ពៃ ឬល្ងសក ទោសខ្លួនប៉ុន ដូចទាំងសម្បក បែររករិះគយគន់មិនយល់ ។

៙ បុគ្គលអ្នកស្រែ ដង្ហៅជួយប្រែ អាមាត្យមន្ត្រី សមណព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតកវី មានសូត្រសិល្បក្ដី កើតវិបុលា ។

៙ ជនទាំងឡាយនោះ មែនមានចំពោះ នៅក្នុងដែនណា ដែននោះរុងរឿង ថ្កុំថ្កើង

មហិមា ក្របកសុខសា បាយបរិបូណ៌ហោង ។

៚ បុគ្គលបានស្តាប់បានរៀនចេះច្រើន សីល្បៈចម្រើនឆ្លៀវឈ្លាសវាងវៃ វិន័យសិក្ខាវាចាប្រពៃ ទាំងបួននេះនៃមង្គលឧត្តម ។ (មង្គលសូត្រ)

៚ បុគ្គលណាមានគតិដ៏បរិសុទ្ធ បុគ្គលនោះប្រសើរផុតលើសអ្នកចេះ លើសអ្នកចេះគិតអាងខាងចំណេះ ច្រើនតែមិនផែះរបេះក្បាច់ដាច់ដួលតូង ។

៚ បុគ្គលពាលសុខបច្ចុប្បន្ន ប្រកបទុក្ខធ្ងន់អនាគត ឯពួកសប្បុរសទុក្ខប្រាកដដល់អនាគតបានឋានសួគ៌ ។

៚ បុគ្គលល្អបរិសុទ្ធស្អាតឥតហ្មង ឆ្លងតាមគន្លងពុទ្ធដំណើរប្រសើរគ្រប់ ព្រមទាំងការចរិយាល្អលើសលុប កម្រឃើញមានក្នុងភពលោកយើងនេះ ។

៚ បុណ្យបាបតាក់តែង សង្ខារចាត់ចែង តាមភាពកិរិយា កើតមកខ្វាក់ខ្វិន ឈឺជាធម្មតា គឺគូរសង្ខារ តាក់តែងបុណ្យបាប ។

៚ បុណ្យអាចជួយឧត្តមប្រាណ នាំយើងឱ្យបានស្ថានសុខា នៅពេលមច្ចុផ្តាច់ជីវ៉ារួចនាំសង្ខារថ្កានសុគតិ ។

៚ បុណ្យត្រជាក់ចិត្ត ម្លប់ឈើតាមពិត ត្រជាក់អ្នកជ្រក បាបឱ្យក្តៅមនោ ចេះគួរលៃលក កុំឱ្យបាបមក ពកក្នុងហទ័យ។

៚ បុណ្យបាត់ដ្បិតបាប លាភបាត់ដ្បិតឃោរ ។

៚ បុណ្យក៏ធ្វើឈើក៏កាប់ សត្វក៏សម្លាប់ ច្បាប់ក៏កាន់ ។

៚ បុត្រល្អតាមពូជ បុត្រដែលខិលខូច មកពីមេបា សិស្សល្អព្រោះគ្រូទូន្មានមេត្តា កិច្ច

កលម្តេចម្តា មិនឱ្យមានឆ្គង ។

៙ បុប្ផាកុលាប តែងមានបែបភាព បន្លាស្រួចមុត សត្វមនុស្សភូមិភព មិនបានសុខសុទ្ធ ចៀសទុក្ខមិនផុត កុំឱ្យប្រមាថ ។

៙ បុរសអ្នកមានធនធានច្រើន មានប្រាក់ចម្រើននឹងគ្រឿងអាហារ លបលាក់របស់ងំឆ្ងាញ់ពិសា តែម្នាក់ឯងជាប្រធានវិនាស ។

៙ បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយតាំងប្រុសយ៉ាងនោះ

ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នេះ អំពើទាំងនោះនាំឱ្យវិនាស ។

៙ បុរសសោភ័ណដោយវិជ្ជា ស្រីសោភាដោយស្វាមី ចតុប្បាទល្អដោយធំឥន្ទ្រីយ៍ ព្រះមុនីល្អដោយមានរូបស្គម ។

៙ បុរសមានវ័យចាស់ហួសជ្រុលពេក ហើយមានតម្រេកដោយក្តីតណ្ហា

នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទៅជានាំឱ្យវិនាស ។ (បរាភវសូត្រ)

៙ បុរសមិនត្រេកនឹងភរិយាខ្លួន ហើយត្រូវការស្ទួននឹងស្រីសេព្យា ទ្រុស្តនឹងប្រពន្ធកូនជននានា នេះឯងហេតុជាវិនាសអន្តរាយ ។ (បរាភវសូត្រ)

៙ បុរសទុកដូចមាស ស្រីទុកដូចទង់ដែង ឬ(ស្ពាន់) ។

៙ បុរសឯណាប្រាថ្នាជាប្រុសនោះ សព្វៗជាតិលុះត្រានិព្វាន គួរវៀរគេឱ្យបានដូចជើងវៀរស្ពានភក់ផងផង ។

៙ បុរសចាស់បាននួននាងក្រមុំ ដោះពកឡើងក្បុំប៉ុនទន្លាប់ សឹងវិលតាមអំណាចនាង

នោះជាប់ ការនោះរាងថាជាហេតុអន្តរធាន ។ (បរាភវសូត្រ)

៚ បុរសទុកដូចជាដី ស្រីទុកដូចជាជី ញាតិមិត្រទុកដូចជាវារី ផលផងទុកដូចជារុក្ខា។

៚ បុរាណថាមនុស្សភ្នែកស្រលៀង គឺមនុស្សលំអៀងចាកការពិត ចិត្តកៀចវៀចវេរធ្វើទុច្ចរិត ហាមកុំដើរជិតកុំដើរចូល ។

៚ បុរាណចាយចែង សម្ដីសម្ដែង ទុកតវែងឆ្ងាយ សម្រាប់កូនចៅ ញាតិផៅទាំងឡាយ តែងប្រែអធិប្បាយ តាមចិត្តចំណង់ ។

៚ បុរាណពូជពេជ្រ បច្ចុប្បន្នរំលេច ជាថ្មរចនា យកមកពីភ្នំ សឹងដុំសិលា ដូចជាវាចាមានពីព្រេងនាយ ។

៚ បុរាណថាកុំធ្វើការគួរមុនគិត មិនពិនិត្យតាមក្បួនខ្នាតឱ្យស្ទាត់ការ

ចេះតែធ្វើតាមអំពើចិត្តប្រាថ្នា កុំស្មានការនោះល្អបរិសុទ្ធឡើយ ។

៚ បួញមាត់បត់ដុំដៃ ។ ៚ បួសដោយវត្ត ចិត្តដោយខ្លួន ។

៚ បើជំពប់ជើងគ្រាន់នឹងបិទ តែជំពប់មាត់បង់ប្រាក់ ឬ(គ្រាន់នឹងបទ) ។

៚ បើប្រុងនឹងស្រួច បាច់អីសម្រួចដូចបន្លា ។

៚ បើប្រុងដុះ បាច់អីផ្សាំ បើខ្លានឹងខាំ បាច់អីនឹងចូលព្រៃ ឬ(បើប្រុងដុះបាច់អីដាំ) ។

៚ បើប្រុងនឹងស្រួច បាច់អីសម្រួចដូចបន្លា ។

៚ បើប្រុងដុះ បាច់អីផ្សាំ បើខ្លានឹងខាំ បាច់អីនឹងចូលព្រៃ ឬ(បើប្រុងដុះបាច់អីដាំ) ។

៚ បើស្ដីឱ្យពិនិត្យ ពាក្យណាពិតសឹងចរចា ។

៚ បើបានងារសក្តិយស ចិត្តឱ្យស្មោះនឹងមហាក្សត្រ បើចង់គង់សម្បត្តិ ច្បាប់លោកថាកុំសូវចាយ ។

៚ បើចង់ធ្វើជាហោរ ឱ្យរៀនគូរលេខទំនាយ បើចង់ចេះប្រាជ្ញប្រាយ ឱ្យឧស្សាហ៍រៀនស្តាប់ច្រើន ។ (បទព្រហ្មគិត)

៚ បើបាយត្រជាក់ឱ្យតែសម្លក្តៅ បើស្រីខ្មៅឱ្យតែនៅក្មេង។

៚ បើក្រទ្រព្យក៏ក្រចុះ កុំឱ្យតែទាល់គំនិត ។

៚ បើកាចៗគេកោត បើឆោតៗឱ្យគេអាណិត ។

៚ បើចង់ចំណេញកុំខ្លាចខាត បើចង់ស្អាត់កុំខ្លាចយូរ ។

៚ បើមិនជួយចូកជួយចែវ (ទេ) កុំ(តែ) យកជើងរាទឹក ។

៚ បើឮសូរផ្គរ កុំអាលចាក់ទឹក (បំពង់) ចោល។

៚ បើស៊ីត្រង់ណា កុំជុះត្រង់នោះ ឬស៊ីត្រង់ណាកុំជុះត្រង់នោះ ។

៚ បើឆីកុំតាមឃ្លាន មើលប្រមាណគ្រប់គ្នីគ្នា ។

៚ បើនឹងរស់ឱ្យគាប់ បើនឹងងាប់ឱ្យគួរ ។

៚ បើអាក្រក់ចុះឱ្យតែល្អ បើក្រៗចុះឱ្យតែមាន ។

៚ បើម៉្វៃនឹងកាចឱ្យគេកោត បើម៉្វៃនឹងឆោតឱ្យគេអាណិត ។

៚ បើមានខឹងឈ្លោះនឹងឈ្មោះណា កុំដើរបរិហារបញ្ចោរជេរ អ្នកផងគេអៀនមិនល្អទេបើគេប្រកាន់រវល់ប្រកែក ។

៙ បើម៉ែនឹងកាចឱ្យពេញវង់ បើម៉ែនឹងល្ងង់ឱ្យផុតថា បើម៉ែនឹងប្រាជ្ញឱ្យបានការ បើម៉ែឱ្យគេថាឱ្យបានខ្នាត ។

៙ បើម៉ែនឹងចេះឱ្យគេកោត បើម៉ែនឹងឆោតឱ្យគេអាណិត បើម៉ែនឹងហ៊ានឱ្យមានចិត្ត បើម៉ែនឹងគិតឱ្យបានការ ។

៙ បើឮគេឈ្លោះកុំចង់ស្ដាប់ ក្រែងគេប្រចាប់ធ្វើសាក្សី ស័ក្ដិសិទ្ធិប្រាកដស្បថមិនថ្វី អ្នកម្ខាងចាញ់ក្ដីគេកើតក្ដៅ ។

៙ បើចេះតែរៀនឥតបើគិត ឥតយោបល់គំនិតឱ្យឃើញជ្រៅ គិតរិះឱ្យដឹងរសជាតិជៅ ទោះរៀនចេះទៅក៏ទន់ខ្សោយ ។

៙ បើធ្វើអ្វីខុស ព្យាយាមទំលុះ ឧបសគ្គគ្រប់យ៉ាង កែខ្លួនជាថ្មី កុំបីចៀសវាង ខំគិតកសាង ជាតិសាសន៍អាត្មា ។

៙ បើនឹងចង់គង់ទ្រព្យ កុំទម្លាប់សាងអកុសល ល្បិញល្បុញរៀចចាកកល ទេវតាផ្ដល់ផ្ដាច់ធនធាន ។

៙ បើគ្រោះថ្នាក់ធ្ងន់ ឧបាយដោះកុន ត្រូវឱ្យប៉ុនគ្នា កិច្ចការរាក់ជ្រៅ ខុសត្រូវម្ដេចម្ដា ដូចជម្ងឺរោគា ប្រើថ្នាំបំបាត់ ។

៙ បើខឹងកុំរំលោភ បើល្មោភឱ្យល្មមមាឌ កុំមាត់ក្រែងភ្លាត់ស្មៀត វាតហួសវង់ខុសគំនិត ។

៙ បើតបគុណស្រី ដោយក្ដីប្រណីត បានតែប្រើចិត្ត ស្និទ្ធស្នាលជាស្នេហ៍ ។

៙ បើស្រឡាញ់ណាស់ ដល់ពេលព្រាត់ប្រាស់ កើតទុក្ខធ្ងន់ក្រៃ ត្រូវគិតអនិច្ចំ ទុក្ខំរាល់

ថ្ងៃ ទើបឃើញធម៌ថ្លៃ ទុក្ខទោសស្នេហា ។

៙ បើចុះធ្វើការឱ្យអស់ចិត្ត ចាញ់ឈ្នះជាក់ពិតទើបពេញជាអង្គ ប្រុសបើជាបរាជ័យ ចាញ់ចុះ ឱ្យតែប្រឹងពុះពារគង់បានការ ។ (បរាជ័យ ចាញ់ អបរាជ័យ ឈ្នះ)

៙ បើធ្វើការណាល្អចំណាប់ ត្រូវតែចាយទ្រព្យច្រើនអនេក ដូចតសំពៅកុំស្ដាយដែក បំបែកការនោះឱ្យបានទៅ ។

៙ បើឡើងរុក្ខាឱ្យដល់ចុង បើផុងអន្លង់ឱ្យដល់បាត បើឡើងគិរីឱ្យខ្មីឃ្លាត ព្យាយាមសង្វាតកំពូលលើ ។

៙ បើការស្លាប់រស់កុំប្រាប់ស្រី បើបានជាខ្ជីៗប្រាក់ទិញ ការស្ងាត់កំបាំងកុំបញ្ចេញ បើបានជាវេញឱ្យមូលមួយ ។

៙ បើច្បាំងត្រូវតែយកឈ្នះចាញ់ បើឆ្លងអរាញ្ញឱ្យដល់វាល បើរៀនវិជ្ជាឱ្យផុតពាល ទើបអាចបណ្ដាលឱ្យគុណគាប់ ។

៙ បើដើររកគ្នា ភ្លាត់ដូចផ្កាប់ផ្ងា ត្រូវក្រោកខ្មីឃ្មាត ប្រឹងដើររត់ទៅ លុះដល់ជាអាទិទីដែលសង្វាត ទើបសម្រេចផល ។

៙ បើធ្វើកិច្ចការ ចូរគិតពិចារ ឱ្យបានមាំមួន បើបរាជ័យ ចាញ់ដៃថ្លស់ខ្លួន ត្រូវខំថៃធ្នួន ផ្នួនធ្វើឡើងទៀត ។

៙ បើមិនរៀនសូត្រមិនសិក្សា ប្រាជ្ញាក៏អាប់ចាប់មិនស្អិត បើខ្លួនមិនអាចពាលមិនស្បិត ហៅមិនអាណិតអាសូរកាយ ។

៙ បើលក់ឱ្យលក់មានរឭក បើភ្លឹកកុំធ្មេចភ្លេចក្នុងក្រៅ តែលក់ក្នុងលោកក្រោកឡើង

សៅ អ្នកប្រាជ្ញអាចហៅថីនមិទ្ធ ។

៙ បើស្ទាត់កុំស្ទាត់ឱ្យស្មើស្ទាក់ បើលាក់កុំលង់ឱ្យរលួយ បើចេះកុំចាំបាច់គេជួយ បើស្ទួយកុំស្ទង់ឱ្យផុងខ្លួន ។

៙ បើខ្លៅកុំខ្លៅឱ្យដល់ភ្លាក់ បើស្លាក់កុំស្លាក់ឱ្យដល់ស្លឹង បើស្រេកកុំស្រេកដល់ស្រវឹង បើប្រឹងកុំប្រឹងឱ្យដល់ព្រួយ ។

៙ បើខូចកុំខើចឱ្យដល់ខាត បើឆ្លាតកុំឈ្លាសហួសចំណាំ បើកាចកុំកោងបង្កកម្ម បើខាំកុំខាំតាមចិត្តខឹង ។

៙ បើហ៊ានកុំហ៊ានឱ្យហួស បើជ្រួសកុំជ្រុលដល់ជ្រែងខ្នង បើស៊ីកុំសាញឱ្យគេសង បើត្រេកកុំត្រង់ឱ្យចិត្តត្រាំ ។

៙ បើប្រាជ្ញកុំប្រាជ្ញដល់ព្រើល បើមើលកុំមើលឱ្យដល់ងាប់ បើឆ្លោយកុំឆ្លោយឱ្យដល់ធ្លាប់ បើជាប់កុំជាប់ឥតគេចង ។

៙ បើលោភព័ន្ធព័ទ្ធមាត់មិនលេច មិនល្មមនឹងគេចគួរអង់នៅ បើមុខជាមុជមិនបានជ្រៅ កុំគិតឱ្យព្រៅវាព្រួយចិត្ត ។

៙ បើឮថាមានអ្នកប្រាជ្ញច្បាស់ កបសូត្រសិល្បសាស្ត្រក្នុងទីណា អ្នកស្វែងរៀនសូត្រខំឧស្សាហ៍ យាត្រាចូលទៅទីនោះហោង ។

៙ បើមាតាហីនជាតិកើតបុត្រា បុត្រនោះមានវាចាភាសាទាប បើបិតាហីនជាតិមាត្រទុរភាព បុត្រនោះទាបកិរិយាអាក្រក់នៅ ។

៙ បើម៉ែឪហីនជាតិទាំងពីរនាក់ កូននោះអប្បលក្ខណ៍ទាំងពីរផ្លូវ ទាំងចរិយាមារយាទ

ក៏ហ្មងសៅ តាមគន្លងម៉ែឪផ្លូវដូចគ្នា ។

៙ បើមាតាប្រសើរកើតបុត្រា បុត្រនោះមានភាសាពាក្យពីរោះ បើបិតាប្រសើរឥតហ្មង មោះ ឯបុត្រនោះប្រកបកិរិយាពិត ។

៙ បើម៉ែឪឧត្តមទាំងពីរវង្ស កូននោះប្រកបទ្រង់អ្នកសុចរិត ទាំងភាសាកិរិយាភាពជា បណ្ឌិត បានជាមិត្រសប្បុរសក្នុងលោកិយ ។

៙ បើខឹងដូចម្ដេចក្ដី ប្រុសស្មារតីកុំឱ្យឆ្លោយ ខឹងនោះនឹងខុសក្រោយ ខឹងនោះឱ្យមាន ទោសា ។

៙ បើខឹងឱ្យខំអត់ បើខ្សត់ឱ្យខំរក ។

៙ បើសត្វមែនទើបឱ្យឈ្មោះថាសត្វបាន ចុះបើស្មានតែក្នុងចិត្តឥតឃើញឡើយ ម្ដេចក៏ថាជាក់ជាសត្វប្រាកដហើយ ហ៊ានទាំងឆ្លើយបំពានត្រោកយកតែឈ្នះ ។

៙ បើប្រាកដពិតគិតឃើញផ្លូវតែមួយទេ មិនវេះវេរទៅរកផ្លូវដទៃតែ ប្រាជ្ញស្មើរល្វើរល្វឹត ល្វល់វល់មិនវៃ មិនស្គាល់ន័យការខុសត្រូវឃើញផ្លូវច្រើន ។

៙ បើយើងចង់ឱ្យគេសុខឱ្យគេល្អ ហេតុម្ដេចក៏គេថាយើងមនុស្សអាក្រក់

ចុះបើយើងនៅស្ងៀមកុំស្លើតស្លក់ តើគេថាយើងអាក្រក់ដូចម្ដេចកើត ។

៙ បើពួកពាលឬសត្រូវពាលបង្អាប់ ថ្លែងសាសព្ទប្រាប់ព្រៀងលានផងដទៃ

ពាក្យសំអប់នោះត្រឡប់ជាមានន័យ ចូរកុំភ័យចូរកុំកិតគិតបារម្ភ ។

៙ បើប្រាថ្នាក្នុងការសុខចម្រើន ត្រូវក្រវើនយកវិជ្ជាមកប្រើការ ទើបសុខសាន្តបាន

ចម្រើនដូចប្រាថ្នា កុំស្មានថាការចុំថ្កើងកើតឡើងឯង ។

៙ បើគិតនឹងប្រាថ្នាការគ្រប់យ៉ាង ចូរកុំអាងអ្នកចំណេះចេះវិជ្ជា ត្រូវអាងមនុស្សមានបំណងប៉ងដូចគ្នា ទុកជាគ្មានចេះវិជ្ជាអ្វីក៏ដោយ ។

៙ បើមានចិត្តគិតសំអប់ស្អប់ជនណា ត្រូវមានការចង់ដឹងខុសកំហុសផង បើមិនឃើញមានកំហុសខុសអ្វីម្ដង គួរកុំចងចិត្តសំអប់ស្អប់គ្នាថ្វី ។

៙ បើគេស្អប់យើងយកស្អប់ទៅតបស្អប់ កាលណាចង់ស្ងប់ស្ងៀមស្ងាត់បាត់រំខាន ចុះបើយើងយកស្រឡាញ់តបវិញថ្កាន តើយើងបានសុខសាន្តកាយសប្បាយទេ?

៙ បើចេះធ្វើអំពើអ្វីប្រាកដពិត នឹងបានផលតាមប្រព្រឹត្តគិតកសាង កុំបាច់ល្បងផ្សងរកព្រេងរកសំណាង មុខជាបានផលតាមយ៉ាងដែលប្រព្រឹត្ត ។

៙ បើធ្វើខុសកំហុសអ្វីស្ដីផ្ដេសផ្ដាស ត្រូវប្រកាសប្រាប់ញាតិមិត្រកុំគិតលាក់ ទើបកំហុសនោះនឹងបាត់ស្ងាត់ផ្សៀងជាក់ ហើយខ្លួនអ្នកនឹងបានល្អតទៅមុខ ។

៙ បើកត់ហើយមិនពិនិត្យគិតសិក្សា នោះគេថាមិនផេះចេះដឹងដែរ បើចេះហើយបើដឹងហើយក៏នៅតែ មិនគិតកែធ្វើតាមចេះក៏កើត ។

៙ បើអ្នកថានឹងធ្វើការនៅពេលនេះ ហើយអ្នករិះគិតពន្យាទៅគ្រាក្រោយ មុខជាគ្មានពេលនឹងបើកឱកាសឱ្យ តែបណ្ដោយការនោះណាមេម៉ាយហើយ ។

៙ បើមានចិត្តស្ថិតក្នុងការក្លៀវក្លាហាន ត្រូវធ្វើប្រាណឱ្យបានរាបសុភាពផង កុំព្រហើនភ្លើនឥតគួរមោះមួហ្មង កុំកន្លងឱ្យខុសច្បាប់សម្រាប់រដ្ឋ ។

៙ បើគិតជួយលើកស្ទួយជាតិឬញាតិមិត្រ តែមិនដឹងកិច្ចដែលគិតជួយយ៉ាងណា នោះ

នឹងត្រូវពាក្យតំនៀលគេដៀលថា ចេញវាចាដូចសត្វក្អែកស្រែកឡូវៗ ។

៙ បើមិនធ្វើគុណគេក៏ហើយចុះ កុំឱ្យតែឱ្យទោសកំហុសទៅគេថ្វី បើមិនព្រួយជួយចូកចែវក៏វាហី កុំតែស្ទីបន្ទោសទៀតឆ្លៀតរករឿង ។

៙ បើប្រកបដោយគំនិតស្មោះស្មាន ត្រូវឱ្យបានប្រកបដោយបញ្ញាផង ទើបធ្វើការម្នាក់ឯងកើតឆើតឥតហ្មង សមតាមប៉ងបំណងការប្រាថ្នាហើយ ។

៙ បើចេះពេកបើដឹងពេកកុំបានដែរ គេនៅតែមានឈ្មោនីសរិះគន់គ្រប់ ម្ដេចចិត្តអាក្រក់ម្ល៉េះមនុស្សក្នុងភព បើតែម្លឹងនឹងរកម្លប់ជ្រកពុំបាន ។

៙ បើបុគ្គលឃើញវាសនាជាក់ មិនត្រូវទំលាក់ព្យាយាមឡើយ ដូចយើងបានល្ងនៅមុខហើយ យើងកន្ដើយប្រេងម្ដេចបាន ។

៙ បើកក្ដោងទាន់ត្រូវខ្យល់ ។

៙ បើមិត្រមិនល្អ កុំយកជាមិត្រ ។

៙ បោះសន្ទូចរំលងភ្នំ ។

៙ បំណាច់នឹងចេះឱ្យគេកោត បំណាច់នឹងឆោតឱ្យគេអាណិត ។

៙បំណាច់នឹងបាប ឱ្យឆ្អាបមាត់ ។

៙ បំណាច់នឹងខូចឱ្យបានការ បំណាច់នឹងគេថាសើមមាត់ ។

៙ បម្រើឪពុកម្ដាយ គេនៅឆ្ងាយគេច្រើនគាប់ អ្នកណាបម្រើខ្ជាប់ធ្លាប់តែខុសពុំដែលត្រូវ ។

៙ បុប្ផាវិសជ្ជនា ដេញដោលកាន់គ្នា នាំកើតគំនិត បង្កើតពន្លឺ បំភ្លឺផ្លូវចិត្ត ចម្រើនចរិត ដោយសាបុប្ផា ។

៙ ប៉ុនក្រចក ធ្លូកជាធំ ។

៙ ប៉ុយគរសំឡីជាជាតិស្រាយ មនុស្សពាលក្លៀវក្លាស្រាលលើសក្រៃ មនុស្សបង់ឱវាទចាស់ប៉ូប៉ៃ ស្រាលលើសដទៃក្រៃនានា ។

៙ មនុស្សមានប្រមាថនៅសព្វកាល លោកចាត់ហៅស្រាលក្នុងសាសនា ប្រមាថមាននៅលើអ្នកណា អ្នកនោះចុះត្រាមច្នុរាជ។

៙ ប៉ះបានការស្អាតខូចខាតទៅ នោះត្រូវគិតកែលៃគ្មាន់គ្នេរ មិនដឹងកលកិច្ចល្បិចជើងភេល រកពេលបំពេញឡើងវិញពិត ។

៙ ប៉ះកល់សត្វគោដំបៅខ្នង ក្អែកហើររំលងច្រើនស្ងប់ស្ងៃញ បោលត្រង់កន្ទុយដោយគិតក្រែង រអែងក្អែកចោះដំបៅខ្លួន ។

៙ ប្រក្រតីស្រីៗចិត្តមិនដឹង ច្រើនឆាប់ខេរខឹងតែឆាប់ជា ប្រុសណាឆាប់ខឹងនឹងប៉ះពាឈ្លោះទាស់ទែងគ្នាជាមិនខាន ។

៙ ប្រញាប់ហួសពេកច្រើនខូចការ ចង់សម្រេចប្រាថ្នាត្រូវសន្សឹម កុំចង់បំបោលឱ្យហួសនឹង បាត់ខ្លឹមបានស្រាយនឹងស្ដាយក្រោយ ។

៙ ប្រទេសមួយស្ដេចពីរមិនភិរម្យ វត្តមិនឧត្តមសង្ឃរាជពីរ ព្រះពុទ្ធទ្វេអង្គហោចសាមគ្គី អាទិត្យពីរក្ដៅនៅមិនបាន ។

៙ ប្រទេសអាក្រក់មិត្រកោងត្រកូលកាច ញាតិកំណាចប្រពន្ធគំនុំខ្ញុំរឹងរូស គប្បីចៀស

ឱ្យឆ្ងាយចេញឱ្យហួស ឬទៅបួសដើរធុតង្គទៅឱ្យបាត់ ។

៙ ប្រព្រឹត្តសុចរិត កុសលក្រមក្រឹត្យ ឧត្តមថ្លៃថ្លា អ្នកផងសរសើរ មិនតិះដៀលថា ធ្វើល្អទេវតា ឱ្យពរជោគជ័យ ។ តែងបានសុខស្រួលស្រស់បស់ប្រិមប្រិយ កេរ្តិ៍ឈ្មោះក៏ល្បីក្រអូបប្រាសខ្យល់ ។

៙ ប្រម៉ង់ខ្លែងចោរប្លន់ ចាប់កូនមាន់កណ្តាលស្រុក មេមាន់យំរកអុក ហែកកញ្ចុករសកូនឯង ។

៙ ប្រមាណជម្រៅទឹកពិនិត្យ ឱ្យដកព្រលិតវាស់វែងវា ប្រមាណត្រកូលអ្នកកាចជាឱ្យមើលកិរិយាអាការចេញ ។

៙ ប្រមាណអ្នកឈ្លាសវៃប្រាជ្ញប្រាយ មើលកាលនិយាយពោលមកមិញ ប្រមាណប្រថពីជីដីដេញ មើលស្មៅខៀវចេញអាក្រក់ល្អ ។

៙ ប្រមាថចាស់អាយុខ្លី ។

៙ ប្រមាថម្តាយរំលាយព្រះ ។

៙ ប្រមាណទឹកពិនិត្យ ដកព្រលិតវាស់វែងវា ប្រមាណមនុស្សកាចជាមើលកិរិយាអាការចេញ ។

៙ ប្រយ័ត្នជនណាគេមានល្បិច កែគេចលើកទោសទម្លាក់លើ ខ្លួនគេស្អាតបានល្អប្រសើរ អាក្រក់ធ្លាក់ទើរលើរូបខ្លួន ។

៙ ប្រយ័ត្នពោលពាក្យ ក្រែងព្រួយលំបាក ដោយសារសម្តី គិតរួចសឹមថ្លែង សម្តែងវចីឥតរឿងអប្រិយ ពិភាល់ដល់ប្រាណ ។

- ប្រយោជន៍ជាតិដូងឆ្មោត មនុស្សណាឆោតគិតមិនដឹង គេកាប់មិនចេះខឹង ប្រឹងតែលូតលាស់ជាថ្មី ។

- ប្រសិនកូនសិស្សឬកូនកាច ពុំខ្លាចគ្រូមាតាបិតា ទៅខ្លាចឯអ្នកក្រៅមេបា ហៅខ្លាចអាចម៍ខ្លាៗមិនខ្លាច ។

- ប្រហែលបាត់ប្រយ័ត្នគង់ គួរយើងទ្រទ្រង់ដោយប្រាជ្ញាចាំ ហើយត្រូវនាំគ្នាឧស្សាហ៍ប្រយ័ត្នកិរិយាកុំភ្លាត់ភ្លេច ។

- ប្រហែសតែងតែបាត់ ប្រុងប្រយ័ត្នតែងតែនៅ គិតសព្វគ្រប់ដោយផ្លូវ សូវទ្រាំនឿយកុំទ្រាំក្រ ។

- ប្រពន្ធពីរ គោបី ដំរីមួយ នាំឱ្យព្រួយចិត្ត។

- ប្រពន្ធច្រើនចាញ់ប្តី ពាក្យច្រើនភូតចាញ់អាត្មា ។

- ប្រមាថសង្ឃរំលាយព្រះ ។

- ប្រមាថព្រៀងលាន តែងមានក្តីទុក្ខ ។

- ប្រមាត់ដី អួតចង់ឡើងទ្រង់ ។

- ប្រហែសបាត់ ប្រយ័ត្នគង់ ឬ(ប្រហែសវាបាត់ ប្រយ័ត្នវាគង់) ។

- ប្រាក់ក៏បង់ថង់ក៏ដាច គួចក៏កាចកូនក៏កើត ។

- ប្រាក់ចាយគង់អស់ ពោលពាក្យសប្បុរស ចាយក្រពន់ពេក បើចាយខាងល្បែង ក្រមានអនេក វិទ្យាចេះប្លែក ចាយចែករឹតពេញ ។

៙ ប្រាក់មានលើកឱ្យគេខ្ចីទៅ ចំណេះចេះនៅក្នុងក្បួន ប្រពន្ធនៅឆ្ងាយពីខ្លួន ដល់ជួនត្រូវការរអាចិត្ត ។

៙ ប្រាជ្ញពុំស្មើពុត បម្រើលំអុត ពុំស្មើក្តីគាប់ មានគុណពុំស្មើ អ្នកមានបុណ្យភ័ព្វ ស្វែងរករៀនច្បាប់ ពុំស្មើចិត្តជា ។

៙ ប្រាជ្ញពុំស្មើប្រប ស្លឹកត្រចៀកខ្លប មិនស្មើឡេមឡឺម ។

៙ ប្រាជ្ញលិចលង់ព្រោះរួមដោយសិស្សពាល ឬប្រពន្ធចណ្ឌាលពាលសាមាន្យ ឬគបដោយអសប្បុរសជាសន្តាន នាំឱ្យអន្តរធានប្រាជ្ញព្រើលអីយ ។

៙ ប្រាជ្ញឯណានៅរួមដោយសិស្សកាច ឬប្រពន្ធកំណាចចោរមាយា ឬយោគដោយអសប្បុរសជាតិពាលា ទោះប្រាជ្ញជាក៏គង់លង់មិនខាន ។

៙ ប្រាជ្ញច្បាស់មិនប្រកាសទ្រព្យរាយ នឹងស្តេចក្តៅក្រហាយក្នុងចិន្តា ទាំងការទុច្ចរិតក្នុងគ្រឹហា ឬមាយាបញ្ឆោតមើលងាយផង ។

៙ ប្រាជ្ញធ្លាក់រណ្តៅ ខ្លៅឡើងឋានសួគ៌ ឬ (ខ្លៅឡើងសួគ៌) ។

៙ ប្រាជ្ញអាងប្រាជ្ញា រមាសអាងបន្លា ខ្លាអាងព្រៃ ដំរីអាងរនាម ត្រីអាងទឹក ទាហានអាងសឹក ប្រមឹកអាងពែង ។

៙ ប្រាជ្ញបុណ្យផងកើតដោយប្រតិបត្តិ ។

៙ ប្រាជ្ញខំធ្វើពាលខំរើបំផ្លាញបាត់ ប្រាជ្ញកំចាត់ពាលប្រមូលចូលជុំជិត ប្រាជ្ញនឹងពាលមិនដែលរាលមកជាមិត្រ ទុកជាគិតឱ្យផ្សំផ្សារតក៏មិនជាប់ ។

៙ ប្រាជ្ញមែនហើយតែនៅឡើយមិនទាន់ប្រាជ្ញ ខ្វះអង់អាចខ្លាចខ្លាសអៀនគ្មានក្លាហាន

ទុកជាចេះចំណេះជ្រៅទៅប៉ុន្មាន ក៏ឥតបានកេរ្តិ៍ឈ្មោះល្បីអ្វីនឹងគេ ។

៙ ប្រាជ្ញមែនហើយតែនៅឡើយអំពើពាល ចេះវាល់វាលនៅតែលង់លូង់ខ្លះដែរ កុំអាងប្រាជ្ញអាងចំណេះចេះពូកែ ក៏គង់មានកំហុសខុសនៅឡើយ ។

៙ ប្រាថ្នាអ្វីក្នុងលោកិយសុទ្ធតែទុក្ខ សុទ្ធតែទោសអបាយមុខជាប្រធាន កុំបណ្តោយឱ្យតម្រេកដែលស្រេកឃ្លាន ចូលទន្ទ្រានជាន់ញាំញីឥន្ទ្រីយ៍ពេក ។

៙ ប្រាថ្នាទ្រព្យគប្បីជួយសព្វនាន ប្រាថ្នាវិជ្ជាគប្បីគប់បណ្ឌិតជាតិ ប្រាថ្នាកូនគប់មេសាវស្អាតៗ ប្រាថ្នារាជមោត្យផ្គាប់ចិត្តម្ចាស់ ។

៙ ប្រាសពីដងវែក ទៅផ្អែកលើពូក ។

៙ ប្រុសរើសភរិយា រូបខ្មៅភ្លឺថ្លា ចិន្តាមិនត្រូវ មួយសល្អដែរ ទាស់តែល្ងង់ខ្លៅ ចង់ដើរច្រើនផ្លូវ ជួបភ្នែកស្រលៀង ។

៙ ស្រឡាញ់នារីច្រើនមិនបានការ ចំណីអាហារច្រើនមុខលំបាកលូកចិត្ត សង្ស័យថ្នេមិនជាក់ក្តាន់ឬជ្រូក រកកលលូកចុះជ្រុះសោះទទេ ។

៙ សំពត់អាវហូលព្រែគំនូរ គិតគូររកឱ្យតាមពេញចិត្ត ។

៙ ប្រុសៗកម្លោះមានកម្លាំង នៅតាំងក្នុងវ័យក្មេងស្រួលបួល បើបានមេម៉ាយយ៉ាងទំនួល ក៏គួរទទួលជាភរិយា ឬ(នៅតាំង) ។

៙ បើត្រាប់សត្វក្ងោក កុំបីត្រាប់ពុតទន្សាយ ។

៙ បើត្រាប់ពុតកង់ ឬ(កង់ត្រាចកង់ធ្នង់) ។

៙ ប្រើត្រាប់កុកសាប់ កុំបីត្រាប់កុសល ។

៙ ប្រើអន្ទង់ឱ្យចំហុងភក់ ។

៙ ប្រើត្រាប់ឫស្សី កុំបីត្រាប់ស្នាយកន្ទ្រាញ ។

៙ ប្រើត្រាប់ឯត្រាជូ កុំបង់ផ្លូវដោយតម្រាស់ ។

៙ ប្រើត្រាប់អ្នកប្រាជ្ញប្រាយ ប្រើត្រាប់ខ្លៅសាមាន្យ ។

៙ ប្រើឱនដាក់គ្រាប់ ប្រើងើបវាស្កក ។

៙ បើត្រាប់ឯតាំងយូ ក្រងគ្រូពុំគួរគ្រាប់ ។

៙ ប្រើទៅជាត្បូងចិញ្ចៀន ក្រវិចក្រវៀនជាមៀនកាំបិត ។

៙ ប្រើគេប្រើបុត្រា ។

៙ ប្រើខ្ញុំមើលមុខវា ទោះកាចជាមើលឱ្យស្ដែង ។

៙ ប្រើបាវមើលចិត្តវា កុំពុះពាត់តប្រណី សត្វបម្រើសោតខ្មី ត្រូវមេត្រីឱ្យស្មោះទឹក ។

៙ ប្រើស្រែចេះស្រែ រករៀនកែប្រែ ចាំស្ទាត់ចំណោះ ហាត់ចិត្តស្គាល់ចិត្ត ហាត់សេះស្គាល់សេះ ដំដែកយកច្រែះ ចង់ចេះខំដាំ ។

៙ ប្រៀបដូចទន្សាយ ប្រាជ្ញាឆ្ងាយ គង់ចាញ់ខ្យង ។

៙ ប្រះដេកឆាប់លក់ ដ្បិតឥតបើគិត ។

★ ★ ★

# ផ

៙ ផល្លាវុក្ខាខ្ចីចង់ទុំ ឥតបុណ្យសន្សំចង់បានស័ក្តិ ឥតនិស្ស័យអប់រំចង់ស្តេចចក្រ ឥតទ្រព្យមាសប្រាក់ចង់សេដ្ឋី ។

៙ ផាយត្រង់កែង ឬ(ត្រង់កន្ទុយ) ។

៙ ផាសជើង ឬ(ផាសក្រញាំ) ។

៙ ផឹកស្រាក្លាសម្ដី ។

៙ ផោមក្នុងទឹកម្ដេចគង់ស្អុយ ។

៙ ផ្កាឧប្បលក្រអូបឯង គ្មានចាប់ចែងចាក់ទឹកអប់ បុលបុត្រចេះដឹងសព្វ គ្មានចាំបាច់គេតឿនក្រើន ។

៙ ផ្ដាប់គ្រូមិនសូវមានគ្រោះខ្លួន បើផ្ដាប់ឱ្យមួនកុំសង្ស័យ ខុសពីរបីដងលោកអភ័យ បើមានចំណីទុកឱ្យស៊ី ។

៙ ផ្ដាប់ស្ដេចតោងតាមព្រះទយា ផ្ដាប់រាស្ត្រដូចគ្នាតោងមើលចិត្ត ។

៙ ផ្ដាប់អ្នកលោភដោយអាមិសគ្រឿងគួរសម ផ្ដាប់អ្នកថ្កើងដោយប្រណម្យដៃប្រណិត ផ្ដាប់អ្នកមោហ៍ដោយប្រព្រឹត្តទៅតាមចិត្ត ផ្ដាប់បណ្ឌិតដោយពោលពាក្យសត្យា ។

៙ ផ្ចាញ់អ្នកក្រោធដោយក្ដីមិនក្រោធា ផ្ចាញ់អសប្បុរសពាលាដោយក្ដីល្អ

ផ្ចាញ់អ្នកកំណាញ់ដោយទេយ្យធម៌ ផ្ចាញ់អ្នកភូតភរដោយពោលពាក្យពិត ។

៙ ផ្ទុករទេះតាមចំណុះ ។ ៙ ផ្ទះបាក់បែកឆាប់ទល់ទ្រ ។

៙ ផ្ទះធំស្រណុកដ្បិតភរិយាជា ។

៙ ផ្ទះជាគ្រូផ្ទះ ជាងមានមានះ ធ្វើដោយសង្វាត ធ្វើផ្ទះច្រើនដង ផ្ទះប្រាប់ទបបាទ ធ្វើផ្ទះក្រោយស្អាត សមល្អជាងមុន ។

៙ ផ្ទះឥតកូនសូន្យស្ងាត់ ដែនឥតក្សត្រសូន្យអាជ្ញា មាត់ឥតសិល្បសូន្យវាចា ខ្យត់កំព្រា សូន្យទាំងអស់ ។

៙ ផ្ទះឯណាឥតក្មេងផ្ទះនោះស្ងាត់ ដែនដែលឥតក្សត្រសូន្យអាជ្ញា មាត់អ្នកគិតសិល្ប សាស្ត្រសូន្យចរចា ទុគ៌តទ្រព្យាសូន្យទាំងអស់ ។

៙ ផ្ទះភ្លើងមានបី អំពើពុតស្រី ខឹងឥតប្រមាណ កូនកាចចចេស កុំយកទូន្មាន ខ្ញុំកាច ជាប្រាណ ភៀសពុំឱ្យប្រើ ។

៙ ផ្លូវកាយវាចាចិត្ត គួរខំគិតខាតរាល់ថ្ងៃ ផ្ទៀងផ្ទឹមតាមធម៌ថ្លៃ ទើបប្រពៃពេញកូន ប្រុស ។

៙ ផ្លូវវៀចកុំបោះបង់ ផ្លូវណាត្រង់កុំដើរហោង ដើរដោយផ្លូវគន្លង តម្រាយអ្នកចាស់ បុរាណ ។

៙ ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា ឈានឈរពិចារណា ឆ្ការឱ្យស្អាតសឹមដើរ ទៅ ។

៙ ផ្លែខ្នុរណាំងទុំ សម្បកក្រៅរុំ ច្រូងច្រាងបន្លា ខាងក្នុងសឹងថ្លែប ក្រអែបពិសា ដូចអ្នក សទ្ធា ចិត្តជាសប្បុរស ។

๛ ផ្លែត្រឡាចគង់មានបណ្តូល មនុស្សទាំងមូលគង់មានចិត្ត ។

๛ ផ្លែឈើមិនដែលជ្រុះឆ្ងាយពីគល់ ។

๛ ផ្លែម្នាស់គេគោះស្គាល់ទុំខ្ចី ជាតិមនុស្សប្រុសស្រីត្រូវសាកសួរ លលូកចាប់ទាញពោលគាប់គួរ ទើបយល់ខួរក្បាលល្អអាក្រក់ ។

๛ ផ្សារកំពង់ទឹកមិនដែលស្ងាត់ ខាងការប្រាសព្រាត់ស្រេចសង្ខារ ជនទាបចម្រើនដល់មេឃា ស្រីមានភស្តាទើបសោភ័ណ ។

๛ ផ្សាក្តៅរោលរាលចិត្តយ៉ាងខ្លាំងក្នុងលោកិយ គ្មានវត្ថុអ្វីប្រៀបផ្ទឹមស្មើចិត្តប្រពន្ធដើមកាលដែលស្វាមីមានស្រីទៀតហើយស្អប់ខ្ពើមឆ្អើម ឱបចេកទាំងដើមក៏ស្លោកស្វិតដូចដុតអគ្គី ។

๛ ហេតុនោះពួកប្រុសលោកិយគប្បីគិតពិចារណា ត្រូវមានមេត្តាស្រីដែលគ្នាស្រឡាញ់ស្មើជីវិត កុំអាងខ្លួនប្រុសធ្វើព្រើលមានស្រីដល់មួយពីរ គួរគិតសម្តីក្រែងខ្លួនក្លាយជាញីពិបាកកែ។ (សុង ស៊ីវ)

๛ ផ្អកក្រឹម តម្រឹមក្តឹបស្វាយ ឬ(ក្តីអម្ពិល) ។

**អ្នកធ្វេសស្មារតី ស្លាប់គំនិតទោះបីមានជីវិតរស់នៅឡើយ ៗ**

ស្រង់ចាកសុភាសិតសម្តេចព្រះមហាសុមេធាធិបតី

សង្ឃនាយកគណៈមហានិកាយ

**(ជោតញ្ញាណោ ជ.ណ)**

# ព

៚ ពពកជាលំអនភាល័យ បុប្ផាក្នុងព្រៃលំអព្រឹក្សា រលកលំអនៃសាគរា គោរពកស្តាលំអនៃស្ត្រី ។

៚ ពងមានកុំជល់នឹងថ្ម ។

៚ ពងមាន់ក្នុងជាល ម្តេចឡើយត្រអាល ទៅពាំក្អែកវិញ ។

៚ ពងមាន់កុំផ្ញើនឹងក្អែក ។

៚ ពស់កាចអាចទ្រុស្តទោះវាខាំ ពេទ្យកែដោយថ្នាំអាចស្ងប់បាន មនុស្សកាចលើសពិសពស់សាមាន្យ កុំមានអ្វីកែបានស្ងប់ស្ងាត់ឡើយ ។

៚ ពស់មួយក្បាលច្រើនចម្រើនទាស់ ចូលមិនអស់ចេញមិនអាចសម្របគ្នា
ពស់មួយកន្ទុយច្រើនទោះបែកវ៉ា អាចសម្របស្របគ្នាចូលចេញបាន ។

៚ ពស់វែកដំបូកមួយស្រែ ពស់វែកស្រងែមួយព្យាម ពស់វែករនាមផស់ស្រួស ។

៚ ពស់ខំលេប កង្កែបខំប្រឹង ឬពស់ប្រឹងកង្កែបប្រឹង ។

៚ ពាក្យខុសកុំឱ្យស្តាប់ សេចក្តីគាប់ឱ្យរិះធ្យាន ឬ(ឱ្យគិតធ្យាន) ។

៚ ពាក្យក្រកុំអាលប្រាប់ ពាក្យឥតស័ព្យកុំអាលថ្លែង ។

៚ ពាក្យគ្រូវែងរឹង ស្រាវែងស្រវឹង ពុំដែលពិសា ។

៚ ពាក្យចាស់អង្វរ ថាបើខ្លាចក្រ បាខំធ្វើស្រែ កាប់កាយធរណី ដាំយកផ្កាផ្លែ លក់ដូរ

ជួយប្រែ មាសប្រាក់រត់ហៅ ។

៙ ឯល្បែងនានា គឺជាពូជធារ នៃទុក្ខសោកសៅ មិនដែលអ្នកលេង ធ្វើជាដង្ហៅ បាន ឈ្នះច្រើនទៅ ស្លៀកពាងក្រឡ ។ (សុង ស៊ីវ)

៙ ពាក្យអប្រិយចាញ់អាត្មា ។

៙ ពាក្យពិតវែងស្លែងពុំពីរោះថា បណ្ដិបមេបាវែងថាពុំគាប់ ឬ(បណ្ដាំមេបា) ។

៙ ពាក្យភូតស្ដាប់គួរឆ្ងល់ មានកង្វល់កុំអាលថ្លែង ពាក្យពិតកុំឱ្យថែង ពាក្យពិតស្លែងពុំគួរលាក់ ។

៙ ពាក្យច្រើនភូតចាញ់អាត្មា ។

៙ ពាក្យព្រេងលោកស្រដី ថាកុំបីចិញ្ចឹមខ្លាច ពាក្យព្រេងលោកឧបមា គិតត្រង់ណាធ្វើឱ្យបាន ។

៙ ពាក្យស្លែងកុំស្អប់ ពាក្យគាប់ឱ្យយក ។

៙ ពាក្យម្ដាយទំនាយគ្រូ ឬ(គ្រូទាយម្ដាយថា) ។

៙ ពាក្យសង្ឃពាក្យសត្យ ។

៙ ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ឬ(ប៉ុននឹងភ្នំ) ។

៙ ពាក្យលើកបញ្ចោរឬបង្អាប់ នាំឱ្យអ្នកស្ដាប់ភ័ន្តស្មារតី ជោរចើចតាមធម៌ជាលោកិយ នេះជនប្រុសស្រីគួរប្រយ័ត្ន ។

៙ ពាក្យបូរាណខ្មែរ អ្នកប្រាជ្ញាលោកកែ ឱ្យគិតប្រយោល ចោលសាច់យកឆ្អឹង ប្រឹងតែខំថ្កោល ទោសពិតឥតពោល អំពើពុតកាល ។

៙ ពាក្យចាស់លោកថា រីអ្នកចម្ការ ចិត្តរែងសើរើ រីគ្រាប់ត្រសក់ កុំយកទៅធ្វើ តែទាល់ឥតបើ ស្រេចហើយយកដាំ ។

៙ ពាក្យលេងជន្លមើលប្រាជ្ញ ពាក្យព្រេងមុសាការគេដេញ អួតខ្លួនតោងឃ្លាតពីខ្លៅចេញ ស្រឡាញ់តោងថ្នមលោមមើលចិត្ត ។

៙ ពាក្យចាស់បុរាណលោកប្រដូច ជាបោះសន្ទួចរំលេងភ្នំ គឺគិតការអ្វីចោលអ្នកធំ ទៅខំផ្គាប់ផ្គុនឯអ្នកតូច ។

៙ ពាក្យសរសើរពាក្យនិន្ទារបស់មនុស្សយើង នោះមិនទើងយកប្រមាណបានតាមមាត់ បើជាពាក្យទេវតារក្សារដ្ឋ ទើបទៀងទាត់តាមគំនូសគូសទុកឱ្យ ។

៙ ពាក្យហួសបង់មាសប្រាក់ ឡើងហួសថ្នាក់ធ្លាក់ចុះទាប ប្រាជ្ញព្រើលហួសសុភាពខ្ពស់ទាបហួសមិនបានការ ។

៙ ពារស្តុកពារស្តោ អ្នកមានប្រាជ្ញាក្រៃណានៅមានបុណ្យភ័ព្វ ។

៙ ពាលដោយពាលពិត បណ្ឌិតដោយបណ្ឌិត មិនដែលរួមគ្នាដូចសត្វចចក មូលចិត្តគ្នាវា មិនចង់មិត្រគ្នា នឹងសត្វដទៃ ឬ(មិត្រភ្វា) ។

៙ ពាលនៅផងបណ្ឌិត អស់ជីវិតល្ងង់អនេក មិនដឹងធម៌អាថ៌ឯក ប្រៀបដូចវែកមិនដឹងរស ។

៙ ពាលនាំគ្នាគប់ឱ្យខាតបង់ បណ្ឌិតនាំត្រង់ផ្លូវសុចរិត ឱ្យបានប្រយោជន៍ប្រពៃពិត

គួរគប់បណ្ឌិតកុំគប់ពាល ។ (ចាប ពិន)

៚ ពាលខ្លៅចូលនៅផងបណ្ឌិត ត្រាអស់ជីវិតលង់អនេក មិនដឹងរសធម៌អាថ៌ជាឯក ដូចវែងមិនដឹងរសសម្ល ។

៚ ពាលឃ្លាតជាតិក្លាយជាបណ្ឌិត បីដូចវិចិត្រដោយកែវមុនី លាក់យសសរសើរសុខពេញទី វិធីនេះត្រជាក់ប្រាណ ។

៚ ពាលស្គាល់ខ្លួនឯងថាពាលពិត បណ្ឌិតពោលថាជាប្រាជ្ញបាន បើពាលអួតគុណដែលមិនមាន កុំស្មានថារួចខ្លួនពីពាល ។

៚ ពាលឯណាដឹងខ្លួនជាពាលពិត ពាលនោះហៅបណ្ឌិតដោយនុយោគ ពាលឯណាកាន់ខ្លួនថាជាប្រាជ្ញព្រោក ពាលនោះឯងលោកហៅថាពាលោ ។

៚ ពាលឯណាឥតបញ្ញាក្លាហានខ្លាំង បានទ្រព្យដោយកម្លាំងក្លាហានគេ ពាលជននោះលុះទម្លាយកាយក៏រេ ទៅកើតក្នុងនិរយេនរកជ្រៅ ។

៚ ពិបាកឱ្យគន់គិត រកគំនិតគិតឱ្យដល់ ។

៚ ពិសាក្រៃណានឹងឃ្លាន អាក្រក់ប៉ុន្មានក្រៃណានឹងចិត្ត ឬថា(អាក្រក់ក្រៃណានឹងស្រឡាញ់ ឆ្ងាញ់ក្រៃណានឹងឃ្លាន) ។

៚ ពុតគ្រូកុំត្រាប់ ច្បាប់គ្រូឱ្យយក ។

៚ ពុទ្ធរូបល្អក៏ដោយសារស្នាដៃជាង រចនារាងព្រាងពុម្ពសិតឥតមានឆ្គង

ការងារល្អឬអាក្រក់តាមគន្លង ហេតុដើមទងពីអ្នកធ្វើអំពើនោះ ។

ពូកែឯង ឱ្យក្រែងពូកែគេ ។

ពូជសិស្សគ្រូបី ពូជស្ត្រីប្តីលែង ពូជគោជ្រលែង ពូជឆ្កែបង់ម្ចាស់ ។

ពូជខ្លាចមិនដែលចាកចោលព្រៃ មច្ឆាជលស័យមិនចោលទឹក ពូជចោរមិនចោលចោរកម្មិក ជនពាលប្រមឹកមិនចោលខូច ។

ពូជទានៅតែទា ពូជមាន់នៅតែមាន់ ។

ពូជហង្សមិនចោលស្រះឈូក មិនចោលប្រមាថជ្រូកសូករៈ ពូជទាមិនចោលការថោកជាក់ ពូជលាមកៈមិនចោលទុច្ចរិត ។

ពូជទាមិនដែលឡើងទ្រនំ ពូជសត្វព្រៃភ្នំនៅស្រុក ពូជបណ្ឌិតមិនខ្វល់ក្នុងផ្លូវទុក្ខ ពូជសត្វកុកមិនដែលបោះបង់បឹង។

ពូជសត្វពានដែលជាប់តើ សើរើមិនរួចស្ដួចជើងដៃ ជាប់ត្រឹងស្លឹងភ្នែកស្រែករាល់ថ្ងៃ ចិត្តចង្រៃជាប់កាមក៏ដូចគ្នា ។

ពួកមនុស្សមុយៗបែបមឹសៗ អង្គុយភ្លឹសៗទន់ពភ្លៀច សម្ដីល្អកល្អើនល្អល្អៀចៗ តែងមានចិត្តកៀចកលឧបាយ ។

ពួកជនណារៀនចិត្តសើៗ ដល់ដប់មិនស្មើប្រសប់មួយ អ្នកចេះគួររកប្រសប់ជួយ លើកស្ទួយចំណេះឱ្យគ្រាន់បើ ឬ(ចេះសើៗ) ។

ពួកកូនគ្មានវិជ្ជានិងច្បាប់ កូននោះដូចស្លាប់ឥតប្រយោជន៍ ដូចភ្នែកដែលខ្វាក់គួរអសោច៍ នាំឱ្យហិនហោចឈឺតែម្យ៉ាង ។

ពួកអ្នកដែលនៅមិនទាន់មាន តែនឹកស្រេកឃ្លានចង់បានច្រើន ពួកអ្នកដែលមាន

សុខលើសកើន រឹតចង់បានច្រើនណាស់ទៅទៀត។

៙ ពួកមនុស្សអ្នកតូចល្ងង់ខ្លៅ តែងទៅក្អេងក្អាងគិតវាទអាទិ៍ ចង់បានយសស័ក្ដិធំហួសមាឌ និងខាតកម្លាំងនាំរំខាន ។

៙ ពួកចេកអំពៅ កុំយកទៅធ្វើ លើសត្វដំរី អស់ស្រូវពូជផង កុំធ្វើកុដុម្ពិក៏ កំព្រយផ្ដែញ្ញី កុំយកព្រ័ក្រធ្វើ ។

៙ ពួកអ្នកជាងស្មិត កុំយកសំរិទ្ធ ទៅធ្វើបញ្ចាំ ប្រមឹកស្រាសោត កុំយកស្រាផ្ដាំ អ្នកលោភស៊ីថ្នាំ កុំយកថ្នាំធ្វើ។

៙ ពួកជឿខ្មាសបាបខ្លាចបាបស្ដាប់ច្រើន សង្វាតចម្រើនសតិបញ្ញា ប្រកបដោយធម៌ប្រាំពីរប្រការ នេះលោកហៅថាបណ្ឌិតពិតមែន ។

៙ ពួកខ្ជិលមិនរៀន គំនិតអៀនប្រៀន មិនខំសង្វាត ដូចសត្វពារនរ មិនស្គាល់មណីជាតិ ខិលខូចដល់ខ្មាត បោះលេងជាល្បែង ។

៙ ពួកចាស់ឯងឆ្លោយគំនិត ប្រព្រឹត្តការល្បែងទាស់ចំណាប់ ជាមួយក្មេងៗរមែងអាប់យកស័ក្ដិខ្ពស់ផ្កាប់ក្រឡាប់ថោក ។

៙ ពួនតែមុខដូចពង្រូល ឬ(លាក់តែមុខដូចពង្រូល) ។

៙ ពួនតែមុខ គូថនៅកណ្ដាលវាល ។

៙ ពេជ្រកើតពីថ្ម តែងទំពាស៊ីនូវថ្មវិញ ។

៙ ពេទ្យគោលូន មេមត់ស្លាប់កូន សុភាចាញ់ក្ដី ក្រពើលង់ទឹក ម្រឹគជាប់ព្រៃ...។

៙ ពេលទ្រព្យបុណ្យស័ក្តិនឹងស្រី ប្រែខុសប្រក្រតីដូចសុរិយា មិនដែលនៅទៀងទិសបូព៌ា នេះជាធម្មតាតាក់តែងឡើង ។

៙ ពេលណាដែលធ្វើការប៉ុនភ្នំ ត្រូវគិតខិតខំដោយមធ្យ័ត កុំគិតឯស្គរកំបែកមាត់ បំភ្លាត់ចោលការមានប្រយោជន៍ ។

៙ ពោលច្រើនស្រេចស្រី ខុសច្រើនស្រដី អ្នកខំធ្វើការ គិតច្រើនៗពាស ប្រាជ្ញចាញ់ពាលា កូនច្រើនមេបា ប្រាជ្ញាសោភ័ណ ។

៙ ពោលក៏ល្អធ្វើក៏ល្អគិតក៏ត្រូវ សំដៅផ្លូវសន្តិសុខសង្ខារ ឯវិថីកាឡីមិច្ឆាចារ សាងតែការបុណ្យទានគ្មានខ្មោះខ្សូរ ។

៙ ពោះជាទេវទត្ត មាត់ជាទេវតា ឬ(ចិត្តជាទេវទត្ត...) ។

៙ ពោះគោពោះក្របី ។

៙ ព្នៅនៅថ្នក់ តម្កក់នៅដៃ ។

៙ ព្យាយាមដុតបាបនឹងប្រព្រឹត្តល្អ នឹងបានឃើញធម៌អរិយសច្ចា ធ្វើព្រះនិព្វានច្បាស់ក្នុងអាត្មា ទាំងបួននេះជាមង្គលឧត្តម ។ (មង្គលសូត្រ)

៙ ព្រលិតខ្មៅក្រហមគ្រោតក្រៅ បកសម្បកទៅប្រែជាស ផ្លែត្នោតស្រអាប់សាច់ក្នុងល្អ មានទឹកក្នុងក៏ជាតិផ្អែមរស ឬ(ទឹកក្នុងក៏) ។

៙ ព្រឹក្សាឥតបុប្ផាមិនសោភ័ណ នគរខេត្តខណ្ឌឥតនាទី គ្រឹហាឥតក្មេងមិនសោភី វារីឥតមច្ឆាមិនសោភា ។

៙ ព្រៃឈើជាម្លប់ត្រសុំសាខា ម្តេចឡើយប្រែជាក្តៅជ្រកពុំបាន ។

៙ ព្រៃគ្មានសត្វជិត ប្រទេសឥតបណ្ឌិត ទ្វីបឥតសាសនា គ្រឹហាឥតបុត្រ ស្រុកគ្មានជាតិជា មេឃឥតចន្ទ្រា សូន្យចក្រវាឡ ។

៙ ព្រះពុទ្ធសាសន៍ជាប្រទីបធំ ភ្លឺសាយត្រសុំក្នុងភារា ធ្វើសត្វឱ្យខ្វាត់ពីអវិជ្ជា លោកអ្នករាល់គ្នាគប្បីកាន់ ។

៙ ព្រះកាយកេណ្ឌកម្មកាច មិនកោតខ្លាចអ្នកមានក្រ បើសីលបរិសុទ្ធល្អទើបអង្វរព្រះកាលបាន ។

៙ ព្រះចន្ទជាគ្រឿងស្អាង ផ្កាយជិតខាងនិងផ្កាឆ្ងាយ ប្ដីជាគ្រឿងស្អាងកាយ ស្ត្រីទាំងឡាយជាតិលោកិយ ។

៙ ព្រះចន្ទជាទីលម្អពួកផ្កាយ ស្វាមីឆើតឆាយនៃពួកនារី ស្ដេចជាលម្អរបស់ប្រឹថពី វិជ្ជាជាទីលម្អសព្វមនុស្ស ។

៙ ព្រះធម៌ថ្លៃថ្លាគ្មានស្អប់សត្វ អ្នកគំនិតកាត់មិនដឹងគួរ លោកតែងដឹកដៃអ្នកទៅសួគ៌ពុំគិតចិត្តជូគួរខ្លាចស្លាប់ ។

៙ ព្រះធម៌ដែលជនបានរៀនយក ប្រៀបដូចពពកខ្ពស់ពេកពន់ ជនណាបានរៀនច្រើនលើសលន់ លោកប្រៀបជាជនកប់ពពក ។

៙ ព្រះធម៌ស្ថិតនៅមនោស្អាត ព្យាយាមសង្វាតនៅបណ្ឌិត ការជួយធុរៈជាក់ជាមិត្រការវិបរិតស្ថិតក្នុងសង្ខារ ។

៙ ព្រះសង្ឃពឹងវិន័យ សត្វភពត្រៃពឹងធរណី សេនាពឹងឫទ្ធី ឯអ្នកជីពិតពឹងវត្ត ។

៙ ព្រះមិនសមព្រហ្មមិនជួយ ។

៙ ព្រះស្ថិតនៅឯគេហដ្ឋាន គួរថ្វាយទានមុនព្រះនៅវត្ត ។ (ជុំ មួង)

**ជីវិតរាល់រូប តិចតួចណាស់ ប៉ុន្តែយើង ត្រូវប្រឹងរៀន ប្រឹងរក**

**ប្រឹងគិត ប្រឹងប្រព្រឹត្ត ហាក់ដូចជាយើងនឹងមានជីវិតរស់នៅរាប់**

**ពាន់ឆ្នាំ ។**

ស្រង់ចាកសុភាសិត សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ (**ជោតញ្ញាណោ ជ.ណ**)

## ភ

៚ ភពគឺប្រទេសជាតិសាសនា ចម្រើនលឿនថាវរៈក្រៃ ដោយសារជនណាខំប្រឹងថ្ងៃ ស៊ូប្តូរដួងចៃមិនខ្លាចស្លាប់ ។

៚ ភរិយាមួយសុខស្រួលកាយចិត្ត ភរិយាពីរពិតដូចផែសង្កំ ភរិយាបីដូចភ្លើងឆេះភ្នំ ភរិយាបួនសមភ្លើងអវិចី ។

៚ ភរិយាល្អចូរពិនិត្យ គឺពិតជាមិនចេះប្រច័ណ្ឌ ទោះឃើញប្តីមានស្រីជាក់ស្បាន់ នាងកាន់តែល្អស្មោះសក្រៃ ។

៚ ចំណែកភរិយាកាឡកិណ្ណី ប្រច័ណ្ឌតែប្តីរាល់យប់ថ្ងៃ ក្នុងចិត្តក្តៅក្តួលនឹកស្រមៃ តែប្តីមានស្រីជាប់ជានិច្ច ។ (សុង ស៊ីវ)

៚ ភរិយាល្អក្ររកបាន បើជាមានទុកធ្វើគំរូ ។ (ជុំ ប៊ួង)

៚ ភាណុវង្ស[9] រះក្នុងទិសបច្ឆិមា សុមារាគិរីទោរទន់ទៅ ភ្លើងក្នុងយមលោកនរកជ្រៅ កុំដៅប្រែទៅជាត្រជាក់ស្និទ្ធ ។

៚ ឧប្បលបុប្ផាផ្កាបទុម រីកលើខ្នងភ្នំឃើញវិបរិត វាចាសប្បុរសពោលចេញពិត មិនប្រែវិបរិតក្នុងកាលម្តង ។

៚ ភិក្ខុសង្ឃប្រឡង់ដោយសិក្ខា សីលសិក្ខាមានពីណាបរិសុទ្ធ អ្នកស៊ីសាច់មានពីណាចិត្តលំអុត ប្រមឹកសុទ្ធមានពីណាពោលពាក្យសត្យ ។

---

[9] ភាណុវង្ស = ព្រះអាទិត្យ ។

៙ មហាលោភមានពីណាក្តីខ្មាសអៀន អ្នកខ្ជិលរៀនមានពីណាសិល្បសាស្ត្រស្ទាត់ មហាក្រោធមានពីណាទ្រព្យសម្បត្តិ ឥតប្រតិបត្តិមានពីណាបញ្ញាបុណ្យ ។

៙ ភូតនៅហោរ ចោលនៅជាង ។

៙ ភូមិផងរបងជាមួយ ។

៙ ភេលង់ទឹក ។

៙ ភោជនមេថុននឹងនិទ្រា មានក្នុងគោបានិងបុរស វិជ្ជាវិសេសរបស់ប្រុស វិជ្ជាហីន យសស្មើគោខ្មៅ ។

៙ ភ្លៀវមកតោងមើលអាការចេញ ពាក្យពោលម្ដេចមិញគង់ឃើញពិត ពាក្យស្លែងរំរែង ស្លុតជូនជាមិត្រ ពាក្យពិតជូនពោលមមាលវិញ ។

៙ ភ្លាត់មាត់មិនទប់ប្រាក់ ភ្លាត់ជើងៗបាក់មានថ្នាំបិទ ភ្លាត់ការគង់តែបំបែរគិត ភ្លាត់ចិត្ត គង់រាប់ទៅតាមចេះ ។

៙ ភ្លើងឆេះមកពីសម្រាម ។

៙ ភ្លេភ្លើដូចក្រពើវង្វេងបឹង ។

**គ្មានសុខដទៃក្រៃលែងជាងសន្តិភាព ៕**

**សេចក្ដីលោភនាំឱ្យអន្តរាយសន្តិភាព ៕**

ស្រង់ចាកសុភាសិត **ព្រះមុនីកោសល (សោម-ឈុន)**

# ម

៚ មច្ឆាត្រីឆ្លោរស៊ីកូន កូនចេកប្រាជ្ញចែងស៊ីមេវា ឫស្សីបបុសផ្លែតែងមរណា បាបវេរា តែងសម្លាប់ជនពាល ។

៚ មនុស្សពាលមានការរករឿងជាកម្លាំង ។ (ប៉ាង-ខាត់)

៚ បណ្ឌិតមានការមិនរករឿងជាកម្លាំង ។ (ប៉ាង-ខាត់)

៚ អ្នកពហុសូត្រមានការពិចារណាជាកម្លាំង ។ (ប៉ាង-ខាត់)

៚ សមណព្រាហ្មណ៍មានខន្តីជាកម្លាំង ។ (ប៉ាង-ខាត់)

៚ ទារកមានយំជាកម្លាំង ។ (ប៉ាង-ខាត់)

៚ ស្ត្រីមានក្រោធជាកម្លាំង ។ (ប៉ាង-ខាត់)

៚ ចោរមានអាវុធជាកម្លាំង ។ (ប៉ាង-ខាត់)

៚ ព្រះរាជាមានឥស្សរិយៈជាកម្លាំង ។ (ប៉ាង-ខាត់)

៚ មនុស្សយកសម្តី ដំរីយកភ្លុក ឬ(មនុស្សគេយកសម្តី ដំរីគេយកភ្លុក) ។

៚ មនុស្សមាត់ឥតគ្រប ។

៚ មនុស្សស្លាប់ព្រោះវាចា ឬ(ព្រោះសម្តី) ។

៚ មនុស្សកាចកុំប្រសព្វ កុំទៅគប់នឹងចោរក្បួយ ។

៚ មនុស្សកុំមើលងាយមនុស្ស ។

៙ មនុស្សខឹងកុំឱ្យលាងចាន មនុស្សឃ្លានកុំឱ្យដាំបាយ ។

៙ មនុស្សខ្លាំងទុកជារបង មនុស្សកាចទុកជាខ្នង មនុស្សកោងទុកជាកម្រាស់ មនុស្សស្លូតណាស់ទុកជារនាំង ។

៙ មនុស្សឆ្លាតគេថាឆោត មនុស្សប្រាជ្ញគេថាល្ងង់ ។

៙ មនុស្សចេះគេថាកាច មនុស្សប្រាជ្ញគេថាព្រើល ។

៙ មនុស្សទាបរែងធ្វើខ្ពស់ ក្រទុយ៌ស(រែង) អួតធនធាន ខ្លាចរែងធ្វើជាហ៊ាន ប្រាជ្ញគ្មានរែងអួតចេះ ឬ(រែងអួតមាន) ។

៙ មនុស្សនឹងប្រាក់ យក្សនឹងសាច់ ឆ្កែនឹងអាចម៌ ស្រីនឹងប្រុស ។

៙ មនុស្សមិនស្គាល់មនុស្ស កុំយកចំពោះធ្វើការឧត្តម ស្រីមិនស្គាល់ស្រី កុំឱ្យសេពសម ភរិយាជាធំអភ័ព្វវិនាស ។

៙ មនុស្សភ្នែកងងឹត មានទ្រព្យច្រើនពិត ហៅក្រពេកពន់ ចេះមិនប្រតិបត្តិ ហៅល្ងង់លើសលន់ មានវិទ្យាគុណ ហៅមានប្រាកដ ។

៙ មនុស្សច្រើនងងឹតល្ងង់មិនបានការ មនុស្សម្នាក់ប្រាជ្ញវិសេសឯក អាចរំលឹកទូន្មានគួរចូលសេក្ខ ខំស្ដាប់ធម៌ប្លែកៗប្រដៅប្រាណ ។

៙ មនុស្សក្នុងផែនដី បុរាណស្រដី តាមន័យភាសិត ថ្លៃថោកយ៉ាងណា កិច្ចការកំរិតទៅតាមគំនិត មនុស្សជាន់ថោកថ្លៃ ។

៙ មនុស្សលោកលោភលន់ មិនដែលឆ្អែតឆ្អន់ បានច្រើនយ៉ាងណា នៅតែខ្វះខាតកន្លះចិន្ដា ចិត្តចើងលាភា វែងបាត់ធនទៅ ។

៚ មនុស្សនឹងមនុស្ស តែងមានត្រូវខុស ទាស់ទែងខ្វែងគ្នា ឯសត្វនឹងសត្វក៏ដូច្នោះណា តែងមានវេរា តគ្នាជានិច្ច។

៚ មនុស្សក្នុងលោក មានច្រើនគគោក ត្រូវប្រាស្រ័យគ្នា អ្នកខ្លះធ្វើស្រែ ខ្លះធ្វើចម្ការ ជាងសង់គ្រឹហា មុខការរៀងខ្លួន ។

៚ មនុស្សមានពូជ មិនសូវខិលខូច ខាងផ្លូវមុសា ពោលតែពាក្យពិត តាមវង្សគុណា អម្បូរថ្លៃថ្លា ការកេរ្តិ៍អ្នកជា ។ (ប៉ុណ្ណ្យ-សម្កាជ)

៚ មនុស្សសត្វទាំងឡាយ កិច្ចកលក្រងាយ មិនស្គាល់ជម្រៅ ព្រោះសន្តានចិត្ត ចរិតសខ្មៅ បងប្អូនកូនចៅ សឹងផ្សេងពីគ្នា ។

៚ មនុស្សសត្វលោក តែងជួបទុក្ខសោក ព្យាធិមរណា ធំតូចខ្ពស់ទាប ស្តេចរាស្ត្រប្រជា មន្ត្រីក្តីណា សឹងមរណ៍សូន្យបង់ ។

៚ មនុស្សណាល្ងង់មិនដឹងខ្លួនថាខ្លួនល្ងង់ ដូចហ៊ីងប៉ោងថ្មីមទ្រង់ពង្សគុជសារ មនុស្សបែបនេះអ្នកប្រាជ្ញវិះឱ្យឈ្មោះថា ពាលមាហាកុំប្រាថ្នាចងជាមិត្រ ។

៚ មនុស្សណាល្ងង់ហើយដឹងខ្លួនថាល្ងង់ បន្ទន់ភាពបន្ទាបពង្សថាល្ងង់ពិត មនុស្សបែបនេះគួររាប់គេយកជាមិត្រ អ្នកប្រាជ្ញព្រឹទ្ធប្រើប្រាប់គ្នាកុំទ្រមក់ ។

៚ មនុស្សណាចេះមិនដឹងថាខ្លួនចេះ ទុកចំណេះឱ្យភាន់ផុងកប់ក្នុងភក់ មនុស្សបែបនេះឈ្មោះថាគ្នាទិន្ទ្រាលក់ គួរតែគត់ទាញតប់ទះដាស់តឿនថ្កាន ។

៚ មនុស្សណាចេះហើយដឹងខ្លួនថាចេះ ផ្សាយចំណេះជាពន្លឺភ្លឺសព្វស្ថាន មនុស្សបែបនេះចំជាប្រាជ្ញអាចហៅបាន គួរសន្និដ្ឋានទុកជាមហាបុរសរដ្ឋ ។

៙ មនុស្សណាផ្សាយតែការល្អរបស់ខ្លួន លាក់បំពួនការអាក្រក់មិនសម្ដែងទុកជាមានអានុភាពខ្ពស់ឈ្មោះខែងរ៉ែង ក៏គេតែងតែនិន្ទាជានិរន្តន៍ ។

៙ មនុស្សមិនស្របប្រកបដោយគុណសម្បត្តិ គ្មានពាក្យសត្យពាក្យសុចរិតឥតមេត្តា គង់នឹងភាន់ក្នុងជ្រោះនៅឯកា គ្មាននរណាគេអាណិតគិតប្រណី ។

៙ មនុស្សអំនួតអួតពូកែគ្នាឯង គេមិនឆោតទៅកោតក្រែងស្វែងធ្វើអ្វី គេមិនស្ដាប់ត្រាប់ត្រងទេពាក្យសម្ដី គេមិនខ្វីទៅពឹងពាក់ការរាក់ជ្រៅ ។

៙ មនុស្សដែលល្ងង់ឃើញតែទ្រង់ទម្រង់ការ មិនពិនិត្យពិចារណារកការពិត ចេះតែជឿដោយភាន់ភាំងទាំងងងឹត គ្មានគំនិតផ្សំហេតុផ្សំផលផង ។

៙ មនុស្សច្រើនភាព អាហារប្រៃសាប ជូរចត់ល្វីងខារ តិរិច្ឆានច្រើនក្រុម ជាតិច្រើនភាសា ធម៌ច្រើនប្រការ និព្វានតែមួយ ។

៙ មនុស្សណាមានទុក្ខភ័យ ក្រេបរសប្រៃល្វីងជូរខារ តែងញញើតកាយា ឃើញស្រមោលក៏ខ្លាចដែរ ។

៙ មនុស្សខឹងច្រើនៗខុស មនុស្សច្រើនឈ្លោះច្រើនប្រមាថ ការល្អច្រើនត្រូវខ្នាត បើចង់ស្អាតកុំខ្លាចយូរ ។

៙ មនុស្សរើសចំណី ឆ្កោប្រាមិនឆី រើសឆ្នើងបែរបៀង រកជ្រូកមាន់ទា សម្រាប់ជប់លៀង ដល់ឃ្លានមិនទៀង លូកពាងប្រហុក ។

៙ មនុស្សនៅក្រោមមេឃត្រេកតែទុក្ខ ព្រោះជឿថាសុខក្នុងរូបក្ខន្ធ ខន្ធអត្តីកុំចង់កាន់ស្គាល់ខន្ធឱ្យមាំខំគិតដោះ ។

៚ មនុស្សជាគេថាកាច មនុស្សប្រាជ្ញគេថាព្រើល។

៚ មនុស្សប្រាសចាកគុណ ទុកជាមានបុណ្យត្រកូលខ្ពស់ធំ ក៏គ្មានប្រយោជន៍ដល់អ្នកសេពសម គ្រាន់តែខ្ពស់ធំៗមិនប្រសើរ ។

៚ មនុស្សល្ងង់តែងខ្លួន បិទបាំងបំពួន ដោយសំពត់សៃ្ប មើលពីចម្ងាយ សមល្អប្រពៃ ដោយសារអាស្រ័យ សំពត់អាវនោះ ។

៚ មនុស្សថោកសម្ដីខ្ពស់ ឥតឥស្សរិយយសឫកចចើង ប្រាជ្ញាតិចស្ដួចស្ដើង ប្រឹងដំឡើងអំនួតចេញ ។

៚ មនុស្សរស់ឈ្មោះស្លាប់មានប្រាំហេតុ មួយគឺពេទ្យបំភពខ្មោចបិសាច ពីរគឺកើតព្យាធិរោគកំណាច បៀតបៀនកាយមិនអាចឱ្យក្សាន្តចិត្ត ។បីអ្នកមូទ្បោកំជិលជាក់ បួនគឺអ្នកជំពាក់បំណុលពិតប្រាំគឺរាជអមាត្យគាល់នៅនិត្យមានជីវិតប្រាំនេះប្រាជ្ញថាស្លាប់ ។

៚ មនុស្សវៀរតម្រាប្រាំពីរនាក់ មួយគឺអ្នកល្មោភដេកត្រេកនិន្ទ្រា ពីរគឺអ្នកប្រមាថសព្វវេលា បីគឺអ្នកសុខាភ្លីស្មារតី[10] ។ បួនគឺអ្នកមានរោគជាមន្ទិល ប្រាំគឺអ្នកកំជិលជួរអប្រិយ ប្រាំមួយគឺប្រាថ្នាការលោកិយ ប្រាំពីរគឺមានក្ដីត្រេកក្នុងការ ។

៚ មនុស្សយើងសព្វថ្ងៃ ហួងគោរិស័យ ស៊ីស្មៅនៅវាល ជាតិខ្លារាជសីហ៍ ប្រុងស្មៀតគ្រប់កាល មិនចោលក្បួនពាល ចាំចាប់បរិភោគ ។

៚ មនុស្សកាចប្រាកដ លាក់ពុតមិនមាត់ ធ្វើឫកសុភាព ឯមនុស្សព្រហើន ឫកមិនរាបទាប ពាក្យឥតសុភាព នាំឱ្យគេស្អប់ ។ (ជុំ-មួង)

---

[10] ប្រហែលជា "បីគឺអ្នកសុខាភ្លេចស្មារតី" ។

៙ មនោបរិសុទ្ធ មិនសូវច្បុត កាន់ទីសល់រ៉ល់ គំនិតថោតទាប ដូចភាពត្រូវខ្យល់ ឱ្យកើតអំពល់ អំពើព្រួយប្រាណ ។

៙ មនោឃិទ្ធនឹងវាសនា ធម៌ពីប្រការនេះនៃបនិត្យ តែងជួបគ្នាគ្រាប្រឱត ផ្តើមគិតធ្វើអ្វីឱ្យសម្រេច ។

៙ មហាក្សត្រតម្រាស់ត្រាប់តែម្តង សមណព្រាហ្មផងពោលម្តងស្រេច សប្បុរសពោលម្តងក៏សម្រេច ធម៌ដែលដាច់នោះជាធម៌បុរាណ ។

៙ មហាក្សត្រគួរជ្រាបព្រះរាជទ្រព្យ វិនាសទៅឬត្រឡប់ចម្រើនវិញ ទាំងមានការឥតការយ៉ាងណាមិញ គួរបំពេញឬបន្ថយដោយកិច្ចណា ។

៙ អ្នកណាធ្វើខុសប្រោសធ្វើទោស កុំសន្តោសយល់មុខសេវកា ។

៙ មន្ត្រីភ្លេចជាតិ និទ្រាភ្លេចស្មៀត ស្តេចភ្លេចឧបាយ ក្រេបរសដទៃ ភ្លេចរសជាតិបាយ បានលាភស្រួលកាយ ភ្លេចជាតិអាត្មា ។

៙ មន្ត្រីស៊ីរាស្ត្រ ពួកអ្នកទាំងផ្តាស ស៊ីរាស្ត្រកម្មករ ដូចពួកសេដ្ឋី ពឹងអ្នកក្រីក្រ ឱ្យខំត្រដរ អូសនឹមអាត្មា ។

៙ មាត់អាក្រក់ច្រើនចិត្តកល្យាណ អ្នកចិន្តាសាមាន្យច្រើនមាត់ល្អ ឯរបៀបភាពមារយាទខ្មៅស កម្រយល់ពិតបណ្ឌិតដឹង ។

៙ មាត់មានគ្រប ដប់មានឆ្នុក ។

៙ មាត់ស៊ីអំបិលប្រហុក ។

៙ មាត់តែប្រកែកអង្រែកតែទទួល ឬ(មាត់តែប្រកែក ភ្នែកតែឱ្យការណ៍)។

៙ មានពីរោះ ពោះកាត់ក។

៙ មានត់ចាបមាត់ព្រាប ឬ(ឮតាមមាត់ចាបមាត់ព្រាប) ។

៙ មាត់ឥតគ្រប ។

៙ មាត់នៃជនឯណាដូចបទុម ពាក្យភិរម្យត្រជាក់ដូចខ្លឹមចន្ទន៍ ដួងហឫទ័យ ដូចសរមុតដូចខ័ន កុំពាក់ព័ន្ធគប់សេពនឹងជននោះ ។

៙ មានទ្រព្យមិនស្មើនឹងមានវិជ្ជា មានរោគាពុំស្មើពាលតង្គាន ស្រឡាញ់អ្វីពុំស្មើស្រឡាញ់ប្រាណ កម្លាំងអ្វីមិនស្មើស្ពានកម្លាំងកម្ម ។

៙ មានទ្រព្យមិនស្មើមានវិជ្ជា វិជ្ជាចោរលួចយកមិនបាន វិជ្ជាទុកជាមិត្រសន្តាន ក្សាន្តក្នុងឥធលោកយោគបលោក ។

៙ មានវិជ្ជាជាពន្លឺភ្លឺសាយសុស នាំឱ្យមើលឃើញកំហុសរបស់អ្នកខ្លៅ បើឃើញហើយត្រូវបង្រៀនប្រៀនប្រដៅ ទើបឈ្មោះហៅថាអ្នកចេះចំណេះមែន ។

៙ មានទុក្ខសឹងនឹករកញាតិ ដល់ទុក្ខឃ្លាតបាត់នឹកឈឹង ។

៙ មានកូនមិនឱ្យកូនសូត្ររៀន ចំណេះរបៀនការនានា មាតាលោកថាជាវេរា បិតាទុកជាសត្រូវធំ ។

៙ កូនពេញរូបពាលពត់មិនឡើង ហៅថាមិនថ្កើងក្នុងជំនុំ ប្រៀបដូចកុកគ្រោងចូលទ្រនំ កណ្តាលជំនុំនៃរាជហង្ស ។

៙ មានផ្លូវឥតមនុស្សដើរ តាមដំណើរពីព្រេងនាយ អ្នកស្រែក៏អត់បាយ អ្នកព្រៃឆ្ងាយគ្មានអុសដុត ។

៙ មានផ្ទះឥតមនុស្សនៅ មានផ្លូវឥតមនុស្សដើរ ។

៙ មានទោសពីព្រោះដី គំនិតខ្លីឆោតជឿជាក់ ឆោតបង់ទាំងលុយកាក់ រើលើកដាក់រកដីល្អ ។

៙ មានទ្រព្យគាប់គ្រាន់បើ តែពុំស្មើនឹងវិជ្ជា ចេះចាំកិច្ចវិទ្យា ចោរលបលួចយកពុំបាន។

៙ មានទ្រព្យគង់នឹងមានមិត្រភ្ងា មានទ្រព្យមុខជាមានផៅពង្ស មានទ្រព្យរាប់ថាប្រុសខ្ពង់ខ្ពស់ មានទ្រព្យជាវង្សបណ្ឌិតជាតិ ។

៙ មានបុណ្យពុំស្មើមានសម្បត្តិ មានធនធានក្ដាត់ពុំស្មើមានកុសល មានបរិពាពោពាសពុំស្មើបុត្រនិមល ជនច្រើនរវល់ពុំស្មើព្រះពុទ្ធមួយ ។

៙ មានភ្លើងមានផ្សែង មានងងឹតមានថែង[11] ស្លឹកឈើកំរើក ដ្បិតមានខ្យល់បក់មច្ឆជាតិរើក ហែលហែបកខ្វើក ល្អក់ទឹកពុំជា ។

៙ មានមាសនិងប្រាក់ជាដើមទង តែងមានអ្នកផងជាញាតិមិត្រ គេសូកអង្វរឱ្យជួយគិត ប្រឹតកិច្ចការផងទាំងឡាយ ។

៙ មានយោបល់យល់ស្របគ្នាជាធ្លុងមួយ នោះមិនព្រួយនឹងប្រកែកជជែកអ្វី បើជាបែកយោបល់គញ្ញនាជាពីរបី ទោះប្រកែកដូចម្ដេចក្ដីឥតបានការ ។

៙ មានគំនិតឥតកំណើត ។

៙ មានភ្នែកដូចម្នាស់ ។

៙ មានភ្នែកដូចមនុស្សខ្វាក់ ។

---

[11] ថែង = ភ្លឺ , ច្បាស់ ។

៙ មានធនប្រពន្ធមិនក្រ មានដីសមិនក្រក្ដារខៀន មានរបៀនមិនក្ររបស់ ។

៙ មានមិនដែលបិត ក្រមិនដែលបីជាន់ ។

៙ មានបញ្ហាការជ្រៅរាក់ទាក់ទាមអ្វី ឬកើតក្ដៅឈ្លោះប្រកែកជជែកគ្នាខ្វែង គំនិតគិតផ្ដេសផ្ដាសមិនសះជា កុំយកពាលធ្វើសភាកាត់ក្ដី ។

៙ មានទុក្ខមហាក្សត្រ មានទុក្ខចៅវត្ត មានទុក្ខស្រីរូបល្អ ។ (ខ្លះថាស្រីមានគត៌)

៙ មានស្រមោចទើបឆ្អែវាជុះ ។

៙ មានប្រឡាយទើបទឹកហូរ ។

៙ មាន់ពងលើជង្រុកស្រូវ ។

៙ មាន់តែយក កតែកាច់ ឬ(មាន់ក៏យក កក៏កាច់) ។

៙ មាន់ព្រៃកំចាយមាន់ស្រុក ។

៙ មាន់ល្អព្រោះរោម រូបឆោមល្អព្រោះតែង ។

៙ មាន់ណាខ្ទត មាន់ហ្នឹងពង ។

៙ មានៈជាធម៌ ធ្វើឱ្យល្អក់ពណ៌ ធ្វើឱ្យខាតលក្ខណ៍ ធ្វើសត្វឱ្យសាប សូន្យលាភសូន្យភ័ក្ត សូន្យចាកពុំនាក់ សូន្យមគ្គសូន្យផល ។ (ខ្លះថាភក្តិ)

៙ មានៈបាត់មិត្រ ឥតអ្នកជាផៅ គ្រេវគ្រោធឃោរឃៅ រមែងបាត់អង្គ ។

៙ មារជ្រែក ។

៚ មាសប្រាក់ទាំងឡាយ ទ្រព្យផងសម្ងាយ ទោះច្រើនយ៉ាងណា បើឥតសុខកាយ ឥតសប្បាយចិន្តា ទើបលោកពោលថា ទ្រព្យមិនប្រសើរ ។

៚ មានប្រាក់កែវសូរ្យកាន្ត អាចអួតហាននឹងពេជ្ររតន៍ ភមរជាតិកន្លង់សត្វ អួតហើរកាត់ភ្នំព្រះសុមេរុ ។

៚ មិត្រមួយសោតណា ទៅមកកាន់គ្នា បង្កើតឱ្យសុខ មិត្រមួយឱ្យទោស បង្កើតជាទុក្ខ មិត្រមួយឱ្យទុក្ខ ឱ្យបង់ទ្រព្យា ។

៚ មិត្រមួយឱ្យហឹន ទៅមកខ្វាន់ៗ ជក់ថ្នាំស៊ីស្លា ចុះឡើងឥតអាក់បង្ខិនអាត្មា កូនអើយលោកថា អាសារបង់ទ្រព្យ ។

៚ មិត្រឯណាលុបគុណមិត្រកំបាំង លុះមកតាំងឆ្ពោះមុខពោលភិរម្យ មិត្រយ៉ាងនោះគួរតែកុំស្វាគមន៍ ដូចទឹកឃ្មុំនៅក្នុងឆ្នាំងថ្នាំពិស ។

៚ មិត្រឯណាហាមឃាត់ការអប្រិយ ត្រង់ការសួស្ដីខំដាស់តឿន ក្នុងពេលវិបត្តិមិនចោលភឿន មិត្រនោះទើបហៅថាជាមិត្រពិត ។

៚ មិត្រឧត្តមធំបំផុតនៅវិជ្ជា សត្រូវក្លាកាចបំផុតនៅព្យាធិ ការស្រឡាញ់ក្រៃបំផុតកាយិន្ទ្រិយ ពលពលីខ្លាំងបំផុតនៅផលកម្ម ។

៚ មិត្រល្អឱ្យសុខ បាបមិត្រឱ្យទុក្ខ គ្រប់ទិសទិវា មិត្រល្អក្រមាន ខ្ពស់ទាបយ៉ាងណាតែងយកអាសា ដាស់តឿនខុសត្រូវ ។

៚ មិនលេងបានឈ្នះ នេះគឺពាក្យព្រះ ពាក្យចាស់ពីព្រេង អ្នកណាចាញ់ៗ គឺសុទ្ធតែលេង នេះពាក្យពីព្រេង ចូរចាំកុំភ្លេច ។ (សុង ស៊ីវ)

៙ មិនត្រូវចោលសាច់ស្រវាឆ្អឹង ទំពាររទៅរឹងទើបបានគិត ងាកមកសាច់ខ្លួនឯងពិត ដោយទាស់គំនិតគេចពុំរួច ។

៙ មិនប្រហែសភ្លេចស្មារតី វិជ្ជាទ្រព្យអ្វីត្រូវរៀបចំ ត្រូវចេះរំលឹកចេះសន្សំ ចេះរៀបចេះខំកុំខានឡើយ ។

៙ មិនត្រូវរង់ចាំព្រេងវាសនា មិនត្រូវធ្វើការខុសលំអាន មិនត្រូវខ្ជិលរៀនទូន្មានប្រា-ណ មិនត្រូវឱ្យទានគ្មានពិចារណា ។

៙ មិនមានចេះសោះ ថាមិនចេះស្មោះ ហៅគាត់ប្រសើរ បើចេះថាចេះ ហៅចេះគ្រាន់បើ ចេះប្រាជ្ញចេះប្រើ ដំណើរការពិត ។

៙ មិនជឿពាក្យស្រីអស់ស្រូវពូជ ឬ(តែជឿ...)។

៙ មិនឱ្យអ្នកក្រៅដឹងទោសខ្លួន ទោសគេបំពួនអាចដឹងបាន ទោសខ្លួនពួកលាក់ធ្វើហាក់គ្មាន ដូចកល់ជើងក្រានលាក់គ្រាប់ធ្យូង ។

៙ មិនជឿពាក្យចាស់វាស្រឡះដៃធេង មិនជឿពាក្យក្មេងរលីងដុចគុជ ឬ(វារលីងសក់ក្បាល) ។

៙ មិនទាន់ចាស់កុំអាលបេះមកបន្ទុំ ជាក់ជាពុំមានរសផ្អែមល្ហែមឡើយណា មិនទាន់ចេះកុំអាលចង់ធ្វើមេបា នឹងខូចការដោយសារលង់ស្នង់មិនត្រូវ។

៙ មីះៗកែះឆ្នាំងបាយឆ្លុះ ។

៙ មុខរឹងដូចដែក ។

៙ មុខឆ្អែស្រែជម្រៅ ។

៚ មុខក្រាស់ដូចស្បែកជើង ។

៚ មុជមិនជ្រៅទៅមិនឆ្ងាយ ។

៚ មុតដូចកាប់នឹងកាំបិត ឬ(សម្ដីមុតដូចកាប់នឹងកាំបិត) ។

៚ មុននឹងធ្វើទារុណកម្មទៅលើគេ ត្រូវអ្នកផ្ទេរប្ដូរមកដាក់រូបអ្នកសិន តែមិនគិតចេះតែមិតសង្កត់កិន ឱ្យគេហីនដោយសារឯងមិនក្រែងខ្លាច ។

៚ មួយសេនសន្សំ ចូលចង់ប្រជុំ ផ្សែផ្សំគ្នីគ្នា យូរទៅបានច្រើន រាល់ថ្ងៃវេលា តិចៗផ្ដួនគ្នា ទៅជាសេដ្ឋី ។

៚ មើលផ្ទះស្រាស់របង រាំងចំណាររគួររក្សា ឬ(ឯងអាត្មា) ។

៚ មើលអាយមើលនាយមើលកៀនកោះ កុំឱ្យចន្លោះប្រយោជន៍បង់ ឈានជើងក្នុងលោកធៀបមើលអង្គ កុំចង់បង់បោយឱ្យហួសខ្លួន ។

៚ មើលមេឃតោងមើលទៅទេវតា ចូលព្រៃព្រឹក្សាតោងមើលលើ យកមិត្រមើលចិត្តឱ្យស្មោះស្មើ យកក្លើតោងមើលឱ្យសមប្រាណ ។

៚ មើលឃើញច្រើនកល ខេមរៈកុំឆ្ងល់ គួរសេពមេត្រី អ្នកមើលច្រើនស្រុក ចេះបែបបទថ្មី ភមរាវិស័យ ច្នៃខ្មែរទាន់លោក ។

៚ មើលឱ្យជាក់សឹមញាក់ចិញ្ចើម ឬ(មើលមិនជាក់ កុំអាលញាក់ចិញ្ចើម ប្រពន្ធមិនទាន់ផើមកុំអាលរកខុស)។

៚ មេម៉ាយកូនមួយដូចព្រហ្មចារី មេម៉ាយកូនបីដូចស្រីសៅកែ។

៚ ម៉ែឪមានគុណណាស់ មិនសំពះខ្មាសអៀនដៃ ឯអ្នកក្រៅដទៃ វិស័យស្មោះសំពះបាន ។

៚ ម៉ែឪនៅផ្ទះ លោកទុកជាព្រះ ដូចព្រះឯវត្ត សំពត់អាហារ ត្រូវកូនផ្គង់ផ្គត់ កុំឱ្យលោកអត់ បានបុណ្យដូចគ្នា ។ (ជុំ មួង)

៚ ម៉ែឪជាបុគ្គលប្រសើរណាស់ក្នុងលោកិយ កូនប្រុសស្រីកុំយល់ថាគុណតែនឹងខ្លួន ម៉ែឪគឺជាម៉ែឪសកលលោកពេញសំនួន ជាម៉ែឪនៃក្បួនច្បាប់វិទ្យាសាស្ត្រទាំងអស់។

៚ ព្រោះអ្នកប្រាជ្ញ អ្នកមានយសមានទ្រព្យគ្រប់ជាន់ថ្នាក់ គ្មាននរណាម្នាក់កើតឯងឥតម៉ែឥតឪសោះ គ្រប់ជាតិសាសន៍សុទ្ធតែកូនម៉ែកូនឪទាំងអស់ នេះឯងព្រះរស់កូនត្រូវបូជាគុណរាល់ពេល។ (សុង-ស៊ីវ)

៚ ម្ចាស់កំណាញ់ពេញកំណាចលើសម្ចាស់គ្រោត ម្ចាស់ថយជាតិមិនលើសម្ចាស់កំណាញ់ ម្ចាស់ផ្ទាល់ជួរលើសម្ចាស់មិនលើសវិញ ម្ចាស់បួននេះកុំស្រឡាញ់យកជាម្ចាស់។

៚ ម្តាយឪពុកនិងកូន បីដូចខ្លួននឹងស្រមោល ឃើញខុសកុំដេញដោល កុំថ្កោលទោសអ្នកមានគុណ ។

៚ ម្ទៅៗទាយកជ័រញ្ញោមកត្បៀតក្បៀក ឬ(មិននៅៗ...)។

៚ ម្ទៅៗយកស្កុរទៅផ្ញើនឹងស្រមោច ។

៚ ម្លប់នៃព្រឹក្សាហៅមហាសុខ ម្លប់ម្តាយឪពុកញាតិកា វិសេសលើសម្លប់នៃព្រឹក្សា ម្លប់គ្រូអាចារ្យលើសម្លប់ញាតិ។

៚ ម្លប់ស្ដេចលើសម្លប់គ្រូអាចារ្យ ម្លប់ព្រះឈ្នះមារបរមនាថ វិសេសលើសម្លប់ខត្តិយជាតិ ព្រោះស្អាតខាតបង់សង្សារចក្រ ។

★ ★ ★

# យ

- យកផ្សែងថ្ងូតជាដុំ ។

- យកហេះទៅដូរហោះ ។

- យកអន្ទង់ទៅចំហុងភក់ ។

- យកសំធឹងធ្វើប្រពន្ធ យកប្រពន្ធសំធឹង (សុភាសិតចិន)។

- យប់យូរនៃអ្នកមិនលក់ឯង យោជន៍យូរឆ្ងាយវែងនៃអ្នកចរ សង្សារយូរឆ្ងាយនៃនិករពាលពុំចេះធម៌ទៅនិព្វាន ។

- យល់ញាតិឃ្លាតច្បាប់ចាប់រវាត យល់ការគង់ឃ្លាតឃ្លៀងចំណេះ ដំរីជើងបួនគង់មានភ្លាត់អេះ អ្នកប្រាជ្ញដែលចេះគង់មានភ្លេច។

- យល់ឆ្ងាយកុំណាយចិត្តគិត ទោះយល់ជិតកុំណាយខំ មិនជាក់មើលឱ្យចំ ក្រែងប្រទ្បាំសជាខ្មៅ ។

- យល់តូចកុំអាលខំ ទោះយល់ធំកុំអាលស្រោយ គិតក្ដីគិតងាយ មើលពិនិត្យពីនីច្ច័យ។

- យល់នាមថាជាបង យល់ឯថាជាក្មួយ ។

- យល់តាថាជាដូន យល់ឯកូនថាជាក្មួយ យល់ពីរជាមួយ យល់ឯព្រួយថាជាសុខ។

- យល់ទោសថាជាគុណ យល់ឯបុណ្យថាជាបាប ។

- យល់ល្អថាអាក្រក់ យល់ឯលាមកថាជាផ្កា ។ ឬ(យល់ឯបុណ្យថានរក)។

៙ យល់ឈើថាខ្មោច ស្មានស្វាជាទោច យល់ក្តោងនារី ពីឆ្ងាយសន្ធឹម សន្ធំឃ្លាតខ្មី ចូលចតជិតដី ទើបគេស្មានយក ។

៙ យើងជាតិខ្មែរយើងពូកែប៉ុណ្ណាហើយ យើងចោទឆ្លើយតែខ្លួនយើងក៏បានដែរ ព្រោះខ្លួនយើងៗបានដឹងជាហូរហែ ខ្លាំងពូកែឬមានក្រក៏យើងដឹង។

៙ យើងធ្វើគេៗធ្វើយើងវិញដូចគ្នា។

៙ យើងរាល់គ្នានេះឯងហើយជាមនុស្សលោក គួរអធ្យោគយោគយល់គ្នាជាញាតិមិត្រ យល់សាមគ្គីជាទីតាំងរួមគំនិត ត្រិះរិះគិតកសាងលោកឱ្យចម្រើន។

៙ យើងពលរដ្ឋត្រូកផ្គាប់ច្បាប់សម្រាប់រដ្ឋ កុំបីភ្លាត់ចូលបទល្មើសល្មើសនឹងច្បាប់ ល្អជាងផ្គាប់មនុស្សនានាជាលំដាប់ ល្បីកិត្តិស័ព្ទថាស៊ូស្លាប់ក្រោមច្បាប់មែន។

៙ យើងកុំធ្វើអ្វីឱ្យគេខឹងនឹងយើង នោះមិនទើងគេនឹងថាយើងអាក្រក់ ចុះបើយើងពោលតែពាក្យភូតកុហាក មិនឱ្យគេថាយើងអាក្រក់ដូចម្តេចបាន ។

៙ យើងជាមនុស្សកុំខ្លាចមនុស្សមានវិជ្ជា ដូចមច្ឆាពឹងគង្គាជាទីស្ថានតែគួរ គិតខាងផ្លូវចិត្តដ្បិតបុរាណ លោកសន្និដ្ឋានថាកុំអាលទុកចិត្តមនុស្ស ។

៙ យើងចង់ឱ្យគេធ្វើតាមសព្វសារពើ ត្រូវយើងធ្វើការនោះមុនឱ្យកើតសិន ចុះបើយើងធ្វើមិនផែះចេះតែហីន ម្តេចក៏កិនថាគេធ្វើមិនដូចខ្លួន ។

៙ យើងខ្សត់ខ្សោយកុំឱ្យយកស្រេចតែម្តង មុខជាឃ្លាតក្តីបំណងប៉ងប្រាថ្នា ត្រូវគេយកព្យាយាមជួយទៅវិញណា ទើបកិច្ចការមិនអសារសោះសូន្យឡើយ ។

៙ យើងធ្វើល្អគេធ្វើអាក្រក់ហក់មកខ្លួន យើងត្រូវផ្ទួនពោលផ្អែមថែមទៅទៀត កុំរវល់

ពោលពាក្យបៀនបៀត នោះពុតពាលនឹងរវាតឃ្លាតទៅឯង។

៙ យោធាទាហានវៀរបង់សស្ត្រាវុធ ចេញសង្គ្រាមតយុទ្ធទៅពុំបាន ជាតិអ្នកប្រាជ្ញវៀរគម្ពីរតម្រាមាន ពុំអាចថ្លែងបានខានចរចា។

៙ នាយពាណិជវៀរបង់យានរទេះ ទាល់ចំណេះទៅឆ្ងាយពុំបានណា អ្នកនឹងទៅកាន់ប្រទេសទីនានា វៀរយាននឹងយាត្រាទៅពុំបាន ។

៙ យោធាស្រុះគ្នាធ្វើហត្ថកម្ម ជីកគាស់ដីដាំយកផ្កាផ្លែ ធ្វើថ្នល់ធ្វើស្ពាន កាប់រានស្រែនេះឯងទាហានខ្មែរសន្តិភាព ។

៙ គ្មានកាប់គ្នាចាក់គ្មានសរសន់ ទៅលួចទៅប្លន់ធុនចោកទាប កាន់ច្បាប់អន្តរជាតិផ្ទេរាប មានភាពថ្លៃថ្នូរអម្បូរខ្ពស់ ។ (សុង-ស៊ីវ)

៙ យោធិនជារបង ខំឃុំគ្រងជាតិសាសនា ព្រមទាំងព្រះមហាក្សត្រា កុំឱ្យសត្រូវយាយីទោះមានខ្មាំងសត្រូវ ខ្លាំងម្ដេចកូវគ្រប់ទិសទី ស៊ូតែប្ដូរជីវិត ធ្វើសង្គ្រាមឈាមក្រាលដី។ (ជុំ មួង)

៙ យោធិនជាតិខេមរា បើត្រូវការធ្វើសង្គ្រាម ស៊ូតែប្ដូរសាច់ឈាម បូជាជាតិក្សត្រសាសនា បើស្លាប់ក្នុងចម្បាំង គ្មានភ័ន្តភាំងស្ដាយជីវ៉ា ព្រោះបានជួយរដ្ឋា ស្លាប់ពីខ្មែរកើតជាខ្មែរ ។ (ជុំ មួង)

៙ យោធិនយកកំណើតកើតជាខ្មែរ ជាតិខ្លាំងពូកែផ្នែកអាស៊ី ត្រូវខំធ្វើការខំសាមគ្គីបំពេញនាទីពូជអង្គរ។ (សុង ស៊ីវ)

★ ★ ★

## រ

៙ រកស៊ីនឹងក្តិតដូចពីងពាង ។

៙ រកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក។

៙ រកស៊ីយប់ដូចខ្វែក ។

៙ រកស៊ីទុកក្តាររំពឹងក្អែង សត្វក្ដាមពពងប្រកោងស្មៅ អ្នករកស៊ីជួញអាងដង្ហៅ រៀបចំកូនចៅអាងប្រពន្ធ ។

៙ រងាផល្គុន ភ្លៀងធ្លាក់ប្រាំមុន លួជាអាក្រក់ ធំទៅជាតូច ពាលឡើងយសស័ក្តិ មិនខំបានប្រាក់ ឈើក្រាក់ដុះត្រួយ ។

៙ រង៉ាប់រងើដូចពុលក្ដួច ។

៙ រងាវតែក្នុងព្រៃ ឬ(បានតែរងាវក្នុងព្រៃ) ។

៙ រងាវឱ្យតែគេស្ដាប់ រួចជុះអាចម៍ដាក់បង្គងឯង។

៙ រងើពកថ្ងាស ។ ៙ រងីរងើដូចរាហូកន្លង ឬដូចគ្រោះកន្លង។

៙ រដិបរដុបដូចផ្លែក្រសាំង។ ៙ រដិបរដុបដូចអាចម៍សេះ។

៙ រត់ផាសក្រញាំ។ ៙ រត់ផាសកែង។

៙ រត់បាតជើងសព្រាត។ ៙ រត់ឥតអំពើ ដើរអំណត់ចម្រើនជាង។

៙ មនុស្សបាក់ត្រង់ណា ល្មិតស្មៅត្រង់ណោះ។

៚ រទេះសេះដំរី រាប់បញ្ជីកុំឱ្យឃ្លាត ខ្ញុំណាមានមារយាទ ទុកដាក់ដៃឱ្យរក្សា។

៚ រទេះបាក់មិនគិត ទៅគិតឯគោលួចដាំង។

៚ រទីសរទាស ដូចរាស្រ្តឥតស្តេច។

៚ រនាបបាក់គ្រាន់នឹងជួស តែសម្ដីថាហួសមុខជាបង់ប្រាក់។ ឬ(តែសម្ដីហួសកំពុបប្រាក់) ឬថាតែសម្ដីហួសមុខជាបង់ប្រាក់។

៚ របស់ព្រះ បូជាព្រះ។

៚ របាំងបង់លេងលង់ប្រាំថ្ងៃ ជាមន្ទិលគឺដៃខុសលំអាន នាយខ្មាន់ធ្នូបង់ បាញ់កន្លង់បាន ប្រាំពីរថ្ងៃក៏មានមន្ទិលភ្លាត់។

៚ ប្រពន្ធល្អបង់ប្ដីលង់មួយខែ ជាមន្ទិលគឺប្រែចិត្តព័ទ្ធ សិស្សបង់ការសិក្សាក្នុងវត្ត កន្លះខែក៏ភ្លាត់ការសិក្សា។

៚ រលំមិនបាច់ច្រាន បានមិនបាច់ខំ ឬ(រលំបាច់អីច្រាន)។

៚ រលាក់រលើដូចឆ្នួតលេលា។

៚ រសាត់ដូចចក។

៚ រស់នៅថាអាក្រក់ ស្លាប់បាត់មុខថាល្អ។

៚ រស់ក៏គាប់ងាប់ក៏គួរ ។ ៚ រពឹសដៃផ្ទៃឆ្អែត ។

៚ រស់នៅធម្មតា អ្នកប្រាជ្ញពោលថា មិនគាប់ប្រពៃ លុះតែប្រឹងប្រែង ទុកកេរ្ដិ៍ស្នាដៃទុកប្រាជ្ញាថ្លៃ ទើបរស់បានផល ។

៚ រស់ទុកដូចជាស្លាប់ គឺជនអាប់អន់អប្រិយ មិនធ្វើប្រយោជន៍ពីរ ដ៏ជាទីគោរព ឡើយ។

៚ របស់អ្វីមិនស្មើចិត្តដែលនឹក មុតអ្វីមិនស្មើទឹកហូរជោរជន់ ធ្ងន់អ្វីមិនស្មើព្រះគុណធ្ងន់ ធន់អ្វីមិនស្មើប្រពន្ធប្រើ។

៚ របស់អ្វីមិនស្មើចិត្តដែលគិត ពិសកាចអ្វីមិនស្មើពិសពាលា ជួបអ្វីប្រសើរមិនស្មើជួបពុទ្ធា រសពិសាអ្វីមិនស្មើរសព្រះធម៌ ។

៚ របស់តែពាក្យ ត្រគាកស្លាប់ស្លូក ឬ...ស្លាប់ឈឹង។

៚ រឡឹករឡក់ដូចទឹកន្លះក្អម ។

៚ រឡេះរឡោះដូចកូនក្មេង ។

៚ រាជសីហាប្រាថ្នាភស្តុចំណី ដេកស្ងៀមនៅដីហាមាត់ចាំ ឱ្យម្រឹគដើរចូលមាត់ទើបខាំយ៉ាងនេះរាល់ឆ្នាំក៏គ្មានឆី ។

៚ រាជទសពិធលម្អស្តេច ស្តមដោយស្មាធ៍កិច្ចល្អតសី សិក្ខាបទលម្អសង្ឃព្រះជិនស្រីប្រុសកាឡីលម្អដោយវិទ្យា ។

៚ រាជហង្សនៅក្នុងហ្វូងក្អែក រាជសីហ៍ចូលសែកនៅក្នុងហ្វូងគោនានា អាជានេយ្យនៅក្នុងហ្វូងលា អ្នកមានប្រាជ្ញនៅក្នុងពួកពាលសាមាន្យ។

៚ រាជអាមាត្យគួរគិតក្នុងចិត្តច្នេះ ថាព្រះរាជានេះមិនមែនជាមិត្រស្និទ្ធមិន មែនជាញាតិសាច់សាលោហិត ព្រះអង្គពិតជាម្ចាស់នៃអាត្មា។

៚ រាជសីហ៍ដំរីសប្បុរសផង ប្រទេសសៅហ្មងនាំអន្តរាយ សឹងលះបោល ទីនោះទៅ

មិនស្តាយ ស្វែងរកទីសប្បាយចម្រើនប្រាណ។

៙ រាជសីហ៍សត្វខ្ពស់ទោះអត់ឃ្លាន ក៏ពុំបានបរិភោគស្លឹកឈើស្មៅ ឈ្មោះសីហោទោះស្គមទ្រមហ្មងសៅ ស៊ូអត់នៅមិនស៊ីសាច់ដំរី។

៙ រាត្រីវៀរព្រះច័ន្ទមិនសោភា សាគរវៀររលកមិនសោភី បោក្ខរណ៍វៀរហង្សពុំពិសី នាងកញ្ញាវៀរប្តីពុំពិសេស។

៙ រាត្រីពុំមានព្រះចន្ទ្រា មេឃាងងឹតឥតរង្សី សមុទ្រឥតរលកបោកប្រក្រតី រាសសូន្យស្ងាត់បាត់ខ្ញុរខ្ញារ។

៙ ស្រះស្រង់ឥតហង្សចុះវារី បាទីប្រៀបដូចឥតបរិពារ កញ្ញាឥតប្តីគ្រងព្យាបាល អាការនាំកើតឱ្យគេគៀរ។

៙ រាល់រូបទាំងស្រីប្រុស ចង់រស់ជន្មជីវិត គួរជឿគម្ពីរពិត មិនគួរគិតជឿអាគម។

៙ វីគ្រូបាធ្យា ប្រដូចនឹងម្តាយ អាពុតឯងហោង។

៙ វីនឹងចេះឯង ដូចអ្នកវង្វេង កណ្តាលអាធ្វា ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា ចរចេញយាត្រា ឥតអ្នកដឹកដៃ។

៙ វីជោគវាសនា របស់ជនណា មិនដែលជួយកែ កំណើតជននោះ ឱ្យផ្លាស់រូបប្រែ សម្រាប់ចំណាំ កត់កាលវែងខ្លី រត់លឿនទៅមុខ ទុកសត្វលោកិយ សល់តែអដ្ឋី ធាតុកលោកកា។

៙ វីការសិក្សា ចំណេះវិជ្ជា ផ្លូវធម៌ផ្លូវលោក បីដូចកូនសោ ធ្លាក់ទ្វារឃ្លាំងភោគ សម្បត្តិគរគោក ក្នុងនាលោកិយ។

៙ រីទ្រព្យសម្បត្តិ ត្រូវតែប្រយ័ត្ន កុំឱ្យអន្តរាយ បានច្រើនចាយតិច កុំឱ្យខ្ជះខ្ជាយ តែចាយពាលងាយ ធ្លាក់ខ្លួនក្រីក្រ។ (ជុំ មួង)

៙ រីអ្នកប្រដៅដូចស្ទូនឆ្នាំង តែងតាំងច្របាច់ដីបែកខ្ចាយ ដីល្អញធ្វើបានមិននឿយឡាយ ដាំបាយអាស្រ័យរាល់វេលា។

៙ រីឯវិជ្ជានាលោកិយ ប្រយោជន៍សិរីសួស្តីជា នឹងជួយឱ្យមានទ្រព្យនានា ក្សេមក្សាន្តសុខាក្នុងលោកនេះ។

៙ រីអ្នកខ្លាចស្លាប់ គាប់ពុំហ៊ានពុះពារ ក្រែងមានថ្លស់ឆ្លោយ ដល់ក្ស័យជីវ៉ា ត្រូវលះភរិយា ទើបជាតិថ្កើងថ្កាន។

៙ រីឯស្រីជាភារិយា ទុកជាមេម៉ាយក៏ល្អពិត បើជាក្រមុំអស់ពីចិត្ត គំនិតមិនបានក៏មិនស្រួល។

៙ រីឯប្រពន្ធយ៉ាងល្អឯក គាប់ភ្នែកខ្លួនឯងនឹងអ្នកផង អ្នកជាស្វាមីត្រូវឃុំគ្រង កុំបីរំលងការរក្សា ។

៙ រីពួកទាហាន សេនាថ្កើងថ្កាន រហ័សក្លៀវក្លា បើគ្មានថ្វីដៃ ឥតជ័យចេស្តា ពុំរាប់ហៅថា ជាទាហានឡើយ ។

៙ រីឯមូលពឹងក្រឡឹង រីឯត្រង់ពឹងបន្ទាត់ កិរិយាពឹងសំពត់ អ្នកបរិសុទ្ធពិតពឹងសីល។

៙ រីមនុស្សសប្បុរស សម្តីមិនខ្ពស់ ពីពាក្យសច្ចា ទោះត្រូវអាក្រក់ ឬល្អយ៉ាងណាពោលតែសត្យា បានការជានិច្ច។

៙ រីរបស់អ្វីថ្មី ក្នុងភពផែនដី ក្រោមដួងសូរិយា មិនដែលមានសោះ ពីព្រោះលោកថា

ថ្មោងថ្មីយ៉ាងណា កើតមកពីចាស់ ។

៙ រឹងដូចដែក ឬ(ចិត្តរឹង ឬមាត់រឹងដូចដែក) ។

៙ រុក្ខជាតិត្រូវពត់ពីតូចតាច មនុស្សជាតិគេអាចពត់ពីក្មេង សិក្សាវិជ្ជាត្រូវខ្នះខ្នែង ឱ្យចាំជាក់ស្ដែងពីដំបូង ។

៙ រុក្ខាខ្ពស់ធំ វាយោប្រជុំ បោកបក់ខ្លាំងក្លា រលំលាន់ឮ សព្វព្រៃព្រឹក្សា សូរសព្ទលោកា ជាងស្មៅជើងក្រាស់ ។

៙ រូបគេឯងតែងមានកម្មប្រចាំកាយ ប្រចាំកិតតតឃ្លាតឆ្ងាយណាយក្ដីល្ហែបើម្លឹងៗ ប្រឆាំងខ្លាំងពូកែ ទទូចតែឈ្នះប្រកែកនឹងកម្មឯង ។

៙ រូបគេឯងស្វែងរកយកជ័យជំនះ បើបានឈ្នះដូចបំណងប៉ងប្រាថ្នា នោះនឹងបានសាន្តសុខសព្វគ្រប់ប្រការ ហេតុនេះហើយគេប្រាថ្នារកការឈ្នះ។

៙ រូបសព្វរស់ដោយអាហារពិត ថាបើមិនគិតរកចំណេះ តែរោគរឹតរុំពុំរបេះ មុខជាលិទ្ធផែះពុំលែងឡើយ ។

៙ រូបរាងសខ្មៅ លោកមិនសំដៅ យកជាប្រមាណ ប៉ុន្តែឯចិត្ត ជាដួងវិញ្ញាណ ល្អក្ររកបាន ទើបគាប់ប្រសើរ ។

៙ រូបរាងនៃស្ត្រីជារបស់ វិជ្ជានៃបុរសជាទ្រព្យ សីលនៃភិក្ខុសង្ឃភោគា កម្លាំងនៃរាជាជាភោគោ ។

៙ រួចបាត់ថាត្រីរ៉ស់ បានទាំងអស់ថារន្ទត។

៙ រៀនរិះសារពើក្ដី ទោះស្រដីកាន់ពាក្យសត្យ។

៙ រៀនសិល្បសាស្ត្រកុំរាន់បន្ទាន់ញាប់ ស្វែងទ្រព្យសន្សំកុំខំខ្លាំង ឡើងភ្នំសន្សឹមកុំប្រណាំង សេពកាមតាមកម្លាំងតិចៗវ៉ា។

៙ ខឹងឃោតិចៗកុំឱ្យស៊ុន កាមគុនទាំងប្រាំជាមាត្រា សន្សឹមតិចៗមើលកិរិយា តម្រាសន្សឹមកុំបោល។

៙ រៀនរិះរូសរវាំង ធ្វើស្រែប្រាំងស្រែវស្សា (ធ្វើស្រែមានចំណារ ធ្វើចម្ការចាររបង)។

៙ រៀនរិះរក្សាគ្រង យកចេញចាយដោយរដូវ ។

៙ រៀនស៊ីឱ្យល្មមកុំពមល្មោភ កុំលេបរំលោភឫកដូចប្រេត តែស៊ីច្រើនពេកច្រើនកើតហេតុ ស៊ីហួសពីឆ្អែតខានធ្វើការ ។

៙ រៀនច្បាប់ឱ្យល្អិតកុំឱ្យឆៅ ចេះល្អិតក្នុងក្រៅអ្នកខ្លៅខ្លាច មនុស្សមានចំណេះមានអំណាច ចង់ឈ្នះមនុស្សកាចកុំស្ដីកោង ។

៙ រេចទាំងលើរេចទាំងក្រោមដូចត្បាល់កិន ។

៙ រោគរោមកាយា ថ្កើងឯគ្រូពេទ្យ ។

៙ រោគឃ្លាននាំមនុស្សហ៊ានលួចប្លន់ ស្រឡាញ់ពេកពន់ហ៊ានសម្លាប់ ស្វាមីភរិយាត្រូវតាមច្បាប់ ទាល់ច្រកប្រចាប់ហ៊ានតដៃ ។

៙ រោគអ្វីមិនស្មើរោគឃ្លាន ទានអ្វីមិនស្មើទានធម៌ទេសនា មានអ្វីមិនស្មើមានបញ្ញា ថ្លាអ្វីមិនស្មើចិត្តជាបុណ្យ។

៙ រោគត្រូវមានឱសថកែ កើតទុក្ខចិត្តប្រែធម៌ជាថ្នាំ ពេលក្រលំបាកខន្តីទ្រាំ ចិត្តពោលប្រាជ្ញផ្ដាំគ្មានថ្នាំកែ។

ៜ រោចគល់រញ្ជួយដល់ចុង ។

ៜ រំងាប់ជនកំណាចដោយប្រហារ រំងាប់មិត្រឧចារដោយកុំស៊ី រម្ងាប់ស្រីដោយកុំឱ្យអ្វីៗ រម្ងាប់រោគដោយក្តីបន្ថយបាយ។

ៜ ឫកពាសុភាព សម្តីរាបទាប ស្គាល់ចាស់ព្រឹទ្ធា អ្នកផងសរសើរ រាល់មាត់គ្រប់គ្នា សម្បូណ៌លាភា គេក្តីឈ្មោះថ្កុំថ្កើង ។ (ជុំ មួង)

ៜ ឫក្សជតាក្រៃណានឹងពន្យាកំណើត ។

ៜ ឫកក្រអឺតដូចអាចម៍ត្រូវថ្ងៃ ឫ(ធ្វើឫកក្រអឺត...)។

ៜ ឫស្សីមួយដើមគង់ផ្សេងថ្នាំង បងប្អូនត្រឡាំងគង់ផ្សេងចិត្ត ។

ៜឫស្សីធ្វើក្លាក់ដាក់គ្មានថ្នាំង គងស្គររគាំងវាយមិនឮ សុរិយាមិនយកជាពន្លឺ អួតក្លី អពិលអំពែកសត្វ ។

ៜ ឫស្សីអាងបន្លាការពារខ្លួន ប្រាជ្ញអាងច្បាស់ក្បួនការពារខុស មនុស្សល្ងង់គ្មានអាងអ្វីទាំងអស់ អាងតែឈ្លោះតទល់កម្លាំងបាយ ។ (សុង ស៊ីវ)

ៜ ឫស្សីសីលា ខំប្រឹងភាវនា ចម្រើនកម្មដ្ឋាន ហោះហើរវេហាស៍ ដោយកម្លាំងឈាន មិនសង្រួមប្រាណ ដាច់ឈានដើរដី។ (ជុំ មួង)

**មនុស្សចាស់ស៊ីអំបិលច្រើនជាងក្មេងស៊ីអង្ករ**

**គង់ស្គាល់អាក្រក់ល្អច្រើនជាងក្មេងៗ**

ស្រង់ចាកសុភាសិត សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា (**ខជិរប្បញ្ញោ លី ឯម**)

# ល

៚ លលេងកូនក្មេងគង់អាប់យស លលេងនឹងពស់គង់ចឹកផ្សា លលេងអ្វីៗគង់គេថា លេងស្រីលេងស្រាគង់ឆ្កួតចិត្ត។

៚ លង់ទឹកប្រាក់នាំឱ្យខ្វាក់ថ្លង់ហ៊ានលះបង់ច្បាប់ ចេះដឹងចំណាប់បែជាល្ងង់ល្ងើឫក ថោកទាប ហ៊ានយកឋានៈមុខក្រសួងខ្លួនទៅប្តូរលោភ ឱ្យជនថោកទាបវាយប្រាក់ទិញខ្លួនបាន ។

៚ បុគ្គលបែបនេះសំគិលណាស់គ្មានខ្មាសអៀន បើទុកជាមានប្រាក់រាប់លានមិនថ្កើងថ្កាន ថោកដល់កូនចៅដែលគ្មានមកកើតទាំងប៉ុន្មានញាតិព្រៀងលានគេដៀលថាកូនេះរស់ព្រោះសំណូក ។ (សុង ស៊ីវ)

៚ លាក់តែមុខ គូថនៅកណ្តាលវាល។

៚ លាក់តែមុខដូចពង្រូល។

៚ លាភណាស់លោកណាបានកើតមក កុំជ្រកក្នុងស្នូកដូចអណ្តើក តែភ្លើងព្រៃរោលរត់កក្រើក របើកស្រកាផ្ការចង្រ្កាង ។

៚ លិចកញ្ឆែងលង់កញ្ឆើ ។

៚ លិចកណ្តោងដី ឬលិចកណ្តោងផ្លុះ។

៚ លិចទាំងជង់លង់ទាំងកុក លិចទាំងអ្នកស្រុក លក់ទាំងអ្នកដំណើរ ឬ(លាញទាំងអ្នកស្រុក) ។

៙ លិចសឹមលោត ដល់កំប៉ូតដឹមតោង។

៙ ឮផ្គរឱ្យមើលខ្យល់ ក្ដីពុំយល់កុំអាលក្រោធ។

៙ ឮផ្គរកុំអាលចាក់ទឹក (បំពង់) ចោល។

៙ ឮផ្គរឱ្យមើលខ្យល់ ក្ដីអម្ពល់កុំអាលក្រោធ។

៙ ឮតាមមាត់ចាបមាត់ព្រាប។

៙ ឮស័ព្ទសូរធ្ងន់ស្រាលកុំអាលស្លុត មិនមែនសុទ្ធតែសូរស័ព្ទកាំភ្លើងទេ ទោះម្ដេចម្ដាឱ្យពិនិត្យគិតគ្នាន់គ្នេរ ត្រិះរិះរេរកជ្រៅរាក់ឱ្យជាក់សិន។

៙ លូកប្រហុក លូកឱ្យកប់ក្លៀក ឬ(លូកឱ្យកប់ដៃ)។

៙ លួចគេវាធ្លាប់ដៃ ដេកថ្ងៃវាធ្លាប់ភ្នែក។

៙ លួចគេវាគ្រាន់ ដល់ពេលគេទាន់វាក្រៃល។

៙ លើកដាក់តាមកម្លាំង កុំភើចចាំងឈើជាលស្នា ឬ(ប្រស្នា)។

៙ លើកស្នារំអាក្អែក ។

៙ លេចឮកិត្តិស័ព្ទខ្មែរដ៏ខ្ពង់ខ្ពស់ពេញផ្ទៃលោក ជាមហាជោគក្នុងសតវត្សទី១៩នៃគ.ស ដោយបារមីព្រះនរោត្តមសីហនុដ៏បវរ សត់អធីករណ៍ជនជាតិលាវដោយសន្និសិទក្រុងហ្សឺណែវ។ (សុង ស៊ីវ)

៙ លេចលើស្មើក្រោម ។

៙ លេងនឹងក្មេងវាអាប់យស លេងនឹងពស់វាខាំដៃ លេងនឹងចាស់វាចង្រៃ ឬ(លេង

ក្មេងអាប់យស លេងពស់ខាំដៃ)។

៙ លេងច្រើនៗឈ្លោះ ។

៙ លេខមួយមានប្រាំនាក់មិនបាន បទនេះជាស្ថានពិចារណា មិនងាយបានស្រួលក្នុងលោកា ទ្វីបមួយសុរិយាប្រាំឆេះកប្ប។

៙ លេបទៅវាស្លាក់ ខ្ទាក់ទៅវាស្លែង។

៙ លោកធ្វើមាត់មួយម្រាមដៃដប់ សង្ខារប្រាប់ព្វសត្វប្រដៅ ត្រូវដៃធ្វើការជាងចៅរៅ មិនត្រូវនៅស្ងៀមកើតជាមនុស្ស ។

៙ លោកនេះសម្បូរណាស់ឧបាយ កិច្ចកលលៃបខាយខាងមិនពិត ខ្លួនឥតមារយាឃ្លាតគំនិត ខ្លៅមួយជីវិតគិតមិនលេច។

៙ លោកិយគរគោកខាងមុខការ វិចារណ៍មិនចង់មិនចេះល្អិត ធ្វេសមិនប្រមូលខានចូលចិត្ត ខុសក្រឹត្យក្រមច្បាប់អាប់រាសី។

៙ លោភពេកវាយបែកពោះ។

៙ លំបាកខ្លួនប្រាណទើបស្គាល់ធម៌ លំបាកនគរទើបប្រពៃធ្លង វដ្តសង្សារលំបាកក្រៃគប់ពាលចង្រៃលំបាកលើស។

៙ លះបង់កិច្ចចំណាប់ ស្រវាចាប់កិច្ចមិនពិត តែងតែឆ្លោយគំនិត ក្តួលក្តៅចិត្ត នឹកស្តាយក្រោយ។

៙ លះមនុស្សមិនប្រឹងប្រែង មិនខ្នះខ្នែងក្នុងកិច្ចការ ច្រើនក្រោធខឹងសំបា ព្រោះជាការនាំលិចខ្លួន ។

៙ លះទុក្ខប្រាថ្នាស្រណុកខ្លួន ត្រូវប្រឹងមាំមួនខ្លាំងកន្លង សិក្សាវិជ្ជារកទ្រព្យផង ទើបឆ្លងចាកទុក្ខបានសុខស្រួល។

៙ ល្មមទៅល្មមខាន ល្មមដើរបំពាន កុំគិតត្រង់ងាយ ល្មមគិតបង្អង់ ល្មមខានទៅអាយ ក្តីក្រកុំស្រាយ ក្តីងាយកុំធ្វេស ។

៙ ល្អមើល មិនល្អស៊ី។

៙ ល្អតែរូបម្លូបមិនបាន ឬ(ល្អតែមាឌមារយាទមិនបាន) ។

★ ★ ★

# វ

៙ វក់នឹងល្បែងតែវិនាស (ងប់នឹងល្បែងតែវិនាស ឬ……តែងហិនហោច)។

៙ វក់នឹងអាភៀន តែងញៀនជាប់។

៙ វត្តមួយសង្ឃរាជពីរទីមិនស្អាត លោកធាតុមួយមានព្រះអាទិត្យបី នគរមួយស្តេចច្រើនអធិបតី អ្នកប្រាជ្ញគប្បីដឹងដោយឧបមា។

៙ វត្តអត្តាវាចាចិត្ត ឱ្យសុចរិតឥតទាក់ទាម បាបបាត់បុណ្យបានដោយព្យាយាម អាចសន្មតនាមហៅមេធី។

៙ វរៗឆ្កែទរប្រហុកអស់។

៙ វ័យបឋមឱ្យខំរៀនវិជ្ជា វ័យទីពីរខំឧស្សាហ៍រកធនធាន វ័យទីបីស្វែងធម៌បម្រុងប្រាណ វ័យទីបួនក្បួនគ្មានឱ្យធ្វើអ្វី។

៙ វល្លិបណ្តូលពេចរសល្វីងក្តាត់ ស្កររអាចស្បាត់បានរសឱជា ឯជនជាតិបាបចិត្តពាលាបើសេពមេធាចិត្តជាភ្លាម។

៙ វាចាត្រជាក់មិត្រជុំចម្រើននៅ វាចាក្តៅមិត្រក៏ឃ្លាតប្រាសចាកមិត្រ ត្រជាក់ក្តៅដូចព្រះចន្ទនិងព្រះអាទិត្យ ហែបបណ្ឌិតគួរដឹងឱ្យឧបមា។

៙ វាយពស់ឱ្យក្អែកស៊ី។

៙ វាយឱ្យយំ ខំបញ្ចុកចេក។

៙ វាយអារស់ អាងាប់ស្រែក។

៙ វិជ្ជាទុកជាមិត្រ លោកិយពិត ពេញថ្កើងថ្កាន បរលោកក៏ក្សេមក្សាន្ត សុខសម្រាន្ត បានជាពូជ។

៙ វិជ្ជាឧត្តម ទោះធ្លាក់ទៅធំ មនុស្សទាបសក្តា គួររៀនគ្រប់បទ ស្រីរតន៍ទុកជា វង្សទាបយ៉ាងណា ក៏គួរចិញ្ចឹម។

៙ វិជ្ជាពិសេសលើសទ្រព្យធន ចោរមិនអាចប្លន់លុកលួចបាន វិជ្ជាគ្មានថ្លៃនឹងប្រមាណ ប្រើចេះតែបានគ្រប់វេលា ។

៙ វិជ្ជាមិនដែលកើតឡើងឯង ដោយឥតគេស្វែងរកប្រាថ្នា ទ្រព្យធនមិនកើតដល់អ្នកណា ដែលគ្មានឧស្សាហ៍ខំប្រឹងរក។

៙ វិជ្ជាអាជីពការជួញប្រែ កើតផលមកតែពីគំនិត ថាបើដង្ហៅខ្លៅឥតគិត នោះពិតជាពោះរស់ពីបាយ ឬ(នោះពិតជាពោះរស់ពីបាក)។

៙ វិជ្ជានិងវ័យនៃមនុស្ស មិនគួរឱ្យខុសជំនាន់គ្នា វ័យច្រើនត្រូវចម្រើនវិជ្ជា ទាំងពីរស្មើគ្នាទើបប្រពៃ។

៙ វិជ្ជាចំណេះ ដែលយើងចាំចេះ រួចស្រេចពេលណា ត្រូវទូន្មានគេឱ្យចេះផងណ៉ា ទាំងតែងទុកជា ក្បួនតកូនចៅ។

៙ វិទ្យាទុច្ចរិត នាំអ្នកប្រព្រឹត្ត ឱ្យដើរខុសផ្លូវ ចាកគន្លងធម៌ ដែលល្អត្រឹមត្រូវ នាំឱ្យអាស្រូវ អន្តរាយអាត្មា។

៙ វិធីហ្វឹកខ្លួន ថៃទាំមាំមួន ព្រួយប្រាណអាត្មា នៅតែខ្លីជាង សព្វសិល្បវិជ្ជា ច្នេះត្រូវសិក្សា រៀបរៀនចេះឆាប់។

៙ វិស័យចិត្តល្អក្រខ្លួន មើលក្បួនលំអានបុរាណប្រាម ការខុសចោលទៅការត្រូវតាម ឯកាមគួរកាត់រំលត់ខ្លះ។

៙ វិស័យបុគ្គលមានឧបាយ កែកុននាយអាយកាយត្រឡប់ ធ្វើការបានស្អាតល្អទាំងគ្រប់ ឆាប់ចប់ឆាប់កើតមិនបាច់ព្រួយ។

៙ វិស័យពេលថ្ងៃលម្អអាទិត្យ ពេលយប់ងងឹតលម្អចន្ទ្រា អំពើបាបលម្អពួកពាលា កុសលធម្មាលម្អពួកសប្បុរស ។

៙ វិស័យចេះច្រើនលំបាកគេច ចេះតិចព្រួយប្រាណរំខានគិត ល្ងង់ល្ងើប្រើការដូចងងឹត ឥតបើគិតមិនកើតការនោះឡើយ។

៙ វុឌ្ឍិពរអ្នកនគរតែងត្រូវការ ។

៙ រៀចបានជាកង់ ត្រង់បានជាប្រែក ឬ(រៀចបានជាកុង)។

៙ រៀចវេរមានភ័ព្វអាយុយឺនយូរ ឬ(រៀចវេរ...)។

៙ វៀរចាកអំពើទុច្ចរិត ប្រព្រឹត្តធម៌ល្អសព្វៗថ្ងៃ នឹងបានជាឧបនិស្ស័យ បច្ច័យទៅដល់ព្រះនិព្វាន។ (ជុំ មួង)

៙ វេចសំពាយចាំព្រេងសំណាង អាងតែដុតធូប ។ (សុង ស៊ីវ)

៙ វែងផុតត្រឹមពាក្យសម្តី ខ្លីផុតត្រឹមមិននិយាយ។ (សុង ស៊ីវ)

**អ្នកធ្វេសស្មារតី ស្លាប់គំនិតនោះមិនមានជីវិតរស់នៅឡើយក៏ទុកដូចជាស្លាប់ស្រេចទៅហើយ៖** (ស្រង់ចាកសុភាសិតសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ (**ជោតញ្ញាណោ ជ.ណ**)។

# ស

៙ សក់មួយច្រៀកជាដប់ ។

៙ ស័ក្តិពុំស្មើយស នាមានរបស់ ពុំស្មើសក្កា សូវបង់ទ្រព្យធន កុំខុសអាជ្ញា សូវមានរោគា កុំគ្នាមើលងាយ ។

៙ សង់ផ្ទះតាមចិត្តអ្នកនៅ ។

៙ សង្ខារសព្វសត្វ តែងតែខ្ទាត់ភ្លាត់ មិនដែលទៀងត្រង់ មានរូបអង្គពេញ សោភ័ណសមទ្រង់ បណ្ឌិតខ្លៅល្ងង់ សឹងស្លាប់ដូចគ្នា។

៙ សង្ឃកំពង់សត្វ ។

៙ សង្ឃក្នុងសាសនា ប្រិតត្រៃសិក្ខា ពលរដ្ឋប្រិតច្បាប់ ព្រះរាជប្រិត ទសពិធម៌គាប់ បណ្ឌិតសម្រាប់ បំភ្លឺជនខ្លៅ។

៙ សង្ឃផ្គង់វិន័យ ស្រីផ្គង់មារយាទ។

៙ សង្ឃឥតសន្តោស រាជាមានប្រោស សន្តោសទោសា សំធឹងខ្មាសប្រុស សន្តោសភរិយា នាងកុលធីតា ឥតការកេរខ្មាស។

៙ ជនប្អូននេះមាន ឈ្មោះអន្តរថាន ចុះហៅវិនាស នាក្នុងលោកិយ សិរីឱភាស ពុំមានឱកាស ចម្រើនលោកិយ។

៙ សង្ឃាតសូត្ររៀន កុំធ្វើអៀនប្រៀន ក្នុងចិត្តសព្វថ្ងៃ លំអុតបម្រើ ផ្គាប់ដោយហឫទ័យ បារម្ភមែៗ ក្តីច្បាប់កុំបីបង់។

៙ សង្វាតសរសេរ អស់អញកុំខ្ជិល ទើបបានជាគាប់ សង្វាតសូត្ររៀន ដោយគ្រូប្រញាប់ កុំធ្វើលេបលាប់ ដោយចិត្តមាក់ងាយ។

៙ សង្វាតសរសេរ សូត្ររៀនឱ្យណាស់ ប្រាជ្ញយល់ច្បាស់ នាំញាតិទាំងឡាយយ។

៙ សត្វកើតសត្វងាប់ជាប់កិលេស ប្រហែសសុខហួសជ្រួសសីលម័យយកទុក្ខធ្វើសុខពុំប្រពៃ ត្រាដល់ក្សីណក្ស័យក្តីសុខគ្មាន។

៙ សត្វក្រៀលឆោតភ្លើៗ ទំមែកឈើមិនខ្លាចបាក់ ដើរដីជើងម្ខាងដាក់ ម្ខាងលើកលាក់ខ្លាចផ្កាប់ដី។

៙ សត្វតុកកែស្លាប់ ដោយសារប្រើស។

៙ សត្វស្មោញគួរគ្រាប់ លោកទុកជាច្បាប់ សណ្តាប់អាត្មា កុំត្រាប់ជ្រូកស្រុក នៅក្នុងទ្រុងមារ ដល់ពេលប្រហារ ទើបដឹងខ្លួនស្លាប់ ។

៙ សត្វត្មាតពិតពឹងរុយ សាច់សត្វស្អុយពឹងអំបិល មង្គលព្រាហ្មណ៍ពឹងពពិល រក្សាសីលពិតពឹងទាន ។

៙ សត្វទាំងឡាយកាយតូចស្វិតល្អិតយ៉ាងណា អាចរក្សាការជីវិតឱ្យរស់បាន មនុស្សក្រក្សត់តោយ៉ាកយ៉ាប់អាប់ប៉ុន្មាន កុំគិតស្មានថាមិនចេះយោងជីវិត ។

៙ សន្តានបិតា អាក្រក់យ៉ាងណា កូនតែងតែដើរ ទៅតាមលំអាន ដូចកលផ្លែឈើជ្រុះចុះពីលើ ទើរជិតគល់វា។

៙ សន្សឹមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា។

៙ សប្បាយនឹងល្បែង ហេងស៊យចង់លេង ផ្សងព្រេងវាសនា នឹងកើតទុក្ខក្រោយ

នឹងអស់ទ្រព្យ នឹងកើតនិន្ទា បង់មារយាទគាប់។

៙ សប្បាយធ្វើស្រែ ចម្ការជួយប្រែ នោះមានគេរាប់ សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយនោះគាប់ សប្បាយយឺនយូរ។

៙ សប្បុរសពេកចាញ់ធន នាទុជិនចាញ់ឥន្ទ្រិយ ប្រពន្ធល្អច្រើនចាញ់ប្ដីពាក្យ អប្រិយចាញ់អាត្មា ។

៙ សប្បុរសយល់ដោយមុខ ស៊ុកគ្រលុកពេកពុំជា កំណាញ់ក្រៅតម្រា សោតសឹងអាប់ប្រយោជន៍យស។

៙ សព្វមន្តទាំងឡាយ ពុំបានស្វាធ្យាយ ជាមន្ទិលណា គ្រឹហាទីស្ថាន ពុំបានឧស្សាហ៍ប្រក់ឡើងកាលណា ជាមន្ទិលនៅ។

៙ សេចក្ដីកំជិល កើតជាមន្ទិល ដល់ពណ៌ហ្មងសៅ សេចក្ដីប្រមាថ គឺជាតិសៅដៅជាមន្ទិលនៅ នៃអ្នករក្សា។

៙ សម័យបច្ចុប្បន្នពាលច្រើនភាព សាសនាគួរជ្រាបឱ្យចៀសចេញ វិលចុះវិលឡើងជួបពាលពេញ ខ្ពើមទុក្ខទោសមិញគង់តែជួប។

៙ សម៉មិនដែលទុំ ក្រមុំមិនដែលស្លូត ចង្កូតមិនដែលត្រង់ កំពង់មិនដែលស្ងាត់ មាត់មិនដែលស្ងៀម។

៙ សម្បត្តិហឹនជនព្យាយាមហោច មិនបានប្រយោជន៍យូរអង្វែង ឱ្យបានទៅជារបស់ឯង ហឹនជននឹងថ្លែងពោលច្នេះណា។

៙ បុព្វកម្មប្រធានមានពីព្រេង លាភអឺយចូរឯងវិលមកវ៉ា ទោះហៅយ៉ាងនេះមួយពាន់

គ្រា លាភាមិនវិលមកកាន់ខ្លួន។

៙ អ្នកប្រាជ្ញមិនពោលកម្មវាសនា តាំងតែឧស្សាហ៍ព្យាយាមមុន ថាបើកម្មនោះមិនស្រេចធួន ឥតផលទោសខ្លួននឹងមានអ្វី។

៙ សម្បត្តិនៅស្ថាននាលោកិយ មាសប្រាក់ប្រក្រតីនៅសព្វថ្ងៃ សឹងតែប្រកបទៅដោយភ័យ បាត់បង់ខូចនៃជាអនិច្ចំ។

៙ សម្បត្តិអ្វីពុំស្មើគុណសម្បត្តិល្អ ដែលរកបានដោយកម្រក្រពេកពន់ មានតម្លៃថ្លៃលើសលុបជាងទ្រព្យធន គួរតែគន់គួរតែគិតប្រព្រឹត្តល្អ។

៙ សម្លមិនឆ្ងាញ់ឱ្យតែក្ដៅ ប្រពន្ធខ្មៅឱ្យតែនៅក្មេង។

៙ សម្លាប់មេមាន់យកពងមាស ចិត្តលោភពេញពាសដាសពសុធា ខ្លួនតឿតូចទាបភាពដូចទា ប្រាថ្នាជ្រុលហួសនឹងហឹនប្រាក់។

៙ សមុទ្រជលាស័យមានជោរនាច ផល្លាឈើអាចទុំស្រគាល ដូចចន្ទ្រជួនអាប់ជួនភ្លឺប្រចាល នេះឯងបណ្ដាលពីអនិច្ចំ។

៙ សរសើរតែមាត់ ចិត្តផ្គន្ទា។

៙ សរសើរបាយកាលបាយរលាយជ្រាប សរសើរប្រពន្ធកាលភាពលង់អធិក។

៙ សរសើរពេលត្រូវការ ទុកដូចឆ្មាចាំកណ្ដុរ សរសើរពេលកាល វិលចាកប្រាប់សឹក សរសើរស្រែកកាលដឹកស្រូវមកផ្ទះ។

៙ សាច់មិនបានស៊ីយកឆ្អឹងព្យួរក។

៚ សាច់សដូចចាន មារយាទមិនបានដូចឆ្កែក្រោមផ្ទះ ឬ(ស្រីសដូចចាន...)។

៚ សាត់អណ្តែត សែតអញ្ចង់។

៚ សាបមួយដៃ ប្រៃមួយចឹប។

៚ សាមគ្គីមនុស្សកម្លាំងធំពិត សាមគ្គីបណ្ឌិតកើតវិទ្យា សាមគ្គីរាស្ត្រជាតិមិត្រសុខា មន្ត្រីពាលាមិនហ៊ានប្រមាថ។

៚ សារពើរួសរៀនរិះ ឱ្យចាំចេះៗចាំចែង ចង់គាប់ប្រើស្វះស្វែង រករៀនរិះសារពើក្តី។

៚ សារពើទ្រព្យអ្វីៗ មើលស្រដីទុកឱ្យល្អ អុសទឹកស្រូវអង្ករ យកចេញចាយមានកំណត់។

៚ សិល្បសាស្ត្រមិនចាំមាត់ មានប្រាកដនៅក្នុងក្បួន ដល់ពេលដែលជួបជួន គេសួរសាកពិបាកគេច។

៚ សិល្បសាស្ត្រឯណាមិនស្ទាត់ពិត នៅក្នុងស្លឹករិតឬសៀវភៅ ទ្រព្យធនឯណាដែលមាននៅ ធ្លាក់ទៅដល់ដៃអ្នកដទៃ ។

៚ បើមានកិច្ចការណាដល់មក សិល្បទ្រព្យនោះយកមកអាស្រ័យ ពុំបានដូចចិត្តដ្បិតឆ្ងាយដៃ សិល្បទ្រព្យនោះនៃហៅគ្មានហោង។

៚ សិល្បសាស្ត្រមានពីណាដល់អ្នកខ្ជិល ទ្រព្យធនមានពីណាដល់អ្នកឥតសិល្ប មិត្រឯណាមានអ្នកមន្ទិលឥតធនធាន សុខឯណាមានដល់អ្នកប្រាសមិត្រ បុញ្ញឫទ្ធិឯណាមានដល់អ្នកឥតក្សាន្ត សិវមោក្ខយោគកែព្រះនិព្វាន មានពីណាដល់អ្នកគ្មានបុណ្យកសាង។

៚ សិល្បប្រាជ្ញដ្បិតគ្រូដេរពោលដំរាយ (ពលជាដ្បិតនាយព្រឹសប្រើខះខំ) ឬ(កូនជា

ដ្បិតម្ដាយឪពុកប្រដៅ)។

៙ សិស្សឯណាលោកបៀនរៀនរួសបទ ចាំមិនស្ទាត់មាត់មិនស្ដែងថ្លែងពុំបាន ដូចមនុស្សគយល់សម្ដីដឹងសព្វស្ថាន ថ្លែងពុំបានរំខានចិត្តអិអ៊ះរីយ។

៙ សីលជាស្ពាន ទានជាស្បៀង។

៙ ស៊ីច្រើនៗជុះ លេងច្រើនៗឈ្លោះ ដេកច្រើនៗខ្ជិល។

៙ ស៊ីព្រោះលោះកម្លាំង ឬ(ស៊ីពោះ...)។

៙ ស៊ីនឹងអ្នកណា ត្រូវយកអាសាអ្នកនោះ (ស៊ីបាយអ្នកណា)។

៙ ស៊ីបាយដេកបាយសរសើរ ស៊ីបាយដើរបាយប្រទេចផ្កាសា។

៙ ស៊ីបាយនឹងពន្លឺទៀន និយាយនឹងមនុស្សមាន របៀនសប្បាយស្ដាប់។

៙ ស៊ីបាយនឹងត្រឡោក ផឹកទឹកនឹងរលាជ័ កុំអាលសើចគ្នា ផ្គរលាន់ម្ដងម្នាក់។

៙ ស៊ីត្រង់ណា ជុះត្រង់នោះ។

៙ ស៊ីលៀសរអៀសខ្លួន។

៙ ស៊ីបាយនឹងពន្លឺខ្យល់ និយាយនឹងកំហល់ ប៉ុនគេយកអង្រែបុកដើមទ្រូង ។

៙ ស៊ីសាច់ដាច់មេត្តា សេពសុរាគ្មានពាក្យទៀង។

៙ សឹកដេញអាលបាញ់ ក្ដីជំពាក់ប្រើដោះសា សឹកដល់កុំអាលឆ្លា ឮវាចាកុំអាលយក ឬ(សឹកដល់កុំអាលឆ្លាយ ពាក្យពីឆ្ងាយកុំអាលយក)។

៙ សុនខព្រៃពូកែបស្សាវៈ ចង្កូមនខៈពូកែខាងខ្លា មាន់ជល់ពូកែឆ្នាល់សោតណា គំនិតប្រាជ្ញាពូកែខាងមនុស្ស។

៙ សុភាសិតទុកជាក្រិត្យជាបន្ទាត់ ជាបន្ទាលឱ្យស្គាល់វត្តកិច្ចប្រតិបត្តិ គឺប្រព្រឹត្តគិតប្រិតប្រៀនរៀនប្រយ័ត្ន ជាគ្រឿងហាត់ប្រដៅកាយវាចាចិត្ត។

៙ សុភាសិតជាក្របីស្នែងកែក គឺមនុស្សចិត្តបែកមិនទៀងត្រង់ មិនកាន់តាមធម៌ព្រះពុទ្ធអង្គ លោកឱ្យលះបង់កុំចូលជិត។

៙ សុនខោបែរជាយល់សុនខំ ក៏តាំងកំញើញប៉ងពាធា ជនជួយយល់ជនជួរដូចគ្នា ប្រាថ្នានឹងយាយីគ្នាឯង។

៙ សុសូសាកូនណាខ្វល់ខ្វាយគ្រប់ ប្រៀនរៀនស្ដាប់ចេះដឹងដោយបញ្ញា ធម៌អាថ៌ដែលចេះនោះជួយអាត្មា នាំឱ្យបានស្ថានមហាក្រសេមសុខ។

៙ សូវឱនកុំងើប សូវស្ងៀមកុំថា សូវវាយកុំយារ សូវកាប់កុំផែះ។

៙ សូវកាប់កុំឱ្យជន្ល សូវជេរមេដកទងចោរ កុំឱ្យថានៃវើយ។

៙ សូវនឿយខ្លួនឯង កុំឱ្យបង់ទ្រព្យ សូវបង់ក្ដីគាប់ កុំឱ្យខ្លួនស្លាប់ សូវស្លាប់ទៅជា កុំបង់ធម្មា តវិយាសីលគាប់។

៙ សូវមានទ្រព្យជួយជា កុំធានាណាអ្នកអើយ។

៙ សូវចូលកុំឱ្យចេញ សូវឱ្យទិញកុំឱ្យដូរ។

៙ សូវទូលក្ដីតបាវ កុំឱ្យទូលក្ដីតកញ្ជើ។

៚ សូវបង់ប្រាក់មួយថង់ កុំឱ្យតែបង់ពាក្យសត្យ។

៚ សូវដើរកុំដេក សូវថប់កុំត្រេក នឹងក្ដីប្រហែស សូវខាតកុំពារ ចចើងចចេស សូវចូល កុំចៀស វាសរួចសឹមគួរ។

៚ សូវឱ្យក្រពើលេប កុំឱ្យចង្វាប្របិច។

៚ សូវឱ្យសាច់ កុំបង្ហាញព្រៃ។

៚ សូវបង់ទ្រព្យធន កុំដល់ក្ដីស្លាប់ សូវស្លាប់ទៅគាប់ រសធម៌កុំបីបង់ ។

៚ សូវលើកកុំញោច ចំពាក់កុំបោច ខ្ជិលកុំចងពន្ធ ជាគ្រូអាត្មា កុំឱ្យលោកអន់ សេចក្ដីទម្ងន់ សន្សឹមកុំបោល។

៚ សូវយកសំផឹងធ្វើប្រពន្ធ កុំតែយកប្រពន្ធធ្វើសំផឹង ឬ(កុំយកប្រពន្ធធ្វើសំផឹង)។

៚ សូវបែកក្បាល កុំឱ្យបែកឆ្នាំង សូវដាច់ចង្កាដាំង កុំឱ្យស្រីមើលងាយ។

៚ សូវស្ដួចកុំឱ្យដាច់ គិតការពុំទាន់សម្រេ កុំអាលរន្ធត់ ឬ(កុំអាលរន្ទាន់)។

៚ សូវស្ដួចកុំឱ្យដាច់ បើគង់តិចឱ្យឧស្សាហ៍ រិះរកផ្សំទៀតណា ឱ្យបានច្រើនក្រវើនទុក ឬ(បើវាតិចឱ្យឧស្សាហ៍) ។

៚ សូវស្លាប់បា កុំឱ្យស្លាប់មេ សូវលិចទូកកណ្ដាលទន្លេ កុំឱ្យតែភ្លើងឆេះផ្ទះ។

៚ ស៊ូប្ដូរជីវ៉ា នឹងជាតិអាជ្ញា ឱ្យបានក្ដីសុខ លូតឡាស់ចម្រើន ថ្កើងថ្កានមានមុខ និរភ័យផុតទុក្ខ បច្ចាមិត្រស្ញែង។

៚ សូវធ្វើសង្គ្រាមទើបនាមជាតិល្បី ស៊ូចុះចាញ់ស្រីទើបក្ដីស្ងប់ស្ងាត់ ស៊ូប្រឹងធ្វើការទើង

ស្ពាពរអត្ត ស៊ូប្រតិបត្តិទើងខ្ជាត់មន្ទិល។

៙ សេចក្តីគោរពនឹងរាំងរាទោស សេចក្តីសន្តោសនឹងគុណនានា នឹងការស្តាប់ធម៌តាមកាលវេលា ទាំងប្រាំនេះជាមង្គលឧត្តម។

៙ សេចក្តីអត់ធន់នឹងប្រដៅស្រួល នឹងការទទួលជួបពួកសមណា ការសាកសួរធម៌តាមកាលវេល ទាំងបួននេះជាមង្គលឧត្តម។

៙ សេចក្តីដឹងគុណ ហើយប្រកាសគុណឱ្យប្រាកដ ជានិមិត្តរូបនៃមនុស្សល្អ ។

(**ព្រះធម្មវរោត្តម តុំខ ឈួន ធម្មយុត្តិកនិកាយ**)។

៙ សេពគប់ជនពាលដូចមច្ឆាស្អុយ ចេញចំណាយហុយស្អុយស្លឹកខ្ចប់ អ្នកផងមិនត្រូវចូលសេពគប់ ក្រែងអប់ក្លិនអសោច៍ស្រោចអាត្មា។

៙ សេវកាមាត្យចូលគាល់មហាក្សត្រក្សាន្ត គួររៀរទោសឯស្ថានច្បាប់ខន្តីយា មួយកុំគាល់ឆ្ងាយពេកបាំងនេត្រា ពីរកុំគាប់ជិតទីនាំងអាសន៍។ បីកុំគាល់លើខ្យល់គាល់ព្រះអង្គ បួនកុំគាល់ឆ្ពោះត្រង់ព្រះភក្ត្រម្ចាស់ ប្រាំកុំគាល់លើទួលឬទាបណាស់ ប្រាំមួយគឺខ្ពស់អាសន៍លើម្ចាស់គង់។

៙ កាលចូលគាល់សង្រួមកាយតាមស័ក្តិ អង្គុយថ្នាក់ដាក់ខ្លួនឱ្យសមទ្រង់ ដូចអ្នកចូលជិតភ្លើងកុំភ្លើអង្គ តែភ្លេចកាយភ្លើងគង់រលាកប្រាណ។

៙ សេះជាឱ្យស្ទុះមើលកម្លាំង គោខ្លាំងផ្ទុកឱ្យធ្ងន់បរមើលវា ដឹកដោះរួតឱ្យមើលចុងថនា មេធាឱ្យស្តាប់ស័ព្ទនិយាយ។

៙ សេះដាច់ឱ្យយកសេះតាម។

៙ សំណាបយោងដី ស្រីយោងប្រុស ចង្ក្រានយោងអុស។

៙ សម្អាតអស់សុរិល កុំឱ្យមានក្តីនិន្ទា។

៙ សម្តីពោលចេញ មិនដែលវិលវិញ កាន់អ្នកចរចា ហេតុនេះត្រូវប្រុង ប្រយ័ត្នអាត្មា កុំឱ្យចរចា ថ្លស់ឆ្លោយជាប់កុន។

៙ សម្លេងប្រាប់ភាសា កិរិយាប្រាប់ត្រកូល ឬ(សម្តីប្រាប់ភាសា កិរិយាប្រាប់ត្រកូល)។

៙ សំដីជាឯក លេខជាទោ អក្សរជាត្រី។

៙ សំដីមុតដូចកាប់នឹងកាំបិត។

៙ សំដីដូចចោលដឹងទាំងដង។

៙ សំដីសជាតិ មារយាទសត្រកូល ឬ(មារយាទសពូជ)។

៙ សំពៅពឹងព្រះពាយ អ្នកអភិប្រាយពឹងវាចា រាជសីហ៍ពឹងគុហា សត្វមហឹសាសោត ពឹងស្នែង។

៙ សំឡាញ់ឯណាយកអាសាអាការពំនាក់ ក្នុងកាលថ្នាក់កើតរោគគ្រុនរងាឬស្រុកកើតទុរ្ភិក្សវេទា ឬក្នុងគ្រាអន្តរាយដោយទុក្ខភ័យ។

៙ ឬក្នុងកាលសត្រូវចាប់ប្រហារ ឬក្នុងទ្វារអាជ្ញានៃចៅទៃ ឬស្ថានប៉ាឆាទីខ្មៅព្រៃ សំឡាញ់យ៉ាងនោះ នៃហៅសុមិត្រ។

៙ សំឡេងតាវៅជារូបវា ប្រតិបត្តិភស្តាជារូបស្រី វិជ្ជាការជារូបប្រុសកាឡី អង្គខន្តីជារូបនៃតាបស។

៙ ស្គាល់ឆ្លាតឬល្ងង់ រៀចរេរឬត្រង់ ដោយការចរចា នឹងការសេពគប់ ស្គាល់ភាពសត្វ ឆ្មា ទោះសត្វសឹង្ហខ្លា ដោយការប្រកប។

៙ ស្គាល់ចិត្តប្រុសស្រី អាក្រក់ល្អក្តី ចេញពីដួងនេត្រ ប្រាប់សុខទុក្ខផង បើយើង សង្កេត គង់ដឹងហេតុភេទ ដួងភ្នែកបញ្ជាក់។

៙ ស្តីការមុនក្រោយកុំឱ្យភ្លាត់ កុំអាងតែមាត់មានប្រហោង បើមនុស្សប្រហើនមិនទំនង កុំកោងទល់កើតទោសទាស់។

៙ ស្តេចមិនបានពិនិត្យ ធ្វើតាមចិត្តមិនឧត្តម បណ្ឌិតខឹងមិនសម មិនឧត្តមតាមជាតិ ប្រាជ្ញ ។

៙ ស្តេចកបដោយសំណាង ជាគ្រឿងស្អាងនៃផែនដី វិជ្ជាល្អប្រិមប្រិយ ស្អាងប្រុសស្រី ទាំងអស់គ្នា ។

៙ ស្តេចចូលស្រុកភូមិដែលស្ងាត់ បុគ្គលខ្វាត់ភ្លាត់កុំនៅស្ងៀម ត្រូវស្គាល់ដំណើរឬក មារយាទ ចេញស្មៀតប្រាជ្ញឈ្លាសឬល្ងង់ខ្លៅ។

៙ ស្តេចនិងបណ្ឌិត ផ្ទឹមគ្នានៅនិត្យ គ្រប់កាលមិនបាន ព្រោះស្តេចមានមនុស្ស បូជា រាប់អាន តែក្នុងទីស្ថាន ប្រទេសនៃទ្រង់។

៙ ស្តេចមិនស្អែតសម្បត្តិអាណាខេត្ត ប្រាជ្ញមិនបានឆ្អែតសុភាសិតពុទ្ធដីកា មហា សមុទ្រមិនឆ្អែតស្ទឹងនានា នយនេត្រាមិនឆ្អែតគន់រូបគាប់។

៙ ស្តេចផ្ទំអស់យាមមួយជានិត្យ បណ្ឌិតដេកអស់យាមពីរជាក់ គ្រហស្ថដេកអស់ យាមបីភ្ញាក់ ពួកយាចកដេកលក់អស់យាមបួន។

៙ ស្ដេចមានពលច្រើនជាអំណាច តែពុំអាចនឹងផ្ចាលផ្ចាញ់សត្រូវ នឹងធ្វើអ្វីដោយតេជៈកំដៅ ដូចភ្លើងធ្លាក់ក្នុងរណ្ដៅរលត់ឯង។

៙ ស្មារតីខ្ចាប់ខ្លួន គំនិតប្រុងខ្លួន មិនសង់ប្រទេស ត្រួតត្រាចិត្តឯង មិនមានប្រហែលទើបចិត្តមិនធ្វេស ធ្លាក់ទៅអបាយ។

៙ ស្ទឹងទាំងឡាយមានខ្សែទឹកវៀចវង់ ព្រៃសឹងដំហើយដោយឈើផង ស្រីបានឱកាសស្ងាត់ជាម្ដង អាចកន្លងធ្វើបាបក្នុងទីស្ងាត់។

៙ ស្នូនឆ្នាំងដំសំពង ក្អមឆ្នាំងប៉ងឱ្យបានល្អ គ្រូហាត់ទោះវាយជេរប៉ង ឱ្យតែចេះសិល្បសាស្ត្រ ។

៙ ស្រមោចនឹងស្ករ។

៙ ស្រមោចរូបតូចមែនពិត តែសាមគ្គីចិត្តសម្លាប់បាន មេអំបៅដង្កូវធំរូបប្រាណជនកល្យាណគួរយកតម្រាប់តាម។

៙ ស្នេហ៍កាមបឋមសប្បាយប្លែក ដល់ក្រោយដេកស្រែកយំទុក្ខសោកជាតិ អាហារល្វីងបាយច្រកដោក ឆ្ងាញ់តាមបយោគក្រោយហើមពោះ។

៙ ស្នេហ៍មិនស្មើស្និទ្ធ ឬ(ស្នេហ៍មិនឈ្នះស្និទ្ធ)។

៙ ស្រដីនឹងអ្នកផង ពាក្យឱ្យគួរកុំឯងវ៉ី។

៙ ស្រដីឱ្យស្រួលស្រេច គិតសេចត្រេចកុំគិតងាយ រំពឹងគិតឱ្យឆ្ងាយ យល់ដោយផ្លូវសព្វនានា។

៙ ស្រវឹងបុណ្យ។ ៙ ស្រវឹងយស។ ៙ ស្រវឹងមាទ។

៚ ស្រឡាញ់កូនមួយតៅ ស្រឡាញ់ចៅមួយថាំង។

៚ ស្រឡាញ់ខ្លួនឱ្យស្ងួនចំណី ស្រឡាញ់ប្ដីឱ្យថ្នមចិត្ត។

៚ ស្រឡាញ់កុំសូមទ្រព្យប្រសើរ ពីភ្លើពួកបក្សនាំខូចចិត្ត ប្រៀបយកព្រះខ័នតម្រង់ពិតត្រង់គួរគិតក្ស័យជីវ៉ា។

៚ ស្រឡាញ់ណាស់ប្រែស្អប់ បុត្រល្អសំណប់ ថ្នមហួសខូចខុស ស្រឡាញ់ភរិយាប្រចណ្ឌសាយសុស ស្រីដែលស្អប់ប្រុស ច្រើនឆាប់បានប្ដី។

៚ ស្រឡាញ់ពេញប្រាស ស្អប់ណាស់ជំពប់លើ។

៚ ស្រឡាញ់ផ្លែឱ្យថៃគល់។

៚ ស្រឡាញ់កូនគេវាបង់ចំណី ស្រឡាញ់ប្ដីគេវាបង់ចិត្ត។

៚ ស្រឡាញ់ម៉ែឱ្យថៃកូន ឬ(ស្រឡាញ់មេបំពេកូន)។

៚ ស្រឡាញ់កុំទៅញឹកៗ រលឹកសឹមទៅម្ដងៗ។

៚ ស្ត្រីមានរូបជាសម្បត្តិ ប្រុសចាត់វិជ្ជាជាធនធាន ភិក្ខុសង្ឃមានសីលជាទ្រព្យបានក្សត្រក្សាន្តមានពលជាភោគា។

៚ ស្រីល្អមានខ្នាស ដល់ចិត្តវិបល្លាស គេរ៏ឈ្មោះអាស្រូវ ចេញមុខបាត់អៀន ពេស្យាពាសផ្លូវ បុរាណប្រដៅ ឥត្ថីកិរិយា។ ខ្លះថា (ពេស្យាពាសផ្លូវ)។

៚ ស្រីឯណាមានប្រក្រតីពោលវិវាទ មានប្រមាថពោលនាំពាក្យឫស្យា ត្រេកបំណងឱ្យប្រុសគន់អាត្មា កិរិយាស្លដាំប្រចាំប្ដី ស៊ីបាយមុនប្ដីនៃអាត្មា ត្រេចយាត្រាផ្ទះគេពុំជូក្ដី ស្រី

យ៉ាងនេះបុរសក្នុងលោកិយ ទោះមានកូនមួយរយក្តីគប្បីលែង។

៙ ស្រីក្រមុំឯណាកបរូបរាង សព្វសារពាង្គលឿងដូចសុវណ្ណ នេត្រថ្លាយង់ដូចក្នុងភ្នែកម្រឹគា ចង្កេះរៀវសមស្មាគាងរាងរាជហង្ស។

៙ ឧរូស្រួលទំនួលសមឱរ៉ា មានកេសាខ្មៅយង់ចុងងខ្វង់ មានទន្តាក្រឹតល្អសរលង់នាភីទ្រង់ខូងជ្រៅកបមារយាទ។

៙ ស្រីមានល្អយ៉ាងនេះ ទាំងចំណេះចេះការបម្រុងញាតិ ទោះបីកើតក្នុងត្រកូលហីនជាតិ គួរសង្វាតអភិសេកឯកមហេសី។

៙ ស្រីមួយដូចក្រូចមួយដើម ឬ(ស្រីម្ដូចក្រូចម្ដើម)។

៙ ស្រីក្អោកមាស។ ៙ ស្រីកញ្ជើធ្លុះ។

៙ ស្រីខ្មៅដូចអំបែង ចេះតុបតែង ម្ហូបពេញថាស។ (អៀង ភូរិន្ទ)

៙ ស្រីដកទងវៀរបង់បុរសខ្សត់ បណ្ឌិតប្រាកដវៀរបង់ជនពាល ស្រីក្បត់ស្នេហ៍វៀរបង់សុក្កបក្ស វារីវៀរចាកផែនដីទួលខ្ពស់។

៙ ស្រីស្អាតត្រង់ភក្ត្រ សំពត់ល្អជាក់ ចំពោះជរជាយ អ្នកមានបុណ្យស័ក្តិ គ្រឿងយសឆោមឆាយ ជាតិឯករាជ្យសាយ ល្អផុតលោកា។

៙ ស្រីស្រស់កម្លោះខ្ចីម មុខខ្លាញ់រងើមឥតចេតនា។

៙ ស្រីសដូចចាន មារយាទមិនបាន ដូចឆ្កែក្រោមផ្ទះ។

៙ ស្រុកមានសឹកកុំបីទៅជួញខ្ចីរកធនធាន រីខ្លួនកំព្រាប្រាណរក្សានូវមាសប្រាក់ ចោរ

ក្អួយចាំប្លែប្លន់ ឥតតម្បន់ណានឹងលាក់ ខ្លួនឯងឥតបើដាក់ សារពើទ្រព្យបាត់អស់ឯង។

- ស្រើបតាមផ្គរ អរតាមភ្លៀង។

- ស្លឱ្យសាប អង្គុយឱ្យទាប ប្រាជ្ញឱ្យវៃ សម្តីឱ្យខ្ពស់ ឬ(គំនិតឱ្យវៃ សម្តីឱ្យទាន់)។

- ស្លម្ហូបឥតបំបោររករសគ្មាន គ្រឿងតែងប្រាណឥតរសអ្នកគ្មានទ្រព្យ សម្លឥតអំបិលរសមិនជាប់ ព្យាករណ៍គាប់ឥតរសមនុស្សកម្លៅ។

- ស្លាប់ដូចពស់ រស់ដូចកង្កែប។

- ស្លាប់ព្រោះជួយជាតិ គួរខំខ្មីឃ្មាត ឱ្យជាប់និស្ស័យ កើតជាកូនប្រុស គួរកុំអាល័យរូបរាងក្សីណក្ស័យ កេរ្តិ៍ឈ្មោះជាប់នៅ។

- ស្លាប់ក្នុងចម្បាំងជាមង្គលសួស្តី កាន់អាវុធនៅដៃមិនត្រូវភ័យសត្រូវ។ (ជុំ មួង)

- ស្លាប់ទុកដូចជារស់ បានចំពោះដល់ជនណា កាលរស់ខំធ្វើការ ជាប្រយោជន៍លោកទាំងពីរ។

- ស្លឹកឈើជ្រុះ មិនដែលឆ្ងាយពីគល់។

- ស្លឹកឈើឥតកម្រើក នឹងកម្រើកដ្បិតខ្យល់បក់ ទឹកថ្លាល្អឹកលើល្អក់ដ្បិត រលកបោកសោះសា។

- ស្លូតស្លាប់ វៀចវេរមានភ័ព្វ អាយុយឺនយូរ។

- ស្លៀកស្បង់មិនកោរសក់ ឆ្កុះកញ្ជក់ធ្មេចនេត្រា ឃើញសេះថាជាលា ឃើញគោថាជាកណ្តុរ។

៙ ស្លៀកសកាន់ព្រឹទ្ធចិត្តនៅខ្មៅ បោលប្រាជ្ញតាមខ្លៅចង់ចៀសបាប លូកវែកឱ្យដឹងរសប្រៃសាប យកខ្សាច់មកគាបបានប្រេងឬ?។

៙ ស្វាចង់ពាក់មួដ លាត្រាប់ឆ្កែពុត ក្អែកទឹកត្រាប់គោក ល្ងង់ត្រាប់បណ្ឌិត រាស្ត្រតាមប្រយោគ ត្រាប់ស្តេចឥតជោគ មិនសមឋានា។

៙ ស្វាមិនចោលបៀម សៀមមិនចោលក្បួន យួនមិនចោលពុត ខ្មែរបរិសុទ្ធ មិនចោលសច្ចៈ ឬ(ស្វាមិនបង់បៀម)។

៙ ស្វែងយសគឺស្វែងលាភ ទុរជនភាពតែងត្រូវការ រស់នឹងជាតិអាហារ ជាវាសនាជនសាមញ្ញ ។

៙ ស្វែងរករៀនច្បាប់ ពុំស្មើចិត្តជា។

៙ ស្វះស្វែងរៀនសូត្រឬការធ្វើ ដែលជាអំពើល្អមួនមាំ បើចេះព្រិលៗនៅព្រលាំ ត្រូវខំអត់ទ្រាំកុំលះបង់។

៙ ស្អប់ខ្ពើមការថោកទាប ជាសភាពមិនមែនសុខ ស្រឡាញ់ធម៌ជាប្រមុខ នៃស្ថានសុខគឺនិព្វាន។

៙ ស្អប់គេកុំអាលថា មានប្រាជ្ញាឱ្យចេះយល់។

៙ ស្អប់កុំអាលបាញ់ ស្រឡាញ់កុំអាលខ្ចី ឬ(កុំឱ្យរក)។

៙ ស្អប់ជំពប់លើ ស្រឡាញ់ពេញប្រាស។

៙ ស្អប់ណាស់មិនឱ្យជួបភក្ត្រា ដូចមហាក្សត្រានិងធនញ្ជ័យ ដោះប្រស្នាមិនរួចព្រួយព្រះទ័យ ហៅធនញ្ជ័យឱ្យមកវិញ។ (ជុំ មួង)

៚ ស្អប់អ្នកដែលស្រឡាញ់ខ្លួន សពីក្បួនតម្រាច្បាប់ ចាស់ទុំលោកប្រៀងប្រាប់ ថាដូចចាប់ឆ្នាំងបាយបោក។ (សុង ស៊ីវ)

★ ★ ★

# ហ

៙ ហង្សនៅកណ្ដាលហ្វូងកាកា សីហានៅកណ្ដាលនៃហ្វូងគោ តុរង្គនៅកណ្ដាលហ្វូងគទ្រភោ បណ្ឌិតនៅកណ្ដាលពួកពាលា។

៙ ហាឡើងវាស្លាក់ ខ្ទាក់ទៅវាស្លែង។

៙ ហាហួសចង្កា ថាហួសសេចក្ដី។

៙ ហាឡើងមិនធ្យាន ស្ដីមិនប្រមាណនឹងអង្គអាត្មា។

៙ ហ៊ានស្បែកដាច ខ្លាចស្បែកស្វិត ឬ(អ្នកហ៊ានស្បែកដាច)។

៙ ហ៊ីងគីង្គក់ជើងខ្លី អួតសម្ដីចង់ទៅកាន់ ស្រះស្រង់ហេមវន្ត ជនខ្ជិនខ្វាក់អួតចង់រត់។

៙ ហុចអម្បោះស្រណោះដៃ។

៙ ហុតសម្លសំឡឹងកាក ហូតច្រវាក្រាសសំឡឹងជ្រោយ ឬ(ហុតទឹកសំឡឹងកាក ទាញច្រវាក្រាកសំឡឹងជ្រោយ)។

៙ ហេតុភេទណាអំពើណាគេធ្វើប្លែក ធ្វើចំឡែកពីធម្មតាការគួរឆ្ងល់ តែត្រូវគិតពិនិត្យក្នុងឧបាយកល មុខជាមានប៉ះពាល់ដល់ខ្លួនយើងហើយ។

៙ ហេតុវិនាសទ្រព្យសម្បត្តិ៦យ៉ាង មួយបានខាងប្រមឹកផឹកសុរា ពីរដើរត្រេចលេងខុសវេលា បីគឺយាត្រាមើលរាំរបាំភ្លេង បួនគឺលេងល្បែងភ្នាល់បៀប៉ោពិត ប្រាំគឺគប់បាបមិត្រចិត្តអ្នកលេង ប្រាំមួយគឺកំជិលមិនចាត់ចែង ពួកនេះឯងប្រយោជន៍អន្តរធាន។

៙ ហែបុត្រឧត្តម ចូលបាខះខំ រៀនសិល្បសាស្ត្រ បើខ្ជិលយ៉ាងនេះ នឹងចេះកាលណា

យូរទៅគង់ជា ខ្ញុំគេមិនខាន។

៚ បើបាបានចេះ ក្នុងលោកិយនេះ គង់គេរាប់អាន បូជាប្រាក់យស ស័ក្តិខ្ពស់ថ្កើងថ្កាន ចូរកូនរៀនអាន សព្វៗថ្ងៃហោង។

៚ ហៃចៅជាតិពិសី ចូរលះក្តីច្រឡំទៅ ដោយជនពាលឃោរឃៅ គួរគាប់នៅនឹងសប្បុរស ។

៚ ចូរធ្វើបុណ្យប្រក្រតី សព្វរាត្រីថ្ងៃទាំងអស់ ចូរមានចិត្តសោមនស្សនឹក រលឹកព្រះត្រៃលក្ខណ៍ ។

៚ ហោរាប្រយ័ត្នមានអិល ជាងទងកាន់សីលប្រយ័ត្នទៀង ចៅក្រមប្រយ័ត្នមិនលំអៀង អ្នកផ្សៀងប្រយ័ត្នបាត់អក្ខរា។

៚ ហោរាច្រើនតែផ្សំ ទាយបន្លំយកប្រាក់កាស សមដូចពាក្យអ្នកចាស់ ភូតនៅហោរ ចោរនៅជាង។ (ជុំ មួង)

៚ ហៅហានពេក ដេកមិនសូវលក់។

**អ្នកឆ្វេសស្មារតី ស្លាប់គំនិត នោះបីមានជីវិតរស់នៅឡើយ**

**ក៏ទុកដូចជាស្លាប់ស្រេចទៅហើយ ៕**

ស្រង់ចាកសុភាសិតសម្តេចព្រះមហាសុមេធាធិបតី

សង្ឃនាយកគណៈមហានិកាយ (**ជោតញ្ញាណោ ជ.ណ**)

# ឡ

៙ ឡូៗមើលតែគេអារក។

៙ ឡាចៅលូកនាយអាយ មនុស្សទាំងឡាយមិនចូលចិត្ត លេងច្រើនឥតបើគិត គេស្អប់សម្ដីចៅ។ (ជុំ មួង)

៙ ឡឹកឡក់ដូចកូនក្មេង។

៙ ឡឹមឡុំមិនដឹងមុខបាត មុខជាខាតអន្តរធាន។

៙ ឡេមឡឹមម្ដងៗ ប្រសើរកន្លង ជានៅវក់វី បម្រើជានិច្ច ខ្លបត្រចៀកពីរ ផ្គាប់ផ្គុនម្ដេចក្ដី ពុំស្មើឡេមឡឹម ។ (ជុំ មួង)

៙ ឡូវៗដូចក្អែកបូល ជាប្រផ្នូលមានភ្លៀវមក បើតាមគិតលៃលក ជួនណាខុសជួនណាត្រូវ ។ (ជុំ មួង)

៙ ឡេះឡោះឡូឡា លោកថាអាប់យស។

៙ ឡេះឡោះដូចក្មេងវត្ត។

៙ ឡេះឡោះដូចទឹកកន្លះក្អម ឬ(រឡេះរឡោះ)។

៙ ឡើងចាងឡើងចិត្ត ឡើងជោរពិតៗ ដោយអាងអ្វីៗ នៅពីក្រោយខ្នង ក្អេងក្អាងសម្ដី បើឥតអាងអ្វី ធ្វើមុខក្រញ៉ុះ។ (ជុំ មួង)

៙ ឡើងជោរដូចទឹកក្រហុក។

៚ ឡើងជោររឡាម ខ្វះមួយចំអាមទាល់មេឃ។ (សុង ស៊ីវ)

៚ ឡើងភ្នំសនឡឹមកុំប្រណាំង សេពកាមតាមកម្លាំងតិចៗរ៉ា។ (សុត្តន្ត ប្រីជា ឥន្ទ)

៚ ឡើងទ្រើងដូចឃ្លោកដូចត្រឡាច គ្មានកោតខ្លាចបុគ្គលណា ដល់ទ្រើងរំលំដួលផ្កាប់ផ្ងារ ធ្វើមុខដូចស្វាឱ្យគេជួយ ។ (សុង ស៊ីវ)

★ ★ ★

# អ

៙ អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ បង់បោយហួសស្មា ពុំមើលប្រមាណ និងប្រាណអាត្មា ហាហួសចង្កា ថាហួសសេចក្តី។

៙ អញ្ចុលទុកឱ្យគង់ ប្រាក់ក្នុងថង់ទុកឱ្យជា ។ (កិរកាល)

៙ អណ្តាតជាអាទិកន្លង ឱ្យសុខទុក្ខផង ពីព្រោះអណ្តាត ។ ឬ(កើតសុខទុក្ខផង ឬអស់ទ្រព្យធនផងពីព្រោះអណ្តាត)។

៙ អណ្តើកនៅជើង ចាំរកឆ្កែកោះ។

៙ អត់ឱនឥតទោស ធ្វើចិត្តសន្តោស បង្កើតជាទ្រព្យ មេត្រីជាញាតិ រក្សាដល់ស្លាប់ចៀសក្តីពុំគាប់ ជាគន្ធពិដោរ ឬ(អត់ឱនអត់ទោស)។

៙ អនាគតយើងកុំអាលមើលឃើញឡើយ ហេតុនេះហើយអ្នកប្រាជ្ញហាមប្រាមប្រាប់ថា កុំអាលស្មានថាបានសុខទុក្ខយ៉ាងណា ព្រោះសង្ខារតែងតែល្បៀងមិនទៀងទាត់។

៙ អន្ទង់វែង រកឆ្នាំវែង ឬ(អន្ទង់វែងចាំរកឆ្នាំងវែង?)។

៙ អបាយមុខនាំទុក្ខគ្រប់កាល នាំចិត្តបណ្តាលរោលរាលគ្រប់ប្រាណ ត្រូវចំណាយទ្រព្យច្រើនលើសប្រមាណ ធ្វើបុណ្យកល្យាណបានស្រួលអាត្មា។

៙ អស់កិច្ចទាំងពួងច្រើនអសារ ខូចការលិចលង់បង់អភ័ព្វ ព្រោះតែល្ងង់មិនចេះផ្គាប់ឱ្យជាប់និស្ស័យនឹងអ្នកធំ។

៙ អាត់តែវិវរ ឆ្កែទរប្រហុកអស់ ឬ(អាល័យតែវីវរ...)។

៙ អាកាសទីខ្ពស់ ស្លាប់ស្វាត់ស្រស់បស់ ប្រសើរថ្លៃថ្លា ឯអាកាសទាប ពុំសូវរាបសា មានព្យុះសង្ឃរា វរវឹកវិលវល់។

៙ អាកាសជាកម្លាំងនៃបក្សា គង្គាជាកម្លាំងត្រីខ្មៅគ្រំ រាជាជាកម្លាំងនៃអ្នកក្រៀមក្រំ ក្តីសោកយំជាកម្លាំងនៃកុមារ។

៙ អាក្រក់ឬល្អសឬខ្មៅ វិធីក្នុងក្រៅប្រដៅខ្មែច បើផ្លូវអាក្រក់គួរយើងគេច កុំភ្លេចផ្លូវល្អ តឱ្យជាប់។

៙ អាគកដូចអាចៃ។ ៙ អាគកណាក៏ស៊ីស្រូវដែរ។

៙ អាគកណាដូចអាគកណាដែរ។ ៙ អាគមផ្សំអាយុ។

៙ អាងតែមានអណ្តាតចេះតែផ្ទាត់ទៅ។

៙ អាងតែអណ្តាតឥតឆ្អឹងចេះតែគ្រលាស់ទៅ។

៙ អាចារ្យប្រែចិត្តជាអាចារ្យចោរ ខ្លួនទំមែកពោធិស៊ីផ្លែជ្រៃ ទុច្ចរិតនាំខ្លួនឱ្យហីនហៃ អាស្រ័យសុចរិតកើតសុខា។

៙ អាចារ្យចេះទូន្មានហាមប្រដៅ បុគ្គលខ្លៅឱ្យលះបង់បាបបាន អាចារ្យនោះជាទីគាប់រាប់អាន នៃសន្តានសប្បុរសទាំងអស់គ្នា។

៙ តែពុំគាប់នៃចិត្តអសប្បុរស ព្រោះពុតអសប្បុរសស្វែងពាលា ស្រឡាញ់តែអំពើបាបវេរា ផ្លូវសួគ៌ាជាទីស្អានសប្បុរស។

៙ អាចារ្យមិនពោលពិសដទៃ ថាជាពិសលើសនៃពិសទ្រព្យសង្ឃ ពិសឯទៀតអាចសម្លាប់តែអង្គៗ ពិសទ្រព្យសង្ឃអាចសម្លាប់ជនទូទៅ។

꩜ អាជ្ញាដែលមហាពាលកំណាច ឱ្យដល់អ្នកប្រាជ្ញដោយសរសើរ បណ្ឌិតគឺប្រាជ្ញកប់ដំណើរ សរសើរដោយគុណការគាប់ចិត្ត។

꩜ អាដែងសត្វសុនខ ឬកអាក្រក់ដេកតែក្រ ឃើញគ្នាទោះខ្មៅស មិនដែលអរស្រាប់តែខាំង ។

꩜ អាណាវៀចៗបានជាកង់ (បកុង) អាណាត្រង់ៗបានជាប្រែក។

꩜ អាយុមិនអស់មិនស្លាប់។

꩜ អាវុធស្តេចស្រេចនៅព្រះឱង្ការ អាវុធសមណាគឺសច្ចៈ អាវុធសេដ្ឋីគឺមាសប្រាក់ អាវុធអ្នកក្រីក្រគឺកម្លាំង។

꩜ អាវុធខ្លានៅត្រង់ចង្កូម សិង្ហសីហ៍ស្រមូមពឹងសម្រែក សត្វចចកពឹងធ្មេញខាំហែក ចំណែកពួកពាលពឹងកម្លាំង។

꩜ អាវែកគេស៊ីក្រោមភ្នែក អាវែកនៅតែមិនដឹងខ្លួន។

꩜ អាស្រ័យក្នុងលោកកុំលាក់មុខ ទង្គក់នឹងលោកកុំអើតក បើល្ងង់ខ្លៅត្រូវខ្លាចក្រ ត្រដរឱ្យដល់ពលៈកាយ។

꩜ អាស្វាមិនស្គាល់ព្រនង់។

꩜ ឥតដំបៅហៅជំងឺ ដំបៅមិនឈឺយកឈើចាក់។

꩜ ឥតមិនឥត យកកទៅលអន្ទាក់ ឬ(អត់មិនអត់...)។ ឬ(មិននៅៗយកកទៅលអន្ទាក់)

꩜ អឹមជាងអៀង ស្មៀមជាស្រដី ស៊ីចេកខ្ចី ជាជាងនៅមាត់ទទេ។

៙ ឧទម្ពរទុំ សម្បកក្រៅរុំ ក្រហមរលង់ ខាងក្នុងពេញនៅ ដង្កូវមមង់ដូច មនុស្សទ្រនង់ចិត្តជូរឫស្យា។

៙ អុសទឹកស្រូវអង្ករ យកចេញចាយមានកំណត់។

៙ អូសសម្រាស់ប្រទះពាក្យ។

៙ អូសទូកកុំឱ្យល្អាន ចាប់ត្រីបានកុំឱ្យល្អកទឹក។

៙ អូសឫស្សីច្រាសចុង ឬ(តឹងដូចអូសឫស្សីច្រាសចុង) ឬ(តឹងដូចអូសឆ្កែចុះទឹក)។

៙ អើធ្វើតែត្រូវពុំសូវត្រូវល្អទេ គង់តែមានគេល្អគ្មានឃ្មើសលើសជាង បើគេត្រូវឯងពុំសូវឃើញជាក់ស្ដែង គេល្អខែងឯងថាគេមិនដល់ខ្លួន។

៙ ឯស្រានឹងស្រីនឹងល្បែង គួរលះគួរលែងកុំប្រព្រឹត្ត ព្រោះនាំឱ្យខ្វល់អំពល់ចិត្ត វិបរិតផ្កាសៗក្នុងលោកិយ។

៙ តែថាឯស្រានិងការល្បែង គួរលះគួរលែងបានមិនអ្វី ឯត្រង់ចំណង់ចង់នឹងស្រីលោកិយយើងក្រលះបានណាស់។

៙ ឯស៊ីប៉ុន្មានមិនបាត់ចង់ មិនបាត់ចង់នោះគួរចូលចិត្ត ចង់ឃើញរូបល្អសម្បុរសល្អិតជាទីគាប់ចិត្តឥតស្រាកស្រាន្ត។

៙ ឯផ្លែខ្នុរខាងក្រៅបន្លា ក្នុងមានឱជារសដូចម្រឹត ធម្មតានៃជនជាអ្នកមានចិត្ត ស្អាតល្អប្រព្រឹត្តក៏ដូច្នោះឯង។

៙ ឱប្រាសាទស្អាតប្រសើរភ្លឺច្រវាត់ ម្ចាស់ដើរចោលទៅបាត់ស្ងាត់សូន្យឈឹង ទុកដំណែលដែលធ្លាក់នៅព្រៅចង្រ្កឹង ឱសង្ខារយើងយ៉ាងហ្នឹងម្ដឹងទេតើឬ (សុត្តន្តប្រីជាឥន្ទ)។

៙ ឱ្យចង់ឱ្យចាំទំនៀមព្រេង ឱ្យចេះចាំចែងកបបរិយាយ ឱ្យរាប់ព្រៀងលានញាតិជិតឆ្ងាយ ឱ្យផ្សាយមេត្តានឹងផលផង។

៙ ឱ្យចេះត្រង់ណាឱ្យមាំមួន ឱ្យចេះចាំក្បួនតម្រាសោត ឱ្យពេញជាប្រាជ្ញលោកិយកោត ឱ្យមានឫកសោតសមប្រាជ្ញប្រាយ។

៙ ឱ្យរៀនអត់ឱនពាក្យជូនតា ឱ្យរៀនវិជ្ជាសិល្បសាស្រ្តស្អាត ឱ្យរៀនចិត្តធ្ងន់កុំប្រមាថ ឱ្យខំសង្វាតរកទ្រព្យធន អ្នកខ្លះថា(ប្រមាទ)។

៙ ឱ្យរៀនតម្រាសណ្តាប់ធ្នាប់ ឱ្យខំរកទ្រព្យកុំលួចប្លន់ ឱ្យសង្រ្គោះញាតិមានអាសន្ន ឱ្យចេះអត់ធន់កុំក្រេវក្រោធ ឬ(រៀនតម្រាប់...)។

៙ ឱ្យមានមេត្តាប្រយ័ត្នទោស ឱ្យខំសន្តោសសល់វេរា ឱ្យមានមេត្រីប្រណីគ្នា ឱ្យជាប់ឱ្យនៅជាធម៌ខន្តី។

៙ ឱ្យស្គាល់ទាបខ្ពស់ដ៏រាប់ទៅ ឱ្យប្រាជ្ញខ្លៅនៅរៀមច្បង ឱ្យចងចាំចិត្តខ្លាចហ្មង ឱ្យត្រងឱ្យត្រាប់ច្បាប់ធម្មតា។

៙ ឱ្យមានក្តីបារម្ភ ធ្វើស្រែកុំចោលចម្ការ ដឹងដែកកាំបិតព្រា ទុកឱ្យជាកុំឱ្យបាត់។

៙ ឱ្យទានចិត្តឱ្យស្មោះ កុំអាឡោះអាល័យស្ងួន ទ្រព្យនេះនឹងនាំខ្លួន ទៅបរលោកកុំសោះសូន្យ។

៙ ឱ្យវិញ្ញាណទាំងប្រាំមួយជួយធ្វើការ កុំបណ្តោយណាផ្អាកឈប់ខាន តែមិនគ្រប់អង្គប្រាំមួយជួយយោងប្រាណ នោះនឹងបានក្តីកំហុសខុសពុំលែង។

៙ អ្វីដែលជាសត្រូវគ្នាពីមុនមក ត្រូវលៃលកមើលឱ្យជាប់ការរាក់ជ្រៅ កុំប្រហែសធ្វេស

ជឿចិត្តមនុស្សឃោរឃៅ គំនុំនៅចងជាប់ស្និទ្ធឥតរសាយ។

๛ អំបិលជារសសម្ល ស្រទៀបរើអ ជារសនៃតូរ្យតន្ត្រី។

๛ អំពៅរសផ្អែមវិសេសណាស់ ផ្អែមស្រីល្អល្អះលើសអំពៅ សុភាសិតបណ្ឌិតពោលប្រដៅ ផ្អែមលើសអំពៅនិងស្រីល្អ។

๛ អាំងភ្លើងឱ្យអាំងពីខាងផ្ទៃ អាំងថ្ងៃឱ្យអាំងពីខាងខ្នង។

๛ អ្នកមានមិនដែលបិត អ្នកក្រមិនដែលបីជាតិ។

๛ អ្នកប្រាជ្ញកាន់ពាក្យទៀង កុំឱ្យល្បៀងពាក្យបុរាណ។

๛ អ្នកចេះដប់ មិនស្មើអ្នកប្រសប់មួយ។

๛ អ្នកដំកុំធ្វើដែក អ្នកប្រមឹកកុំធ្វើស្រា។

๛ អ្នកមានកុំអាលអរ អ្នកក្រកុំអាលភ័យ។

๛ អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅពឹងសំប៉ាន ឬ(ដូចសំពៅនូវសំប៉ាន)។

๛ អ្នកខ្ពស់រក្សាទាប ដោយសុភាពធម៌បុរាណ។

๛ អ្នកឆ្អែតរក្សាឃ្លាន នាអ្នកមានរក្សាឆ្មា។

๛ អ្នកមុនកុំសោយ អ្នកក្រោយមានលាភ។

๛ អ្នកឃើញកាត់គ្រោះតាមរាសី ចៅក្រមកាត់ក្ដីតាមពាក្យបណ្ដឹង។

៙ អ្នកឡើងមិនបានបេះ អ្នកប្រឡះមិនបានស៊ី អ្នកនៅទំនេរស៊ីឆ្អែត។

៙ អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកស្វិត ឬ(អ្នកខ្លាចស្បែកជា)។

៙ អ្នកណាមានគេសរសើរ អ្នកនោះឯងមានគេនិន្ទា។ (នួន ប៊ុត)

៙ អ្នកដេកឆាប់លក់ ដ្បិតឥតបើគិត។

៙ អ្នកណែនាំគួរពិនិត្យ ពិច័យកាមតាមត្រឹមត្រូវ បើចេះតែពោលថាប្លូវៗ នឹងកើតអាស្រូវដល់អាត្មា។

៙ អ្នកសប្បាយច្រើនមានទុក្ខ អ្នកប្រឹងលុយភក់ទើបផុតភ័យ សង្ខាតាក់តែងតាមវិស័យ សុខទុក្ខបច្ច័យផ្លាស់វេនគ្នា។

៙ អ្នកមានប្រាជ្ញចេះសព្វអន្លើ ស្មឹងស្មាធិនៅស្មើគិតពិចារណា អ្នកនោះរស់នៅមួយថ្ងៃគង់ជា បានឈ្មោះហៅថារស់នៅប្រសើរ។

៙ អ្នកត្រកូលទាបថោក តែស្ទាត់ផ្លូវលោក សិល្បសាស្ត្រអាគម ចេះដឹងសព្វគ្រប់ចំណេះតូចធំ ទេវតាឥន្ទព្រហ្ម គង់បូជាដែរ។

៙ អ្នកស្រែធ្វើស្រូវ រដ្ឋមន្ត្រីត្រូវ រក្សាជនជាតិ ពាណិជទិញលក់ ពួកជាងខ្មីឃ្មាត ក្មេងៗសង្វាត រៀនវិទ្យាសាស្ត្រ។

៙ អ្នកល្ងង់ត្រូវរៀនពីអ្នកចេះ ចង់បានចំណេះត្រូវស្តាប់គិត ចង់ទៅនិព្វានត្រូវហាត់ចិត្ត បើទីងងឹតត្រូវរកប្រទីប។

៙ អ្នកធំកុំប្រមាថអ្នកតូច ស្មៅវល្លិវេញគួចចងដំរី ស្តេចពឹងរាស្ត្រសង្ឃពឹងវិន័យ មច្ឆាជលស័យពិតពឹងទឹក។

៚ អ្នកចិត្តជ្រះថ្លា នៅត្រង់ណាចេះតែមាន មិនដែលខ្សត់អត់ឃ្លាន ព្រោះផលទានពីជាតិមុន។

៚ អ្នកដែលចេះដឹងច្រើន តែងចម្រើនយ៉ាងវិសេស ពួកអ្នកឥតចំណេះ តែងវិនាសអន់អាប់ខ្លួន ។

៚ អ្នកចូលចិត្តសេពគប់ នឹងអសប្បុរសធម៌ ការសេពនោះមិនល្អ ជាហេតុករឱ្យអន្តរាយ។

៚ អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល ហើយមិនប្រមូលសាច់ញាតិសន្តាន មើលងាយញាតិខ្លួនដោយអាងខ្លួនមាន នោះជាប្រធាននៃសេចក្តីវិនាស។

៚ អ្នកដែលស្រឡាញ់ធម៌ ត្រឹមត្រូវល្អមិនដែលសូន្យ អ្នកស្អប់ធម៌តែងអូន ទាបសូនយថោកវិនាស។ (បរាភវសូត្រ)

៚ អ្នកស្និតចិត្តស្នូរជន ចាយទ្រព្យធនចាយក្នុងគិត ឱ្យទានឱ្យមិនពិត គំនិតនៅក្នុងកំណាញ់ ។

៚ អ្នកស្លូតស្អប់អ្នកកាច ឬកអ្នកប្រាជ្ញស្ងៀមមិនស្តី ឬកមនុស្សកាឡកណ្ណី ស្អប់សម្តីមិនហ៊ានជិត។

៚ អ្នកខូចនិងអ្នកជា នៅជិតគ្នាមិនសូវបាន អ្នកចេះច្បាប់បុរាណ មិនខានស្អប់អំនើបថ្មី

៚ អ្នកខ្លាចស្អប់អ្នកហ៊ាន ជាតិអ្នកមានស្អប់អ្នកក្រ អាក្រក់ស្អប់អ្នកល្អ ព្រោះជនឈ្មួងរាប់អានគេ។

៚ អ្នកប្រាជ្ញពឹងគម្ពីរ អ្នករកស៊ីពឹងពាក្យឆុត ខ្លាចស្លាប់ភ័យតក់ស្លុត រត់ស្ទឹតស្លក់ទៅរក

ក្បួន ។

៚ អ្នកក្រមានទ្រព្យ ថៅហ្វាយខ្លួនគាប់ នៅគេហដ្ឋាន កិច្ចការបំពេញ ស្រេចនៅខ្លួនប្រាណ ខ្លួនពឹងពាក់បាន តាមចិត្តប្រាថ្នា។

៚ អ្នកស្វែងសម្បត្តិ នឿយហត់ពេកក្តាត់ ទាំងយប់ទាំងថ្ងៃ គិតគូរធ្វើការ ញាប់ជើងញាប់ដៃ លំបាកពេកក្រៃ ដោយសារសម្បត្តិ ។

៚ អ្នកមានទ្រព្យា មិនខ្វះមិត្រភ្វា រាប់អានស្រឡាញ់ អ្នកក្រកម្សត់ មិនសូវហ៊ានចេញមុខមាត់ពេញលេញ ញាតិមិត្រឃ្លាតឆ្ងាយ។

៚ អ្នកពោលច្រើនមិនបានធ្វើ បាត់ការស្ទាក់ស្ទើរឥតប្រយោជន៍ ខូចពេលខាតកាលនាំហីនហោច អាសោច៏អសារឥតអំពើ។

៚ អ្នកមកពីឆ្ងាយ ភូតភរអធិប្បាយ តាមចិត្តប្រាថ្នា តែលោកអ្នកប្រាជ្ញអាចយល់ការរៀចត្រង់យ៉ាងណា ដ៏អាចដឹងដល់។

៚ អ្នកដើរច្រើនស្រុក ដឹងរឿងច្រើនមុខ ព្រោះបានឃើញច្រើន គំនិតអ្នកប្រាជ្ញ ភ្លឺថ្លាចម្រើន ដោយខំក្រវើន យកចិត្តទុកដាក់។

៚ អ្នកណាចិត្តហានក្លា ព្រេងវាសនាបើកទ្វារឱ្យ អ្នកណាចិត្តកំសោយ តែងថ្លស់ឆ្លោយជួបក្តីក្រ។

៚ អ្នកណាឧស្សាហ៍ ព្យាយាមកាប់ឆ្កា មែកឈើរាល់ថ្ងៃ លុះអនាគត បាកុំសង្ស័យកើតផ្លូវប្រាស្រ័យ ក្នុងព្រៃព្រឹក្សា។

៚ អ្នកកាន់សច្ចៈគេទុកចិត្ត អ្នកក្លាហានពិតស្តេចត្រូវការ អ្នកចេះឱសថក្បួនទ្រព្យា

អ្នកមានរោគាតែងតែរាប់អាន ។

៙ អ្នកណាអួតខ្លួនជាប្រាជ្ញប្រោក បែរបានប្រយោគហៅល្ងង់ស៊ប់ អ្នកណានៅស្ងៀមភ្លឺថ្ងៃយប់ អ្នកផងគោរពចូលសាកសួរ។

៙ អ្នកនៅស្ងៀមៗ អ្នកចេះលាក់លៀម ឬកពានឹងធឹង គេត្រូវប្រយ័ត្ន ដូចកលទឹកនឹង លិចស្រីមក្នុងស្នឹង មិនដឹងខ្លួនស្លាប់។

៙ អ្នកជក់មិនខ្លាចផ្សែង អ្នកផឹកមិនខ្លាចពែង អ្នកស្វះស្វែងមិនខ្លាចឆ្ងាយ (អៀង ភូរិន្ទ)

៙ អ្នកសាងសុចរិត ប្រកាន់ធម៌ពិត តាមក្រឹត្យបុរាណ ទោះមានទោសទុក្ខ សុទ្ធតែស្លាប់ប្រាណ ត្រង់ធម៌កល្យាណ មិនបានបោះបង់។

៙ អ្នកតូចតោងពឹងនឹងអ្នកធំ អ្នកធំពឹងតូចទើបសុខសាន្ត នឹងនៅម្នាក់ឯង ទោសពុំបាន ពុំសុខសាន្តគ្រាណដូចពឹងឡើយ។

៙ អ្នកណាមិនរៀននូវចំណេះ មុខជាមិនចេះមិនចម្រើន អ្នកណាមិនខំគិតក្រវើន នឹងបានទ្រព្យច្រើនមកពីណា។

៙ អ្នកពោលល្អពិត ស្ងៀមស្ងាត់ក្នុងចិត្ត គំនិតប្រុងស្តាប់ ក្រេបយករសជាតិ ឱវាទគួរគាប់ ទើបត្រូវសណ្តាប់ បណ្ឌិតទូន្មាន។

៙ អ្នកណាឧស្សាហ៍ខំខ្នះខ្នែង ប្រឹងប្រែងគ្រប់ប្រាណគ្មានរួញរា ខំរៀនខំរិះរកទ្រព្យា អ្នកនោះមុខជាមានទ្រព្យច្រើន។

៙ អ្នកដែលចេះមិនប្រព្រឹត្ត តាមធម៌ល្អពិតដែលរៀនយក បុរាណហៅចេះកប់ពពកត្រឡប់ជាជ្រកអាចម៍ជន្លេន។

៚ អ្នកខ្លះមានចិត្តល្អណាស់ណា តែមានវាចាអសុរោះ អ្នកណាមិនដឹងជាដូច្នោះ ថាមិនល្អសោះព្រោះវាចា។

៚ អ្នកដែលប្រមាថមិនបាសុខ ច្រើនតែកើតទុក្ខពេកកន្លង ទាំងក្នុងលោកនេះនាយហោង សឹងរងវេទនាជាអនេក។

៚ អ្នកដែលធ្វើការប្រញាប់ណាស់ រមែងតែងផ្លាស់ធ្វើច្រើនដង ព្រោះធ្វើមុនខុសធ្វើក្រោយសង ដល់ធ្វើច្រើនដងទៅជាយឺត។

៚ អ្នកដែលព្រហើនភ្លើនបោងហោង ឫកកោងក្រអឺតឡឺតហួសខ្នាត តែងថយស័ក្តិយសរលស់ខាត ព្រោះចិត្តឧត្បាតប្រមាថគេ។

៚ អ្នកធ្វើជំនួញ ចេញសំពៅជួញ ទាត់ក្បាច់ចំណេញ មិនដែលហៅខាត អ្នកចម្បាំងចេញ ចូលទៅប្រដេញ ព្រោះយើងជោគជ័យ។

៚ អ្នកឥតធនធាន ចង់ទទួលទាន រសឆ្ងាញ់លើសលែង ជនឥតកម្លាំង ចង់តាំងប្រទ្បែង ចំបាប់ទាត់ប៉ែង សំដែលអំណួត។

៚ ជនឥតបញ្ញា ល្មោភថ្លែងចរចា ប្រាថ្នាគេអួត ជនបីនេះប្រើ ទុកស្មើគេឆ្កួត ព្រោះទ្បើងអំណួត ល្មោភហួសប្រមាណ។

៚ អ្នកដទៃឱ្យប្រយោជន៍ទុកជាញាតិ ញាតិបើឃ្លាតទុកជាជាតិអ្នកដទៃ រោគក្នុងកាយទុកជាទោសប្រកបភ័យ ឈើក្នុងព្រៃជាឱសថទុកជាគុណ ។

៚ អ្នកមានសម្បត្តិនិងអ្នកប្រាជ្ញ និងស្តេចគ្រងរាជ្យនិងព្រែកស្ទឹង និងពេទ្យវេទ្យាជាទីពឹង ប្រាំនេះសូន្យឈឹងក្នុងស្ថានណា។

៙ ស្ថាននោះមិនគួរនៅអាស្រ័យ ជាស្ថានចង្រៃឥតសុខា កំណត់ថ្ងៃមួយៗវេលា កុំនៅខំយាត្រាទៅឱ្យផុត។

៙ អ្នកធំច្រើនប្រាជ្ញច្រើនក្នុងទីណា សឹងប្រាថ្នាចង់ធំទីទៃៗ ការងារដែលធ្វើនោះពុំប្រពៃ ចុះក្នុងន័យហីនជោគលោកវិនាស។

៙ អ្នកសេវកាមាត្យចូលផ្គាប់បុណ្យ កុំបរិភោគកាមគុណស្មើក្សត្រា កុំគប្បីធ្វើអាកប្បកិរិយា ពោលវាចាកែងកោងមិនកោតក្រែង។

៙ កុំលាបគ្រឿងសុគន្ធពាក់មាលា ស្លៀកភូសាអង្គាឱ្យលើសលែងកុំសំអាងយ៉ាងយសព្រះគម្ដែង អញ្ជើញតែងឱ្យសមសភាពខ្លួន។

៙ អ្នកមានគុណវិជ្ជាចេះលើសលប់ បញ្ញាស្មើចមកភពសព្វញ្ញុតិញ្ញាណ តែគ្មានលោកជាធំនឹងរាប់អាន លើកតម្កល់ក្នុងស្ថានពុំបានល្អ។

៙ កែវមណីយ៉ាងថ្លៃកាត់ពុំបាន អាស្រ័យមាសជាស្ថានជាផ្ទះទ្រ ទើបមណីរុងរឿងឡើងលម្អ បើឥតមាសនឹងទ្រល្អម្ដេចបាន។

៙ អ្នកប្រាជ្ញឃើញភ័យពុំទាន់ដល់ យោបល់គិតវៀរពីចម្ងាយ លុះកាលឃើញភ័យមកដល់កាយ មុខនៅពព្រាយឥតភិតភ័យ។

៙ អ្នកអួតខ្លួនថាបរិសុទ្ធ អ្នកនោះប្រាកដជាសៅហ្មង អ្នកអួតថាខ្លួនចេះចម្បង ប្រាកដតែម្ដងគឺល្ងង់ខ្លៅ។ (សុង ស៊ីវ)

★ ★ ★

**ឃើញគេថ្កុំថ្កើង កុំចចើងតាមគេ ហួសមាឌខ្លួន**

**ប៉ុន្តែមិនត្រូវបន្ធូរបន្ថយព្យាយាមឡើយ៕**

ស្រង់ចាកសុភាសិត

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយ

គណៈមហានិយា (**ជោតញ្ញាណោ ជ.ណា**)

**ចៀសចាកអកុសល ក្តីអំពល់ពីទុក្ខសោករូបរាងតែង**

**ស្មោកគ្រោក គួរឱ្យរកព្រះអរហំ៕**

ស្រង់ចាកសុភាសិត

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយ

គណៈមហានិកាយ ចន្ទត្ថេរោ (**ថ្នាក់ ហិន**)

**បើជឿព្រះ ធ្វើតាមព្រះពិតប្រាកដ នៅបួសក៏ចម្រើន**

**នៅជាគ្រហស្ថក៏ចម្រើនៗ**

ស្រង់ចាកសុភាសិត

សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា

**(វជិរប្បញ្ញោ លី ឯម)**

**តណ្ហាជាហេតុ សេចក្តីទុក្ខជាផល ឧបាយរំលត់**

**ទុក្ខជាហេតុ និរោធធម៌ (ធម៌រំលត់ទុក្ខ) ជាផលៗ**

**នេះជាសច្ចធម៌ពិតណាស់**

ស្រង់ចាកសុភាសិត

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ

**(ជោតញ្ញាណោ ជួន ណាត)**

**មនុស្សដែលចេះសម្អាត ខាងក្រៅខ្លួន ចិត្តខាងក្នុងក៏ស្អាតដែរ**

**បើបែរជាក្រខ្វក់ខាងក្រៅហើយ ចិត្តខាងក្នុងពិតជាក្រខ្វក់ៗ**

ស្រង់ចាកសុភាសិត

សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា

**(វជិរប្បញ្ញោ លឹ្វ ឯម)**

**កិច្ចការដំបូង តែងតែមានខាស់ខុសខ្លះ**

**លុះត្រាតែខ្ចីកស័ប់ស៊ាំ ទើបមិនភ្លាត់ភ្លាំង**

ខុសទៀត។

ស្រង់ចាកសុភាសិត

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក

គណៈមហានិកាយ

**(ជោតញ្ញាណោ ជួន ណាត)**

**មនុស្សអលជ្ជី ឈ្មោះថាស្លាប់ទាំងរស់ស្អុយទាំងស្រស់ៗ**

ស្រង់ចាកសុភាសិត

សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា

**(វជិរប្បញ្ញោ លី្វ ឯម)**

**បានគ្រូវ មកពីស្គាល់ខុស បើមិនដូច្នោះទេ**

**រកគ្រូវពុំឃើញឡើយៗ**

ស្រង់ចាកសុភាសិត

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយ

គណៈមហានិកាយ

**(ជោតញ្ញាណោ ជួន ណាត)**

**ត្រូវដឹងខ្លួនថា អាត្មាអញត្រូវចាស់ ត្រូវឈឺ ត្រូវស្លាប់**

**ត្រូវព្រាត់ប្រាសចាកពីគ្នីគ្នាគេចមិនរួច ព្រោះកើត**

**ក្នុងស្រុកចាស់ ឈឺ ស្លាប់ៗ**

ស្រង់ចាកសុភាសតិ

**(ព្រះពោធិវ័ង្ស ហួត តាត)**

វាយចម្លងអត្ថបទដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ

**ថៃ ប៊ុនឆាយ**